# ព្រះរាជាណាចក្រកម្ពុជា

*ជាតិ សាសនា ព្រះមហាក្សត្រ*

# រាជរដ្ឋាភិបាលកម្ពុជា

# ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹង
# ការប្រែប្រួលអាកាសធាតុកម្ពុជា

## ២០១៤-២០២៣

ឆ្នាំ២០១៣

គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត

បច្ចុប្បន្ន ការប្រែប្រួលអាកាសធាតុបានក្លាយជាហានិភ័យធ្ងន់ធ្ងរមួយ ដែលមនុស្សជាតិបាននិងកំពុងជួបប្រទះ ហើយក៏ជាប្រធានបទអាទិភាពដែលពិភពលោកកំពុងព្រួយបារម្ភនៅក្នុងសតវត្សរ៍ទី២១នេះ។ ស្របពេលដែលភពផែនដីកំពុងឡើងកំដៅ ផលប៉ះពាល់ជាអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ មកលើការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងចីរភាពបរិស្ថាននៅទូទាំងពិភពលោក នឹងបន្តកើតមានឡើងកាន់តែញឹកញាប់និងខ្លាំងឡើងៗដែលទាមទារឱ្យយើងទាំងអស់គ្នាត្រូវបង្កើនការយកចិត្តទុកដាក់ ក្នុងការស្វែងរកដំណោះស្រាយបន្ទាន់។

តំបន់អាស៊ីអាគ្នេយ៍នឹងជួបប្រទះនូវការគំរាមកំហែងពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ កាន់តែច្រើនឡើង ដែលនាំឱ្យបាត់បង់ជីវិតមនុស្ស ធ្វើឱ្យខូចខាតដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងធនធានធម្មជាតិ។ យើងសង្កេតឃើញមាននិន្នាការគួរឱ្យព្រួយបារម្ភនៃគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ការជ្រាបចូលនៃទឹកប្រៃ និងធាតុអាកាសមិនប្រក្រតីកាន់តែញឹកញាប់និងធ្ងន់ធ្ងរ ជាពិសេសនៅក្នុងទសវត្សរ៍កន្លងទៅ។ ការសិក្សាស្រាវជ្រាវបានបង្ហាញថានិន្នាការនេះនឹងកាន់តែកើនឡើងថែមទៀតរហូតដល់ចុងសតវត្សរ៍នេះ។ ប្រការនេះ បានធ្វើឱ្យការប្រែប្រួលអាកាសធាតុក្លាយជាបញ្ហាចម្បងមួយ ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់លើការរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសមស្រប នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ថ្នាក់តំបន់ និងអន្តរជាតិ។

ក្រោយពីបានផ្តល់សច្ចាប័នលើអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុនៅឆ្នាំ ១៩៩៦ មក កម្ពុជាបានចូលរួមយ៉ាងសកម្មជាមួយសហគមន៍អន្តរជាតិ ក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីដោះស្រាយបញ្ហាប្រឈមនានាដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ ប្រទេសយើងនៅតែងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ដោយសារការពឹងផ្អែកយ៉ាងខ្លាំងទៅលើវិស័យនានា ពាក់ព័ន្ធនឹងអាកាសធាតុ ដូចជា កសិកម្ម ធនធានទឹក ព្រៃឈើ ជលផល និងទេសចរណ៍ជាដើម ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់កំណើនសេដ្ឋកិច្ច និងការទ្រទ្រង់ជីវភាពប្រជាជនភាគច្រើន។ គួរកត់សម្គាល់ថា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជាទទួលបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលនាំឱ្យមានកំណើនផលិតផលក្នុងស្រុកសរុបកំណើនប្រាក់ចំណូលគ្រួសារ និងការថយចុះនៃអត្រាភាពក្រីក្រ។ ក៏ប៉ុន្តែ ការធានាបាននូវវឌ្ឍនភាពជាប្រចាំនៅក្នុងលក្ខខណ្ឌនៃការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាប្រឈមសម្រាប់រយៈពេលច្រើនឆ្នាំខាងមុខ។ កិច្ចខិតខំប្រឹងប្រែងក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ គឺមិនអាចកាត់ផ្តាច់ចេញពីការអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្របានឡើយដែលប្រការនេះមានសារៈសំខាន់បំផុត ក្នុងអន្តរកាលឆ្ពោះទៅរកសេដ្ឋកិច្ចបៃតង និងការអភិវឌ្ឍដោយបញ្ចេញកាបូនតិច ហើយធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ។

ក្នុងបរិបទនេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជាខ្ញុំមានកិត្តិយស និងសោមនស្សរីករាយសូមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣។ ផែនការយុទ្ធសាស្ត្រនេះ គឺជាឯកសារគោលនយោបាយពេញលេញដែលពុំធ្លាប់មានពីមុនមកសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដែលប្រជាជាតិយើងកំពុងជួបប្រទះ។ ឯកសារនេះឆ្លុះបញ្ចាំងឱ្យឃើញពីឆន្ទៈនយោបាយ ការប្តេជ្ញាចិត្តដ៏រឹងមាំ និងការត្រៀមលក្ខណៈរបស់យើងក្នុងការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើការអភិវឌ្ឍ និងការចូលរួមចំណែកជាមួយសហគមន៍អន្តរជាតិ ក្នុងកិច្ចខិតខំប្រឹងប្រែងជាសកល ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ។

ការដាក់បញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការរៀបចំផែនការ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការរៀបចំផែនការយុទ្ធសាស្ត្រជាតិ ផែនការសកម្មភាពនិងក្របខ័ណ្ឌហិរញ្ញប្បទានសម្រាប់ការប្រែប្រួលអាកាសធាតុ គឺជាសកម្មភាពអាទិភាពដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣។ ដូច្នេះ ការដាក់ចេញផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា គឺជាជំហានដ៏សំខាន់ឆ្ពោះទៅរកការបញ្ជ្រាបបញ្ហាប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ និងផែនការអភិវឌ្ឍន៍តាមវិស័យនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ។ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនេះ នឹងត្រូវប្រើប្រាស់ជាគោលការណ៍ណែនាំដល់ស្ថាប័នជាតិ និងជាជំនួយស្មារតីសម្រាប់អង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាដៃគូអភិវឌ្ឍន៍នានា ដើម្បីកំណត់នូវវិធានការសមស្រប និងសកម្មភាពជាក់ស្តែងពាក់ព័ន្ធនឹងការងារបន្សាំ និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលជាសសរស្តម្ភគាំទ្រដល់ការសម្រេចបាននូវការអនុវត្តយុទ្ធសាស្ត្រចតុកោណ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។

ខ្ញុំសូមបញ្ជាក់ថា ឯកសារយុទ្ធសាស្ត្រនេះ ផ្តោតលើទិសដៅជាយុទ្ធសាស្ត្រសំខាន់ៗ ដើម្បីលើកស្ទួយការអភិវឌ្ឍប្រកបដោយចីរភាពដែលយើងត្រូវប្រកាន់យកក្នុងរយៈពេល ១០ឆ្នាំខាងមុខ ហើយខ្ញុំយល់ថាឯកសារនេះ គឺជាឧបករណ៍គោលនយោបាយជាថាមវន្ត ដែលទាមទារឱ្យមានការពិនិត្យ តាមដាន វាយតម្លៃ និងកែលម្អជាប្រចាំ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៅពេលអនាគត។ ខ្ញុំមានជំនឿយ៉ាងមុតមាំថាតាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រនេះ យើងនឹងទទួលបាននូវដំណោះស្រាយជាក់លាក់ និងបទពិសោធល្អៗ សម្រាប់រួមចំណែកដល់ការកសាងសមត្ថភាពជាតិឱ្យកាន់តែមានប្រសិទ្ធភាព។ នេះគឺជាគោលបំណងរបស់យើង ដើម្បីជំរុញសង្គមកម្ពុជាក្នុងការបោះជំហានឆ្ពោះទៅសេដ្ឋកិច្ចបៃតង ដែលបញ្ចេញកាបូនតិច និងធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ។

ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់លំដាប់ថ្នាក់នៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុតំណាងក្រសួងស្ថាប័នដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដែលបានរួមចំណែកដល់ការរៀបចំឯកសារដ៏មានសារៈសំខាន់នេះឡើង។

ខ្ញុំយល់ថា សមត្ថភាពរបស់យើងក្នុងការដោះស្រាយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ទៅលើដំណើរការអភិវឌ្ឍន៍ នឹងត្រូវបានកែលម្អជាបន្តបន្ទាប់ អាស្រ័យលើប្រសិទ្ធភាពនៃការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជន និងប្រព័ន្ធធម្មជាតិដែលជាមូលដ្ឋានទ្រទ្រង់ជីវភាពរស់នៅ

របស់ប្រជាជនវឌ្ឍនភាព និងវិបុលភាពសេដ្ឋកិច្ចជាតិ។ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងលេខាធិការដ្ឋានរបស់ខ្លួន ត្រូវដើរតួនាទីសំខាន់ ក្នុងការសម្របសម្រួលវិធានការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុពង្រឹងភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធ និងតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។

ជាថ្មីម្តងទៀត ខ្ញុំសូមឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធ វិស័យឯកជនអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍ បន្តពង្រឹងកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ក្នុងការអនុវត្តវិធានការផ្សេងៗឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ជាពិសេសផែនការយុទ្ធសាស្ត្រនេះ សំដៅរួមចំណែកអភិវឌ្ឍកម្ពុជាឆ្ពោះទៅរកសង្គមមួយ ដែលបៃតង បញ្ចេញកាបូនតិច ធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ ប្រកបដោយសមធម៌ និងចីរភាព៕

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ តុលា ឆ្នាំ២០១៣

**ហ៊ុន សែន**

# អារម្ភកថា

ក្នុងនាមគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងក្រសួងបរិស្ថាន ខ្ញុំសូមសម្តែងការគោរពដ៏ខ្ពង់ខ្ពស់ និងកតវេទិតាដ៏ស្មោះស្ម័គ្រចំពោះ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានគាំទ្រយ៉ាងពេញទំហឹង និងយកចិត្តទុកដាក់ខ្ពស់លើការងារប្រែប្រួលអាកាសធាតុ ដែលកម្ពុជាកំពុងប្រឈមនៅក្នុងដំណើរការអភិវឌ្ឍន៍ប្រទេសជាតិ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣បានកំណត់សកម្មភាពអាទិភាព សម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដែលជះឥទ្ធិពលអវិជ្ជមានលើកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍ជាតិ។ ឈរលើមូលដ្ឋាននេះ ការប្រែប្រួលអាកាសធាតុត្រូវបានចាត់ទុកជាបញ្ហាអន្តរវិស័យ ក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។ ក្នុងន័យនេះ ខ្ញុំមានមោទនភាពចំពោះផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ដែលត្រូវបានរៀបរៀងឡើងក្រោមការដឹកនាំសម្របសម្រួលរបស់គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ។ ផែនការយុទ្ធសាស្ត្រនេះ គឺជាឯកសារយុទ្ធសាស្ត្រពេញលេញលើកដំបូងបង្អស់ ដែលសម្រេចបានក្រោមការដឹកនាំដ៏ឈ្លៀសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរដល់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី មកពីក្រសួងស្ថាប័នជំនាញ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា ដែលបានផ្តល់កិច្ចសហការយ៉ាងល្អក្នុងការរៀបចំឯកសារផែនការនេះ ឱ្យសម្រេចជារូបរាងឡើង។

លទ្ធផលនៃការសិក្សាថ្មីៗនៅក្នុងរបាយការណ៍ជាតិលើកទី២ ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ បានសន្និដ្ឋានថា សីតុណ្ហភាព និងរបបទឹកភ្លៀងនៅកម្ពុជាបានចាប់ផ្តើមប្រែប្រួល ចាប់ពីពាក់កណ្តាលទី២ នៃសតវត្សរ៍ទី២០។ ការប៉ាន់ប្រមាណសម្រាប់រយៈពេល៨០ឆ្នាំខាងមុខ បានបង្ហាញថា សីតុណ្ហភាពនឹងបន្តកើនឡើង ជាមួយនឹងការថយចុះនៃរបបទឹកភ្លៀងនៅរដូវប្រាំង និងការពន្យារពេលនៃការចាប់ផ្តើមធ្លាក់ភ្លៀងនៅរដូវវស្សា ហើយជាមួយគ្នានោះ កម្ពស់ទឹកភ្លៀងនៅរដូវវស្សាអាចកើនឡើងច្រើនជាងមុន។ ការប្រែប្រួលទាំងនេះអាចកើតឡើងក្នុងកម្រិតខុសៗគ្នា អាស្រ័យលើសេណារីយ៉ូនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់លើពិភពលោក។

ការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាប្រឈមដ៏ពិតប្រាកដមួយសម្រាប់ប្រទេសកម្ពុជា ដូចដែលយើងទាំងអស់គ្នាបានសង្កេតឃើញជាក់ស្តែង តាមរយៈព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី ដែលកើតមានជាញឹកញាប់ និងធ្ងន់ធ្ងរជាងមុន ដូចជា គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងខ្យល់ព្យុះ។ល។ ដែលបង្កឱ្យមានការខូចខាតជារូបវន្ត ខាតបង់ថវិកា ប៉ះពាល់លើសេដ្ឋកិច្ច-សង្គម និងជីវភាពប្រជាជន។ ដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងលក្ខខណ្ឌប្រែប្រួលអាកាសធាតុ កម្ពុជាបាននិងកំពុងដោះស្រាយទប់ទល់នឹងការប្រែប្រួលអាកាសធាតុ តាមរយៈការរៀបចំ

និងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការថ្មីៗ។ ឯកសារយុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើង ដោយអនុលោមតាមគោលការណ៍ណែនាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ហើយមានសង្គតិភាពជាមួយវដ្តនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ក្រសួង និងស្ថាប័នជំនាញមួយចំនួនបានផ្តល់ធាតុចូលសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រនេះ និងបានរៀបចំយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ ដែលជាកម្មវិធីគោលនយោបាយសម្រាប់សមាហរណកម្មការប្រែប្រួលអាកាសធាតុ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ឯកសារយុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំឡើងផ្អែកលើដំណើរការពិគ្រោះយោបល់ទូលំទូលាយ ដើម្បីធានាឱ្យមានការឯកភាពគ្នា ភាពពេញលេញ និងភាពជាម្ចាស់របស់អ្នកពាក់ព័ន្ធ។ ដោយផ្អែកលើឯកសារគោលនយោបាយនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដែលមានស្រាប់ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រចតុកោណ គោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍបៃតង និងផែនការអភិវឌ្ឍន៍តាមវិស័យ យើងបានរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រប្រទាក់ក្រឡាគ្នា ដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ តាមរយៈវិធានការបន្សាំ ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការអភិវឌ្ឍដោយបញ្ចេញកាបូនតិច។ វិធានការដែលបានកំណត់ភាគច្រើន គឺសង្កត់ធ្ងន់លើការកសាងសមត្ថភាពស្ថាប័ន និងចំណេះដឹងវិទ្យាសាស្ត្រសម្រាប់ប៉ាន់ប្រមាណផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ការបន្សាំ និងការកាត់បន្ថយគ្រោះមហន្តរាយជាពិសេសសម្រាប់វិស័យងាយរងគ្រោះដូចជា កសិកម្ម ធនធានទឹក ព្រៃឈើ ជលផល និងទេសចរណ៍ ជាដើម។ យុទ្ធសាស្ត្រនេះក៏បានគិតគូរផងដែរអំពីការកសាងសមត្ថភាពធន់ទ្រាំ និងជំនាញផលិតកម្ម នៅថ្នាក់សហគមន៍ ដើម្បីជំនះលើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

ប្រទេសកម្ពុជាសម្បូរដោយធនធានទឹក និងថាមពលកកើតឡើងវិញ ដែលភាគច្រើននៃធនធានទាំងនេះមិនទាន់បានយកមកប្រើប្រាស់នៅឡើយ។ ការលើកកម្ពស់លទ្ធភាពទទួលបានស្បៀង ទឹក និងថាមពល ជាមួយនឹងការលើកស្ទួយការអភិវឌ្ឍដែលបញ្ចេញកាបូនតិច តាមរយៈការផ្ទេរបច្ចេកវិទ្យា កំណែទម្រង់ច្បាប់ គួបផ្សំនឹងវិធានការលើកទឹកចិត្តហិរញ្ញវត្ថុ ត្រូវបានចាត់ទុកថាជាដំណោះស្រាយសមស្រប សម្រាប់ការអភិវឌ្ឍដោយចីរភាពក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។ របាយការណ៍ជាតិលើកទី២ បានផ្តល់ការវិភាគលម្អិតអំពីជម្រើសបច្ចេកវិទ្យាសម្រាប់ការអភិវឌ្ឍថាមពលកកើតឡើងវិញ ការសន្សំសំចៃថាមពល និងសក្តានុពលនៃការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ដែលអាចជាមូលដ្ឋានក្នុងការកំណត់សកម្មភាពជាក់ស្តែង និងការធ្វើវិនិយោគប្រកបដោយជោគជ័យ។

ការកៀរគរថវិកាសម្រាប់អនុវត្តកម្មវិធី ឬគម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ នៅទីកន្លែងជាក់លាក់ដែលមានហានិភ័យអាកាសធាតុខ្ពស់ មានសារៈសំខាន់ដើម្បីសម្រេចបាននូវគោលដៅ និងគោលបំណងនៃផែនការយុទ្ធសាស្ត្រនេះ។ ការបញ្ចូលការងារប្រែប្រួលអាកាសធាតុ ដែលបានលើកឡើងនៅក្នុង**ផែនការយុទ្ធសាស្ត្រឆ្លើយតប**

**នឹងការប្រែប្រួលអាកាសធាតុកម្ពុជា** ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការតាមវិស័យ នឹងផ្តល់អត្ថប្រយោជន៍ច្រើនយ៉ាងដូចជា ការកែលម្អសមត្ថភាពនិងចំណេះដឹងក្នុងការធ្វើផែនការប្រែប្រួលអាកាសធាតុ ការលើកកម្ពស់ការចូលរួមរបស់អ្នកពាក់ព័ន្ធ ការសម្របសម្រួលលំហូរថវិកា និងការឃ្លាំមើល និងវាយតម្លៃការអនុវត្តវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ជារួម ផែនការយុទ្ធសាស្ត្រនេះ នឹងបង្កើតនូវបរិយាកាសអំណោយផលសម្រាប់ឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុ ប្រកបដោយប្រសិទ្ធភាពនិងជោគជ័យ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះតំណាងក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអ្នកជំនាញការទាំងអស់ ដែលបានផ្តល់នូវធាតុចូលល្អៗ ជួយគាំទ្រនិងចូលរួមយ៉ាងសកម្ម ក្នុងដំណើរការរៀបចំ **ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា** ប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា៕

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣

រដ្ឋមន្ត្រី

សាយ សំអាល

# សេចក្តីថ្លែងអំណរគុណ

រាជរដ្ឋាភិបាលកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបណ្តាក្រសួងស្ថាប័នជាតិ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នសិក្សាស្រាវជ្រាវ វិស័យឯកជន និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមនៅក្នុងដំណើរការរៀបចំ**ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា**។

ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ត្រូវបានរៀបរៀងឡើងក្រោមការសម្របសម្រួលពីក្រសួងបរិស្ថាន ដោយមានការចូលរួមយ៉ាងសកម្មពីក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុអន្តរក្រសួង និងមតិណែនាំដ៏មានតម្លៃពីគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ។ ការចូលរួមយ៉ាងទូលំទូលាយរបស់អ្នកពាក់ព័ន្ធទាំងអស់ បានធ្វើឱ្យផែនការយុទ្ធសាស្ត្រនេះ មានសង្គតិភាព និងគាំទ្រដល់ផែនការតាមវិស័យនានាដែលមានស្រាប់នៅតាមបណ្តាក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល។ គំនិត និងយោបល់នានា ដែលទទួលបានពីអ្នកពាក់ព័ន្ធទាំងអស់មានសារៈសំខាន់ណាស់ សម្រាប់តម្រង់ទិសផែនការយុទ្ធសាស្ត្រនេះ។ អ្នកជំនាញការជាតិ និងអន្តរជាតិមួយចំនួន បានផ្តល់ការគាំទ្របច្ចេកទេសនៅក្នុងការរៀបរៀងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជានេះ។

ការរៀបរៀងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា បានធ្វើឡើងដោយមានការគាំទ្រហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍មួយចំនួន ដូចជា សហភាពអឺរ៉ុប ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ តាមរយៈកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា៕

x

# មាតិកា


**សារលិខិត សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ........ i

**អារម្ភកថា** ........ v

**សេចក្ដីថ្លែងអំណរគុណ** ........ ix

**មាតិកា** ........ xi

**ពាក្យបំព្រួញ និងអក្សរកាត់** ........ xv

**សេចក្ដីសង្ខេប** ........ xix

**១. សេចក្ដីផ្ដើម** ........ 1

**២. ចក្ខុវិស័យ** ........ 3

**៣. បេសកកម្ម** ........ 3

**៤. គោលបំណង** ........ 3

**៥. ក្របខ័ណ្ឌយុទ្ធសាស្ត្រ** ........ 3

*៥.១. គោលការណ៍ណែនាំ* ........ 3

*៥.២. ការវិភាគយុទ្ធសាស្ត្រ* ........ 4

ស្ថានភាពគោលនៃការអភិវឌ្ឍជាតិ ........ 5

ព្យាករណ៍អំពីការអភិវឌ្ឍជាតិ ........ 6

បញ្ហាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដែលលើកឡើងនៅក្នុង ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣ ........ 7

ព្យាករណ៍អាកាសធាតុ និងឥទ្ធិពលពាក់ព័ន្ធ ........ 8

សមត្ថភាពឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ........ 10

ស្ថាប័នសម្របសម្រួលការងារប្រែប្រួលអាកាសធាតុ ........ 12

យេនឌ័រ និងការប្រែប្រួលអាកាសធាតុ ........ 12

ការអប់រំ ការលើកកម្ពស់ការយល់ដឹង និងការប្រាស្រ័យទាក់ទង ........ 13

*៥.៣. ទិសដៅជាយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រ*......13
ទិសដៅជាយុទ្ធសាស្ត្រទី ១ ៖......13
ទិសដៅជាយុទ្ធសាស្ត្រទី ២ ៖......14
ទិសដៅជាយុទ្ធសាស្ត្រទី ៣ ៖......15
ទិសដៅជាយុទ្ធសាស្ត្រទី ៤ ៖......16
ទិសដៅជាយុទ្ធសាស្ត្រទី ៥ ៖......17
ទិសដៅជាយុទ្ធសាស្ត្រទី ៦ ៖......18
ទិសដៅជាយុទ្ធសាស្ត្រទី ៧ ៖......19
ទិសដៅជាយុទ្ធសាស្ត្រទី ៨ ៖......19
**៦. សកម្មភាព**......20
*៦.១. ដំណាក់កាលសម្រាប់អនុវត្ត ផ.យ.ប.អ.ក.*......20
ការចាត់ចែងរចនាសម្ព័ន្ធស្ថាប័ន......21
ការកសាងផែនការសកម្មភាព......22
ការបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ......22
ការបង្កើតក្របខ័ណ្ឌពិនិត្យ តាមដាន និងវាយតម្លៃ......22
ការបង្កើតក្របខ័ណ្ឌច្បាប់ស្ដីពីការប្រែប្រួលអាកាសធាតុ......23
*៦.២. ការបង្កើតកម្មវិធី និងការកសាងផែនការសកម្មភាព*......23
រយៈពេល......23
ការពង្រឹងបន្ថែមលើយុទ្ធសាស្ត្ររបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធនានា......23
បញ្ហាអន្តរវិស័យ......24
ការបង្កើតកម្មវិធីចម្រុះ......24
ភាពជាដៃគូ......24

**៧. ការផ្តល់ធនធានហិរញ្ញវត្ថុ** .......... 25

*៧.១. គោលការណ៍នានា* .......... 25

*៧.២. វិធីសាស្ត្រ* .......... 26

*៧.៣. ការគ្រប់គ្រង និងរចនាសម្ព័ន្ធស្ថាប័នសម្រាប់ការអនុវត្ត* .......... 28

**៨. ការពិនិត្យតាមដាន និងវាយតម្លៃ** .......... 28

*៨.១. គោលការណ៍នានា* .......... 29

*៨.២. វិធីសាស្ត្រ* .......... 30

*៨.៣. ការគ្រប់គ្រង និងរចនាសម្ព័ន្ធស្ថាប័នសម្រាប់ការអនុវត្ត* .......... 32

**៩. សេចក្តីសន្និដ្ឋាន** .......... 32

**ឧបសម្ព័ន្ធ** .......... 35

*ឧបសម្ព័ន្ធ ១ ៖* .......... 35

*ឧបសម្ព័ន្ធ ២ ៖* .......... 45

# ពាក្យបំព្រួញ និងអក្សរកាត់

| | | |
|---|---|---|
| AF | Adaptation Fund | មូលនិធិបន្សាំ |
| ASEAN | Association of Southeast Asian Nations | សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ |
| CBO | Community-Based Organization | អង្គការសហគមន៍ |
| CCCA | Cambodia Climate Change Alliance | សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា |
| CCCSP | Cambodia Climate Change Strategic Plan | ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (ផ.យ.ប.អ.ក.) |
| CCD | Climate Change Department | នាយកដ្ឋានប្រែប្រួលអាកាសធាតុ |
| CCTT | Climate Change Technical Team | ក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ |
| CDC | Council for the Development of Cambodia | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.ប.ក.ប.អ.) |
| CDM | Clean Development Mechanism | យន្តការអភិវឌ្ឍន៍ស្អាត |
| CPEIR | Climate Public Expenditure and Institutional Review | ការពិនិត្យការចំណាយសាធារណៈ និងស្ថាប័ន លើការងារអាកាសធាតុ |
| CRDB | Cambodia Rehabilitation and Development Board | គណៈកម្មាធិការស្តារ និងអភិវឌ្ឍន៍កម្ពុជា |
| CSO | Civil Society Organization | អង្គការសង្គមស៊ីវិល |
| DANIDA | Danish International Development Agency | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក |
| EM-DAT | The International Disaster Database | កម្រងទិន្នន័យអន្តរជាតិអំពីគ្រោះមហន្តរាយ |
| EU | European Union | សហភាពអឺរ៉ុប |
| GCF | Green Climate Fund | មូលនិធិអាកាសធាតុបៃតង |
| GDP | Gross Domestic Product | ផលិតផលក្នុងស្រុកសរុប |
| GHG | Greenhouse Gas | ឧស្ម័នផ្ទះកញ្ចក់ |
| INC | Initial National Communication | របាយការណ៍ជាតិលើកទី១ |
| IPCC | Intergovernmental Panel on Climate Change | ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ |
| LDC | Least Developed Country | ប្រទេសអភិវឌ្ឍតិចតួច |
| M&E | Monitoring and Evaluation | ការពិនិត្យតាមដាន និងវាយតម្លៃ |
| MAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ក.ក.រ.ន.) |

| | | |
|---|---|---|
| Mekong ARCC | Mekong Adaptation and Resilience to Climate Change | គម្រោង ការបន្សាំនិងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុនៅតំបន់ទន្លេមេគង្គ |
| MIME | Ministry of Industry, Mines and Energy | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (ក.ឧ.រ.ថ.) |
| MOE | Ministry of Environment | ក្រសួងបរិស្ថាន (ក.ប.ស.) |
| MOEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា (ក.អ.យ.ក.) |
| MOH | Ministry of Health | ក្រសួងសុខាភិបាល (ក.ស.ភ.) |
| MOWA | Ministry of Women's Affairs | ក្រសួងកិច្ចការនារី (ក.ក.ន.) |
| MOWRAM | Ministry of Water Resources and Meteorology | ក្រសួងធនធានទឹក និងឧតុនិយម (ក.ធ.ទ.ឧ.) |
| MPWT | Ministry of Public Works and Transport | ក្រសួងសាធារណការ និងដឹកជញ្ជូន (ក.ស.ដ.) |
| MRD | Ministry of Rural Development | ក្រសួងអភិវឌ្ឍន៍ជនបទ (ក.អ.ជ.) |
| NAPA | National Adaptation Programme of Action | កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ |
| NCCC | National Climate Change Committee | គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (គ.ជ.គ.ប.អ.) |
| NCDD | National Committee for Sub-National Democratic Development | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) |
| NCDM | National Committee for Disaster Management | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម.) |
| NGO | Non-Governmental Organization | អង្គការមិនមែនរដ្ឋាភិបាល |
| NSDP | National Strategic Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) |
| NSPS | National Social Protection Strategy | យុទ្ធសាស្ត្រជាតិគាំពារសង្គម |
| PBA | Programme-based Approach | អភិក្រមផ្អែកលើកម្មវិធី |
| REDD+ | Reducing Emissions from Deforestation and Forest Degradation | ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់និងរេចរឹលព្រៃឈើ |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| RS | Rectangular Strategy | យុទ្ធសាស្ត្រចតុកោណ |
| Sectoral CCSP | Sectoral Climate Change Strategic Plan | ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ (ផ.យ.ប.អ. តាមវិស័យ) |
| SNC | Second National Communication (Draft) | របាយការណ៍ជាតិលើកទី២ (សេចក្តីព្រាង) |
| SRES A1B | Special Report on Emissions Scenarios A1B | សេណារីយ៉ូអត្រាបញ្ចេញឧស្ម័នកម្រិតមធ្យម |
| SRES A2 | Special Report on Emissions Scenarios A2 | សេណារីយ៉ូអត្រាបញ្ចេញឧស្ម័នកម្រិតខ្ពស់ |

| | | |
|---|---|---|
| SRES B1 | Special Report on Emissions Scenarios B1 | សេណារីយ៉ូអត្រាបញ្ចេញឧស្ម័នកម្រិតទាប |
| SWEDEN (Sida) | Swedish International Development Cooperation Agency | ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ |
| SWOT | Strengths, Weaknesses, Opportunities and Threats | ភាពខ្លាំង ភាពទន់ខ្សោយ កាលានុវត្តភាព និងការគម្រាមកំហែង |
| UNDP | United Nations Development Programme | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNFCCC | United Nations Framework Convention on Climate Change | អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |

# សេចក្តីសង្ខេប

ភាពស្មុគស្មាញ និងភាពមិនប្រាកដប្រជាយ៉ាងច្រើនអំពីហានិភ័យ និងការគំរាមកំហែងនៃការប្រែប្រួលអាកាសធាតុមកលើកំណើនសេដ្ឋកិច្ចជាតិ បរចិញ្ចឹមជីវិត និងមុខងាររបស់ប្រព័ន្ធអេកូឡូស៊ីនៅកម្ពុជា បានតម្រូវឱ្យមានវិធីសាស្ត្រចម្រុះចាំបាច់នៅក្នុងការកសាងគោលនយោបាយ និងយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុ ដែលបន្ស៊ីគ្នាជាមួយរបៀបវារៈក្នុងគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចីរភាព កាត់បន្ថយភាពក្រីក្រ និងធានានិរន្តរភាពបរិស្ថាន។ **ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា២០១៤-២០២៣ (ផ.យ.ប.អ.ក.)** ត្រូវបានរៀបរៀងឡើង ដើម្បីបំពេញចំណុចខ្វះខាត និងបំពេញបន្ថែមលើគោលនយោបាយដែលមានស្រាប់ សំដៅឆ្លើយតបទៅនឹងបញ្ហាប្រឈមថ្មីៗ ក្នុងកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍជាតិ នាពេលបច្ចុប្បន្ន។

ដោយគោរពតាមគោលការណ៍ណែនាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា២០១៤-២០២៣ ត្រូវបានរៀបចំឡើង តាមជំហានសមស្រប រួមមានការវិភាគការអភិវឌ្ឍជាតិ និងហានិភ័យពីការប្រែប្រួលអាកាសធាតុ ការកំណត់ចក្ខុវិស័យ បេសកកម្ម និងគោលបំណង ការបង្កើតក្របខ័ណ្ឌយុទ្ធសាស្ត្រ ដែលផ្សំឡើងពីទិសដៅជាយុទ្ធសាស្ត្រនិងយុទ្ធសាស្ត្រ ការកំណត់អត្តសញ្ញាណសកម្មភាពនានា ការចាត់ចែងស្ថាប័ននិងផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្ត ការវិភាគធនធានហិរញ្ញវត្ថុ និងការបង្កើតក្របខ័ណ្ឌពិនិត្យតាមដាននិងវាយតម្លៃ។

ផលិតផលក្នុងស្រុកសរុបរបស់កម្ពុជាបានកើនឡើងក្នុងអត្រា៧,១% នៅឆ្នាំ២០១១ ហើយត្រូវបានព្យាករណ៍ថា នឹងស្ថិតនៅក្នុងកម្រិត៧-៨% នៅឆ្នាំ២០១៣។ សេដ្ឋកិច្ចកម្ពុជាពឹងផ្អែកលើមូលដ្ឋានតូចចង្អៀត ហើយនាំមុខដោយវិស័យចម្បងចំនួន៤ គឺឧស្សាហកម្មកាត់ដេរ ទេសចរណ៍ សំណង់ និងកសិកម្ម។ កសិកម្មនៅតែបន្តជាវិស័យដែលផ្តល់ការងារច្រើនជាងគេ សម្រាប់ពលរដ្ឋនៅជនបទ ពោលគឺប្រមាណ៥៧,៦% នៃចំនួនមនុស្សពេញកម្លាំង៨,៨លាននាក់ ហើយវិស័យនេះបានរួមចំណែកប្រមាណ៣២,១% (ឆ្នាំ២០១១) នៃផលិតផលសរុបក្នុងស្រុក។ រាជរដ្ឋាភិបាលកម្ពុជាមានគោលដៅនាំអង្ករចេញចំនួន១លានតោន ក្នុងមួយឆ្នាំរហូតដល់ឆ្នាំ២០១៥ ដែលប្រការនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ការរីកចំរើនក្នុងវិស័យឧស្សាហកម្មកិនស្រូវ។ ផ្នែកកសិឧស្សាហកម្ម ដូចជាដំណាំកៅស៊ូ និងដំឡូងមី មានការលូតលាស់យ៉ាងឆាប់រហ័ស ចំណែកផលិតកម្មកៅស៊ូបានកើនក្នុងអត្រា១០,១% នៅឆ្នាំ២០១១ (MEF, 2011)។ វិស័យទេសចរណ៍មានកំណើន២០% ក្នុងមួយឆ្នាំៗ ដោយបានចូលរួមចំណែកប្រមាណ៤,៣% នៃផលិតផលក្នុងស្រុកសរុប។ ផលិតកម្មអគ្គិសនីពឹងផ្អែកជាចម្បងលើឥន្ធនៈហ្វូស៊ីលដែលមាន៩៥,២% នៃបរិមាណអគ្គិសនីដែលផលិតបានសរុប ក្នុងនោះថាមពលវារីអគ្គិសនីមានត្រឹមតែ៣,៣%

ហើយថាមពលពីប្រភពដទៃទៀតមានតែ១,៥% ប៉ុណ្ណោះ។ ឧស្សាហកម្មនិស្សារណកម្មប្រេង ឧស្ម័ន និងរ៉ែ នឹងមានតួនាទីសំខាន់ ក្នុងការផ្តល់វិភាគទានដល់កំណើនផលិតផលក្នុងស្រុកសរុប នាពេលអនាគតឆាប់ៗខាងមុខ។

លទ្ធផលនៃការសិក្សាតាមម៉ូដែលក្រោមរបាយការណ៍ជាតិលើកទី១ និងរបាយការណ៍ជាតិលើកទី២ បានបង្ហាញថា សីតុណ្ហភាពបរិយាកាសនៅកម្ពុជាបានកើនឡើង០,៨°C ធៀបនឹងតួលេខឆ្នាំ១៩៦០។ សីតុណ្ហភាពមធ្យមប្រចាំខែត្រូវបានព្យាករណ៍ថា នឹងកើនឡើងរវាងពី០,០១៣°C ដល់០,០៣៦°C ក្នុងមួយឆ្នាំរហូតដល់ឆ្នាំ២០៩៩ ដោយការប្រែប្រួលនេះអាស្រ័យតាមទីកន្លែង។ អត្រាកំណើនសីតុណ្ហភាពនៅតំបន់ដែលមានរយៈកម្ពស់ទាបមានកម្រិតខ្ពស់ជាងនៅតំបន់ដែលមានរយៈកម្ពស់ខ្ពស់។ ក្នុងករណីមានកំណើនឧស្ម័ននៅក្រោមសេណារីយ៉ូអត្រាបញ្ចេញឧស្ម័នកម្រិតទាប (SRESB1) កម្ពស់ទឹកភ្លៀងនៅរដូវវស្សាទំនងជាបន្តកើនឡើងទៅអនាគត ហើយបន្ទាប់មកអាចថយចុះមកវិញនៅក្រោយទសវត្សរ៍ឆ្នាំទី២០៥០។ ប៉ុន្តែនៅក្រោមសេណារីយ៉ូបញ្ចេញឧស្ម័នកម្រិតខ្ពស់ (SRESA2) ការប្រែប្រួលមានទិសផ្ទុយពីនេះ។ តាមរបាយការណ៍វាយតម្លៃលើកទី៤ របស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ បានបង្ហាញថា រហូតដល់ឆ្នាំ២១០០ កំណើនកម្ពស់ទឹកសមុទ្រសកលអាចនឹងកើនឡើងរវាងពី១៨ ស.ម. នៅក្រោមសេណារីយ៉ូ SRESB1 ទៅ៥០ ស.ម. នៅក្រោមសេណារីយ៉ូ SRESA2។

កំណើនសីតុណ្ហភាពទំនងជានឹងមានឥទ្ធិពលមកលើផលិតភាពកសិកម្ម។ យោងតាមវិទ្យាស្ថានស្រាវជ្រាវពូជស្រូវអន្តរជាតិ ទិន្នផលស្រូវនឹងថយចុះ១០% ក្នុងករណីមានកំណើន១℃ នៃសីតុណ្ហភាពអប្បរមា (នៅពេលយប់) ក្នុងរដូវប្រាំង។ ឆ្នេរសមុទ្រកម្ពុជាប្រវែង៤៣៥ គ.ម. នឹងរងឥទ្ធិពលពីកំណើនកម្ពស់ទឹកសមុទ្រ ចំណែកតំបន់កសិកម្មនៅតាមទីទំនាបនឹងរងឥទ្ធិពលពីការជ្រាបចូលទឹកប្រៃ ដែលបង្កឱ្យខូចខាតដំណាំ។

ចក្ខុវិស័យ បេសកកម្ម និងគោលបំណងនៃផែនការនេះ ត្រូវបានរៀបចំឡើង ដោយផ្អែកលើលទ្ធផលនៃការវិភាគសមត្ថភាពស្ថាប័ន ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដែលបានសង្កេតឃើញ និងការព្យាករណ៍អំពីការប្រែប្រួលអាកាសធាតុ។

**ចក្ខុវិស័យ ៖** កម្ពុជាអភិវឌ្ឍឆ្ពោះទៅរកសង្គមមួយដែលបៃតង បញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ សមធម៌ ចីរភាព និងពឹងផ្អែកលើចំណេះដឹងជាគោល។

**បេសកកម្ម ៖** បង្កើតក្របខ័ណ្ឌជាតិមួយសម្រាប់ជំរុញការចូលរួមពីស្ថាប័នរដ្ឋ វិស័យឯកជន អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា សម្រាប់ឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព។



**គោលបំណង ៖**

- កាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជន ជាពិសេសក្រុមអ្នកដែលងាយរងគ្រោះបំផុត និងប្រព័ន្ធសំខាន់ៗ (ធម្មជាតិ និងសង្គម) បណ្តាលមកពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។
- បង្វែរទៅរកមាគ៌ាអភិវឌ្ឍបៃតង តាមរយៈការលើកកម្ពស់ការអភិវឌ្ឍបញ្ចេញកាបូនតិច និងបច្ចេកវិទ្យាពាក់ព័ន្ធ។
- លើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់សាធារណជនក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

ដើម្បីសម្រេចចក្ខុវិស័យ បេសកកម្ម និងគោលបំណងទាំងនេះ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ទិសដៅជាយុទ្ធសាស្ត្រចម្បងចំនួន៨ ដូចខាងក្រោម ៖

១. លើកកម្ពស់ភាពធន់នឹងអាកាសធាតុ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង ទឹក និងថាមពល។

២. កាត់បន្ថយភាពងាយរងគ្រោះតាមវិស័យ តំបន់ យេនឌ័រ និងសុខភាព នៅចំពោះមុខផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

៣. លើកកម្ពស់ភាពធន់នឹងអាកាសធាតុ នៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (បឹងទន្លេសាប ទន្លេមេគង្គ តំបន់ឆ្នេរ តំបន់ខ្ពង់រាប ។ល។) ជីវៈចម្រុះ តំបន់ការពារធម្មជាតិ និងតំបន់បេតិកភណ្ឌវប្បធម៌។

៤. លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យាដែលបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព។

៥. កែលម្អសមត្ថភាព ចំណេះដឹង និងការយល់ដឹងសម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

៦. លើកកម្ពស់ការចូលរួម និងកិច្ចគាំពារសង្គមបែបបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដើម្បីកាត់បន្ថយការបាត់បង់ និងការខូចខាត។

៧. ពង្រឹងស្ថាប័ន និងក្របខ័ណ្ឌការងារសម្របសម្រួល សម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ។

៨. ពង្រឹងកិច្ចសហការ និងចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចខិតខំប្រឹងប្រែងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ នៅថ្នាក់តំបន់ និងពិភពលោក។

**ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា២០១៤-២០២៣** មានសកម្មភាពមួយចំនួន ដែលត្រូវអនុវត្តជា៣ ដំណាក់កាល ៖

**នៅក្នុងរយៈពេលខ្លី (២០១៣-២០១៤) ៖** ដំណាក់កាលនេះផ្តោតលើការពង្រឹងស្ថាប័ន ការកៀរគរហិរញ្ញវត្ថុសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ ការបង្កើតក្របខ័ណ្ឌជាតិសម្រាប់ត្រួតពិនិត្យនិងវាយតម្លៃ និងការរៀបចំផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់រយៈពេលមធ្យម (២០១៤-២០១៨) ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ។

**នៅក្នុងរយៈពេលមធ្យម (២០១៤-២០១៨) ៖** ដំណាក់កាលនេះនឹងបន្តគាំទ្រដល់ការអនុវត្តសកម្មភាពដូចដែលបានគ្រោងក្នុងដំណាក់កាលទី១ ជាមួយនឹងការពង្រីកសកម្មភាពដទៃទៀត ដូចជាការរៀបចំយន្តការទទួលបានមូលនិធិបន្សាំនិងមូលនិធិអាកាសធាតុបៃតង ការស្រាវជ្រាវនិងការគ្រប់គ្រងចំណេះដឹង ការអភិវឌ្ឍសមត្ថភាព ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅតាមវិស័យនានា ការប្រតិបត្តិប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងការចាប់ផ្តើមគម្រោងឬកម្មវិធីនានាដែលមានអាទិភាពខ្ពស់នៅក្នុងវិស័យសំខាន់ៗដូចបានកំណត់នៅក្នុងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ជាដំបូង អាទិភាពត្រូវផ្តោតលើសកម្មភាពបន្សាំ ហើយបន្តិចម្តងៗនឹងគាំទ្រការពង្រីកសកម្មភាពកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់។ រាជរដ្ឋាភិបាលអាចនឹងពិនិត្យនិងកែសម្រួលឡើងវិញនូវ **ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា២០១៤-២០២៣** ដោយផ្អែកលើមេរៀនទទួលបាននៅក្នុងដំណាក់កាលទី១ និងទី២។

**នៅក្នុងរយៈពេលវែង (២០១៩-២០២៣) ៖** ដំណាក់កាលនេះបន្តផ្តោតលើការស្រាវជ្រាវ និងការរៀនសូត្រ ប៉ុន្តែគោលដៅចម្បងគឺការពង្រីកសកម្មភាពជោគជ័យទាំងឡាយ ដែលសម្រេចបានកន្លងមក និងបន្តបញ្ជ្រាបការប្រែប្រួលអាកាសធាតុ ទៅក្នុងកម្មវិធីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ដំណាក់កាលនេះនឹងមានការប្រើប្រាស់ការគាំទ្រថវិកាកាន់តែច្រើនសម្រាប់កម្មវិធីជាតិ ដោយរួមទាំងការផ្តល់មូលនិធិគាំទ្រវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមរយៈរដ្ឋបាលនៅថ្នាក់ក្រោមជាតិផងដែរ។

## ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាមានការប្តេជ្ញាចិត្តខ្ពស់ ក្នុងការឈានទៅអភិវឌ្ឍប្រទេសប្រកបដោយចីរភាព ដោយធានាបាននូវគុណភាព និងស្តង់ដារនៃជីវភាពរស់នៅប្រសើរជាងមុនរបស់ប្រជាពលរដ្ឋ។

កម្មវិធីអាទិភាពចម្បងមួយក្នុងការអភិវឌ្ឍជាតិ គឺការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ ដូច្នេះ កិច្ចប្រឹងប្រែងនានាក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ មិនអាចកាត់ផ្តាច់ចេញពីការអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋបានឡើយ។ ការដោះស្រាយកិច្ចការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដោយរួមបញ្ចូលការប្រែប្រួលអាកាសធាតុ នឹងជួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការកាត់បន្ថយភាពងាយរងគ្រោះ នៅចំពោះមុខហានិភ័យនៃការប្រែប្រួលអាកាសធាតុដែលអាចកើតមាន ការកែលម្អគុណភាពខ្យល់ និងការចូលរួមជាមួយសហគមន៍អន្តរជាតិដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលជាមូលហេតុនៃការប្រែប្រួលអាកាសធាតុ។ ការប្រែប្រួលអាកាសធាតុមានឥទ្ធិពលយ៉ាងខ្លាំងដល់ជីវភាពរស់នៅរបស់ប្រជាជន ជាពិសេសអ្នករស់នៅទីជនបទដោយអ្នកទាំងនោះពឹងផ្អែកយ៉ាងខ្លាំងលើធនធានធម្មជាតិ ដែលតាមរយៈការព្យាករណ៍បានបង្ហាញថា ធនធានទាំងនោះនឹងត្រូវរងការប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ បច្ចុប្បន្ន បណ្តាគ្រួសារដែលប្រកបរបរកសិកម្មមានអត្រាភាពក្រីក្រខ្ពស់ជាងគេ ហើយពួកគេក៏ជាក្រុមដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (**ផ.យ.អ.ជ.**) បច្ចុប្បន្នកម្ម២០០៩-២០១៣ បានគូសបញ្ជាក់ថា "*ដើម្បីដោះស្រាយប្រកបដោយប្រសិទ្ធភាពនូវបញ្ហាពាក់ព័ន្ធជាមួយការប្រែប្រួលអាកាសធាតុ ចាំបាច់ត្រូវពង្រឹងសមត្ថភាពស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីកំណត់រក និងបង្កើតយុទ្ធសាស្ត្រដើម្បីដោះស្រាយផលប៉ះពាល់ ដែលរំពឹងថា នឹងកើតចេញពីការប្រែប្រួលអាកាសធាតុ និងពង្រឹងសមត្ថភាពគ្រប់គ្រងគ្រោះមហន្តរាយ*"។ កិច្ចការនេះទាមទារឱ្យផ្តោតលើអាទិភាពនានា ដែលមានចែងនៅក្នុង **ផ.យ.អ.ជ.** បច្ចុប្បន្នកម្ម ២០០៩-២០១៣ ដូចខាងក្រោម ៖

- ពង្រឹងសមត្ថភាពរបស់លេខាធិការដ្ឋានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ។
- ជំរុញ និងសម្របសម្រួលការបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យពាក់ព័ន្ធ។
- បន្តរៀបចំរបាយការណ៍ជាតិលើកទី២ ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។
- រៀបចំយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពជាតិ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។
- ជំរុញការបង្កើតមូលនិធិប្រែប្រួលអាកាសធាតុជាតិ។
- ជំរុញការអនុវត្ត និងធ្វើបច្ចុប្បន្នកម្ម កម្មវិធីសកម្មភាពជាតិស្តីពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

- បន្តកំណត់រក និងជំរុញការអនុវត្តយន្តការអភិវឌ្ឍន៍ស្អាត និងគម្រោងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់នានា។
- អប់រំ និងផ្សព្វផ្សាយដល់សាធារណជនស្តីពីការប្រែប្រួលអាកាសធាតុ។
- កៀរគរធនធាន និងគាំទ្រដល់ការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។
- ធ្វើវិមជ្ឈការការងាររៀបចំសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ និងរៀបចំប្រព័ន្ធគ្រប់គ្រងកម្រងទិន្នន័យមូលដ្ឋាន។

ការសម្រេចបានចំណុចដៅអភិវឌ្ឍន៍ជាតិ ដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ទាមទារឱ្យមានវិធានការនានា ដើម្បីឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ការរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ផ្តល់ជាចំណុចចាប់ផ្តើម ដើម្បីបង្កើតវិធីសាស្ត្រសមស្របប្រកបដោយសង្គតិភាពនៅក្នុងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ ទៅក្នុងដំណើរការអភិវឌ្ឍន៍ជាតិ។

ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (**ផ.យ.ប.អ.ក.**) បានរៀបរៀងឡើងដោយអនុលោមតាមគោលការណ៍ណែនាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។ នៅក្នុង **ផ.យ.ប.អ.ក.** មានគូសបញ្ជាក់អំពីចក្ខុវិស័យ បេសកកម្ម គោលបំណងនិងគោលដៅ ក៏ដូចជាការវិភាគក្របខ័ណ្ឌយុទ្ធសាស្ត្រ ក្នុងការកំណត់ទិសដៅជាយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រនានាផងដែរ។ ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ នឹងត្រូវរៀបចំឡើងជាឯកសារដោយឡែក ដែលចែងលម្អិតអំពីការកំណត់អត្តសញ្ញាណ និងអាទិភាពសកម្មភាពស្របនឹងទិសដៅជាយុទ្ធសាស្ត្រ ដែលបានកំណត់ក្នុង **ផ.យ.ប.អ.ក.**។

ទន្ទឹមនឹងការរៀបចំ **ផ.យ.ប.អ.ក.** ក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួនបានរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (**ផ.យ.ប.អ.**) តាមវិស័យរៀងៗខ្លួន ដើម្បីធ្វើសមាហរណកម្មការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍តាមវិស័យរបស់ខ្លួន។ ឯកសារ **ផ.យ.ប.អ.ក.** ផ្តល់នូវទស្សនវិស័យ និងក្របខ័ណ្ឌជាតិសម្រាប់ដោះស្រាយការប្រែប្រួលអាកាសធាតុ ដោយឡែក **ផ.យ.ប.អ.** តាមវិស័យ របស់ក្រសួង ស្ថាប័នពាក់ព័ន្ធផ្តោតលើវិធានការជាក់ស្តែង សម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ។ ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងនោះកំពុងរៀបចំផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យរៀងៗខ្លួន អនុលោមតាម **ផ.យ.ប.អ.** តាមវិស័យ ដែលពាក់ព័ន្ធ។ ការសម្របសម្រួលបានល្អលើវិធានការឆ្លើយតបនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានសារៈសំខាន់ខ្លាំងណាស់ សម្រាប់ដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុឱ្យមានប្រសិទ្ធភាព។ ផ្សារភ្ជាប់នឹងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការនៅថ្នាក់ក្រោមជាតិ គោលការណ៍ណែនាំមួយកំពុង

រៀបចំឡើង នៅក្រោមការដឹកនាំរបស់ លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (**គ.ជ.អ.ប.**)។

## ២. ចក្ខុវិស័យ

កម្ពុជាអភិវឌ្ឍឆ្ពោះទៅរកសង្គមមួយដែលបៃតង បញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ សមធម៌ ចីរភាព និងពឹងផ្អែកលើចំណេះដឹងជាគោល។

## ៣. បេសកកម្ម

បង្កើតក្របខ័ណ្ឌជាតិមួយសម្រាប់ជំរុញការចូលរួមពី ស្ថាប័នរដ្ឋ វិស័យឯកជន អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា សម្រាប់ឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព។

## ៤. គោលបំណង

- កាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជន ជាពិសេសក្រុមអ្នកដែលងាយរងគ្រោះបំផុត និងប្រព័ន្ធសំខាន់ៗ (ធម្មជាតិ និងសង្គម) បណ្តាលមកពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។
- បង្វែរទៅរកមាគ៌ាអភិវឌ្ឍបៃតង តាមរយៈការលើកកម្ពស់ការអភិវឌ្ឍបញ្ចេញកាបូនតិច និងបច្ចេកវិទ្យាពាក់ព័ន្ធ។
- លើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់សាធារណជន ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

## ៥. ក្របខ័ណ្ឌយុទ្ធសាស្ត្រ

ប្រទេសកម្ពុជាងាយរងគ្រោះខ្លាំងនៅចំពោះមុខការប្រែប្រួលអាកាសធាតុ ហើយរាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់នូវតម្រូវការចាំបាច់ដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលនយោបាយនានា នៅគ្រប់លំដាប់ថ្នាក់ ដោយផ្អែកលើគោលការណ៍ណែនាំគន្លឹះមួយចំនួន។

### *៥.១. គោលការណ៍ណែនាំ*

១. ប្រកាន់ខ្ជាប់នូវគុណតម្លៃនៃការអភិវឌ្ឍដោយចីរភាព។

២. ធានាថា អាទិភាពនៃការអភិវឌ្ឍជាតិអាចសម្រេចបាន នៅក្រោមលក្ខខណ្ឌប្រែប្រួលអាកាសធាតុ។

៣. ផ្តោតលើការគំរាមកំហែង ក៏ដូចជាកាលានុវត្តភាពនៃការប្រែប្រួលអាកាសធាតុ និងឱកាសទាញយកប្រយោជន៍ពីការបំពេញគ្នារវាងការងារបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

៤. ទទួលស្គាល់ពីភាពស្មុគស្មាញ និងទំនាក់ទំនងគ្នានៃការប្រែប្រួលអាកាសធាតុ និងភាពចាំបាច់ក្នុងការប្រើប្រាស់វិធីសាស្ត្រពហុជំនាញ អន្តរវិស័យ និងវិសាលភាពផ្សេងៗ ក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។

៥. ទទួលស្គាល់ភាពមិនប្រាកដប្រជានៃការប្រែប្រួលអាកាសធាតុទៅអនាគត បង្កើតភាពបត់បែនបាននៅក្នុងការគ្រប់គ្រងប្រព័ន្ធសំខាន់ៗ ដើម្បីដោះស្រាយការប្រែប្រួលដែលមិនអាចដឹងមុន និងប្រើប្រាស់ដំណោះស្រាយផ្អែកលើហានិភ័យ និងជាដំណាក់កាល នៅក្នុងការកសាងផែនការឆ្លើយតប។

៦. ដោះស្រាយជាមួយគ្នានូវព្រឹត្តិការណ៍មិនប្រក្រតី និងការប្រែប្រួលសំខាន់ៗ (ដូចជាការប្រែប្រួលរដូវ) ដែលបង្កដោយការប្រែប្រួលអាកាសធាតុ។

៧. ប្រើប្រាស់រួមគ្នាវិធីសាស្ត្រដែលផ្អែកលើវិទ្យាសាស្ត្រ ផ្អែកលើស្ថានប្រព័ន្ធ និងផ្អែកលើសហគមន៍។

៨. ធានាថា វិធានការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុមានសមធម៌ គិតគូរអំពីយេនឌ័រ មានតម្លាភាព មានគណនេយ្យភាព និងសមស្របទៅតាមវប្បធម៌ជាតិ។

៩. ផ្អែកលើចំណេះដឹង នវានុវត្តន៍ និងការកែប្រែទម្លាប់ នៅក្នុងការបង្កើតដំណោះស្រាយសម្រាប់បន្សាំនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

១០. ចូលរួមយ៉ាងសកម្មជាមួយសហគមន៍អន្តរជាតិ និងនៅថ្នាក់តំបន់ ក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។

## *៥.២. ការវិភាគយុទ្ធសាស្ត្រ*

ដើម្បីធានាឱ្យមានការបន្សុីគ្នាជាមួយគោលបំណង និងអាទិភាពអភិវឌ្ឍន៍ជាតិ ឯកសារសំខាន់ៗមួយចំនួនត្រូវបានលើកយកមកពិចារណា នៅពេលធ្វើការវិភាគជាយុទ្ធសាស្ត្រ។ ឯកសារទាំងនោះរួមមាន ៖

- យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២
- ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ (សេចក្តីព្រាង)
- របាយការណ៍អភិវឌ្ឍន៍មនុស្សកម្ពុជាឆ្នាំ២០១១

- គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា
- សមិទ្ធផល និងទិសដៅទៅអនាគតរបស់រដ្ឋាភិបាលកម្ពុជា សម្រាប់ការអភិវឌ្ឍដោយចីរភាព (របាយការណ៍ជាតិសម្រាប់កិច្ចប្រជុំកំពូលរីយ៉ូ+២០)
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣
- របាយការណ៍ជាតិលើកទី១ ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- សេចក្តីព្រាងរបាយការណ៍ជាតិលើកទី២ ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- សេចក្តីព្រាងគោលនយោបាយបរិស្ថានជាតិឆ្នាំ២០១២
- គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការជាតិ និងតាមវិស័យ
- គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ ២០១៣-២០៣០
- ឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ។

**ស្ថានភាពគោលនៃការអភិវឌ្ឍជាតិ**

កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចសម្រាប់រយៈពេលវែង (១៩៩៤-២០១១) ក្នុងកម្រិត៦-៧% នៃផលិតផលក្នុងស្រុកប្រចាំឆ្នាំ។ ស្ថិរភាពកំណើនសេដ្ឋកិច្ចភាគច្រើនផ្អែកលើការលូតលាស់ក្នុងវិស័យកសិកម្ម វិស័យកាត់ដេរ វិស័យសំណង់ និងទេសចរណ៍។ ជាបណ្តើរៗ ការកសាងផែនការផ្អែកលើគម្រោង ត្រូវបានជំនួសដោយការកសាងផែនការផ្អែកលើកម្មវិធី នៅក្នុងការជំរុញឱ្យមានការអភិវឌ្ឍដោយចីរភាព។ ការប្រមូល និងគ្រប់គ្រងទិន្នន័យឱ្យបានប្រសើរកំពុងរួមចំណែកកែលម្អប្រព័ន្ធកសាងផែនការ និងវិភាជន៍ធនធានប្រកបដោយប្រសិទ្ធភាព។ ទោះជាយ៉ាងណាក៏ដោយ ពិពិធកម្មសេដ្ឋកិច្ចនៅមានកម្រិតទាប ដោយសារប្រជាជនកម្ពុជា ដែលពុំមានជំនាញវិជ្ជាជីវៈច្បាស់លាស់នៅមានអត្រាខ្ពស់។

គម្របព្រៃឈើគិតជាភាគរយនៃផ្ទៃដីសរុបនៅក្នុងឆ្នាំ២០១០ មានចំនួន៥៧,០៧% ក្នុងនោះតំបន់ការពារធម្មជាតិក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន មានប្រមាណជាង៣ លានហិកតា។

កសិកម្មនៅតែបន្តជាវិស័យ ដែលស្រូបយកកម្លាំងពលកម្មច្រើនបំផុតក្នុងចំណោមប្រជាពលរដ្ឋ ដោយបច្ចុប្បន្នមាន៥៧,៦% នៃមនុស្សពេញកម្លាំងធ្វើការនៅក្នុងវិស័យនេះ។

យោងតាម ផ.យ.អ.ជ. បច្ចុប្បន្នកម្ម (២០០៩-២០១៣) ដីដាំដំណាំនៅឆ្នាំ២០០៨ មានទំហំប្រមាណជាង៣,៣១លានហិកតា ដែលក្នុងនោះរួមមាន ដំណាំស្រូវ២,៦១លានហិកតា ដំណាំរួមផ្សំ០,៥៩លានហិកតា និងដំណាំកៅស៊ូ០,១១លានហិកតា។ យុទ្ធសាស្ត្រសម្រាប់កសិកម្ម និងទឹក (២០០៦-២០១០) គូសបញ្ជាក់ថា ផ្ទៃដីដាំដំណាំប្រមាណ៧-៨% តែប៉ុណ្ណោះដែលទទួលបានទឹកស្រោចស្រពគ្រប់គ្រាន់ ហើយប្រហែល១០% ទៀតទទួលបានទឹកស្រោចស្រពបន្ថែមលើទឹកភ្លៀង ចំណែកឯជាង៨០% ដែលនៅសល់ពឹងផ្អែកទាំងស្រុងលើទឹកភ្លៀង។

ត្រីជាប្រភពប្រូតេអ៊ីនរហូតដល់៨០% នៃប្រូតេអ៊ីនសត្វ នៅក្នុងរបបអាហាររបស់ប្រជាជន ហើយវិស័យជលផលរួមចំណែកប្រមាណ១០% នៃផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា ដោយផ្តល់ការងារពេញម៉ោង និងមិនពេញម៉ោងសរុបដល់ប្រជាជន៦លាននាក់ នៅទូទាំងប្រទេស។ ភាគច្រើននៃដែននេសាទទឹកសាបមាននៅតាមទន្លេ បឹង និងតំបន់ដីសើម ដូចជាបឹងទន្លេសាប និងទន្លេមេគង្គ។

ទេសចរណ៍ជាវិស័យធំជាងគេទី៣ ដែលស្ថិតក្នុងលំដាប់បន្ទាប់ពីកសិកម្ម និងឧស្សាហកម្មកាត់ដេរ។ ប្រាក់ចំណូលជាតិបានពីវិស័យទេសចរណ៍មានកំណើន១៧ដង ពី១០០លានដុល្លារ នៅឆ្នាំ១៩៩៥ រហូតដល់១.៧៨៦លានដុល្លារ នៅឆ្នាំ២០១០ ដែលបានបង្កើតការងារដោយផ្ទាល់សម្រាប់ប្រជាជន៣,១៥ សែននាក់។

របាយការណ៍ជាតិសម្រាប់កិច្ចប្រជុំកំពូលរីយ៉ូ+២០ បង្ហាញថា ការផ្គត់ផ្គង់អគ្គិសនីនៅកម្ពុជាពុំទាន់គ្រប់គ្រាន់នៅឡើយទេ ហើយមានតែ១៧,២% នៃប្រជាជនសរុបទូទាំងប្រទេសប៉ុណ្ណោះ ក្នុងនោះប្រជាជននៅជនបទប្រមាណ៦% មានអគ្គិសនីប្រើប្រាស់ នៅឆ្នាំ២០១២។ អត្រាប្រើប្រាស់អគ្គិសនី សម្រាប់ប្រជាជនម្នាក់ មានតែ ១៩៩ គីឡូវ៉ាត់ម៉ោងក្នុងមួយឆ្នាំ (ប៉ាន់ប្រមាណឆ្នាំ២០១៣)។

ការផលិតអគ្គិសនីពីឥន្ធនៈហ្វូស៊ីលមាន៩៥,២% នៃសមត្ថភាពផលិតសរុប ចំណែកថាមពលវារីអគ្គិសនីមានត្រឹមតែ៣,៣% ប៉ុណ្ណោះ ហើយប្រភពថាមពលកកើតឡើងវិញដទៃទៀតគឺ១,៥%។ ប្រជាជនច្រើនជាង៨០% នៅតែពឹងផ្អែកលើអុស និងធ្យូងសម្រាប់ចំអិនអាហារប្រចាំគ្រួសារ។

យោងតាមក្រសួងសាធារណការ និងដឹកជញ្ជូន ចំនួនយានយន្តដែលចុះបញ្ជី ដូចជាទោចក្រយានយន្ត រថយន្តគ្រួសារ រថយន្តដឹកអ្នកដំណើរខ្នាតតូចនិងធំ រថយន្តដឹកទំនិញខ្នាតតូចនិងធំ មានចំនួន៣០៧.០០០គ្រឿង នៅឆ្នាំ២០០៩ ជាមួយនឹងអត្រាកំណើនប្រមាណ១៩% ក្នុងមួយឆ្នាំ។

**ព្យាករណ៍អំពីការអភិវឌ្ឍជាតិ**

- អត្រាកំណើនសេដ្ឋកិច្ចនៅកម្ពុជាត្រូវបានព្យាករណ៍ថាមាន៧-៨% សម្រាប់ឆ្នាំ២០១៤។
- វិស័យដំណាំកសិកម្មអាចមានកំណើន៥% ក្នុងមួយឆ្នាំ ដើម្បីសម្រេចចំណុចដៅកំណើនសេដ្ឋកិច្ចជាតិ។

- នៅឆ្នាំ២០១១ វិស័យកសិកម្មរួមចំណែក៣២,១% នៃផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំ និងត្រូវបានចាត់ទុកថាជាកម្លាំងចលករដ៏សំខាន់នៃកំណើនសេដ្ឋកិច្ចនៅក្នុង **ផ.យ.អ.ជ.** បន្ទាប់នេះ។
- ចំណុចដៅសម្រាប់វិស័យទេសចរណ៍ (គិតជាចំនួនមនុស្ស) គឺទទួលភ្ញៀវទេសចរអន្តរជាតិនៅឆ្នាំ២០១៥ ចំនួន៤,៥លាននាក់ ហើយនៅឆ្នាំ២០១៨ កើនដល់៦,១លាននាក់ រួមជាមួយភ្ញៀវទេសចរជាតិប្រមាន១០,៥ លាននាក់ ដែលអាចបង្កើតការងារដោយផ្ទាល់បានជិត៧សែននាក់។
- រាជរដ្ឋាភិបាលកម្ពុជាមានមហិច្ឆតាជំរុញស្ថានភាពប្រទេស ឱ្យចាកចេញផុតពីប្រទេលមានចំណូលទាបឈានឡើងជាប្រទេសមានចំណូលមធ្យមកម្រិតទាប យ៉ាងយូរនៅឆ្នាំ២០១៨ និងក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០។
- ដោយមានផ្ទៃដី៥៧,០៧% (ឆ្នាំ២០១០) ជាគម្របព្រៃឈើ កម្ពុជាមានឱកាសក្នុងការទទួលផលពីយន្តការទីផ្សារឥណទានការបូន ដូចជា នៅក្នុងក្របខ័ណ្ឌកាកាត់បន្ថយការបញ្ចេញឧស្ម័ន ពីការបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើ (REDD)។
- តាមរយៈអត្រាកំណើនផលិតផលស្រូវប្រចាំឆ្នាំ៥,៧២% កម្ពុជារំពឹងថា នឹងក្លាយខ្លួនជាប្រទេសនាំចេញអង្ករឱ្យបាន១លានតោន នៅឆ្នាំ២០១៥។
- យោងតាមក្រសួងបរិស្ថាន តួលេខប៉ាន់ស្មានអំពីការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីវិស័យដឹកជញ្ជូន នឹងកើនពី៧៨៥ពាន់តោនសមមូលឧស្ម័នកាបូនិក នៅឆ្នាំ២០០០ ដល់១១.៣៧៦ពាន់តោនសមមូលឧស្ម័នកាបូនិករហូតដល់ឆ្នាំ២០៥០ ដែលតំណាងឱ្យកំណើន២៧% ក្នុងមួយឆ្នាំ។

**បញ្ហាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដែលលើកឡើងនៅក្នុង ផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣**

ផ.យ.អ.ជ. បានបញ្ជាក់ពីភាពចាំបាច់ក្នុងការដោះស្រាយបញ្ហា និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងកំណត់វិធានការឆ្លើយតប ដែលរួមមាន ៖

- ស្ថានភាពទឹកជំនន់មកលើហេដ្ឋារចនាសម្ព័ន្ធ
  - ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ត្រូវការពង្រឹងជាបន្ថែម ជាពិសេសផ្លូវថ្នល់ជនបទ ដើម្បីបញ្ចៀសការរំខានពីទឹកជំនន់មកលើការធ្វើដំណើររបស់ប្រជាជន និងការដឹកជញ្ជូនទំនិញ។
  - ទំនប់ និងប្រឡាយដោះទឹកនានាត្រូវសាងសង់បន្ថែម នៅក្នុងតំបន់ភូមិសាស្ត្រ ដែលងាយរងគ្រោះ ដើម្បីគ្រប់គ្រងលំហូរយ៉ាងច្រើនពីទឹកទន្លេ ឬស្ទឹងក្នុងពេលទឹកជំនន់។
- កម្ពុជានៅខ្វះថាមពលអគ្គិសនី ដែលជាមូលហេតុមួយក្នុងចំណោមមូលហេតុនានា បណ្តាលឱ្យការអភិវឌ្ឍឧស្សាហកម្មមានកម្រិតទាប។ ត្រូវយកចិត្តទុកដាក់ទៅលើប្រភពថាមពល ដែលមានមេត្រីភាពជាមួយបរិស្ថាន ដូចជាថាមពលវារីអគ្គិសនីជាដើម។

- ការកាត់បន្ថយភាពក្រីក្រជាបន្តបន្ទាប់ គឺជាគោលបំណងយូរអង្វែងរបស់រាជរដ្ឋាភិបាលកម្ពុជា។ ក៏ប៉ុន្តែដោយហេតុថា ប្រជាជនច្រើនជាង៨០% នៅតែពឹងអាស្រ័យលើវិស័យកសិកម្ម និងសកម្មភាពផលិតកសិផលសម្រាប់តែទ្រទ្រង់ជីវិត នោះគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត អាចរុញច្រានប្រជាជនយ៉ាងច្រើន ឱ្យធ្លាក់ក្រោមកម្រិតខ្សែបន្ទាត់ភាពក្រីក្រ។
- ការគ្រប់គ្រងទឹក និងផលផលរួមចំណែកទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។ ការប្រែប្រួលរបបធារាសាស្ត្របណ្តាលមកពីការប្រែប្រួលអាកាសធាតុ អាចជះផលអវិជ្ជមានដល់ផលនេសាទ។
- កិច្ចការពារ និងរក្សាពពួករុក្ខជាតិ និងសត្វដ៏សំបូរបែបនៅកម្ពុជា។
- កិច្ចប្រឹងប្រែងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ជាពិសេសនៅតាមទីជនបទ ត្រូវការពង្រីកជាបន្ថែម។
- ក្រៅពីកិច្ចការពារធនធានទឹក និងព្រៃឈើ រាជរដ្ឋាភិបាលកំពុងជំរុញការដាំដើមឈើ ស្តារព្រៃរេចរឹល និងការវិនិយោគលើដំណាំសម្រាប់ផលិតជីវឥន្ធនៈ។

## **ព្យាករណ៍អាកាសធាតុ និងឥទ្ធិពលពាក់ព័ន្ធ**

### *ព្យាករណ៍អាកាសធាតុ*

- ក្នុងរយៈពេលកន្លងមក សីតុណ្ហភាពនៅកម្ពុជាបានកើនឡើងរួចទៅហើយ។ និន្នាការនេះត្រូវបានព្យាកណ៍ថា នឹងបន្តកើនឡើង ដោយសីតុណ្ហភាពមធ្យមប្រចាំខែនឹងកើនឡើងចន្លោះពី០,០១៣℃ ដល់០,០៣៦℃ ក្នុងមួយឆ្នាំៗ រហូតដល់ឆ្នាំ២០៩៩ អាស្រ័យលើទីតាំង ដោយមានអត្រាកំណើនខ្ពស់នៅតំបន់ទំនាប។
- ទោះបីពុំទាន់មានភស្តុតាងច្បាស់លាស់អំពីផលប៉ះពាល់លើកម្ពស់ទឹកភ្លៀងក្តី ក៏ការព្យាករណ៍នានាបានបញ្ជាក់ថា ជារួមកម្ពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំនឹងកើននៅប្រទេសកម្ពុជា។ ការព្យាករណ៍របបទឹកភ្លៀងប្រចាំរដូវ បង្ហាញពីនិន្នាការកើនឡើងរវាងខែមិថុនា និងសីហា នៅតំបន់ពាយព្យ និងនិន្នាការថយចុះនៅភាគឦសាន។
- របាយការណ៍វាយតម្លៃលើកទី៤ របស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ បានប៉ាន់ស្មានថា កម្ពស់ទឹកសមុទ្រនៅក្នុងតំបន់នេះ នឹងកើនឡើងទៅតាមកម្រិតដូចតទៅ ៖ រហូតដល់ឆ្នាំ២០៩០ ធៀបនឹងឆ្នាំ១៩៨០-១៩៩៩ កម្ពស់ទឹកសមុទ្រនឹងកើនឡើងពី០,១៨ ដល់០,៤៣ម. នៅក្រោមសេណារីយ៉ូអត្រាបញ្ចេញឧស្ម័នកម្រិតទាប (SRES B1); ០,២១-០,៥២ម. នៅក្រោមសេណារីយ៉ូអត្រាបញ្ចេញឧស្ម័នកម្រិតមធ្យម (SRES A1B) និង០,២៣-០,៥៦ម. នៅក្រោមសេណារីយ៉ូអត្រាបញ្ចេញឧស្ម័នកម្រិតខ្ពស់ (SRES. A2)។ នេះមានន័យថា នៅក្រោមសេណារីយ៉ូ SRES A2 អត្រាកំណើនកម្ពស់ទឹកសមុទ្រនឹងមាន០,៥៦ម. ដែលអាចបង្កឱ្យមានការជន់លិចជាអចិន្ត្រៃយ៍លើផ្ទៃដីទំហំប្រមាណ២៥.០០០ហិកតា នៅតាមតំបន់ឆ្នេរកម្ពុជា ក្នុងរយៈពេល៩០ឆ្នាំខាងមុខ។

*ឥទ្ធិពលពាក់ព័ន្ធ*

- កំណើនសីតុណ្ហភាពទំនងជាបង្កឱ្យមានឥទ្ធិពលមកលើផលិតភាពកសិកម្ម។ យោងតាមវិទ្យាស្ថានស្រាវជ្រាវពូជស្រូវបានបង្ហាញថា ទិន្នផលស្រូវនឹងថយចុះ១០% សម្រាប់កំណើនសីតុណ្ហភាព១°C ធៀបនឹងសីតុណ្ហភាពអប្បបរមានៅរដូវដាំដុះ (ពេលយប់) នៅក្នុងរដូវប្រាំង។
- គម្រោងបន្សាំ និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុក្នុងតំបន់មេគង្គ (Mekong ARCC) បានបង្ហាញថា ខេត្តនៅរយៈកម្ពស់ខ្ពស់នៃកម្ពុជានៅរដូវវស្សានឹងមានភ្លៀងច្រើនជាងមុន ដោយឡែកនៅរដូវប្រាំងវិញមានសភាពស្ងួតហែង ដែលអាចរារាំងការផលិតកាហ្វេ និងកៅស៊ូ។
- ឆ្នេរសមុទ្រកម្ពុជាប្រវែង៤៣៥គ.ម. ងាយរងគ្រោះដោយសារកំណើនកម្ពស់ទឹកសមុទ្រ និងផលប៉ះពាល់ធ្ងន់ធ្ងរពីខ្យល់ព្យុះទីហ្វុងកាន់តែញឹកញាប់ នៅក្រោមការព្យាករណ៍អាកាសធាតុនាពេលអនាគត។ បញ្ហានេះអាចមានឥទ្ធិពលមកលើសក្តានុពលភ្ញៀវទេសចរ និងបង្កឱ្យមានការហូរច្រោះផងដែរ ហើយខ្យល់បក់ខ្លាំងបណ្តាលឱ្យខូចខាតដល់លំនៅស្ថាននៅតំបន់ឆ្នេរ។
- ក្នុងករណីដែលផ្ទៃដីស្រោចស្រពគ្រប់គ្រាន់មានតែ៧-៨% កម្ពុជាប្រហែលជាពិបាកសម្រេចបានកំណើនកសិផល៥% ក្នុងមួយឆ្នាំៗ ដើម្បីសម្រេចបានចំណុចដៅក្នុងការបង្កើនការនាំចេញផលិតផលកសិកម្មនៅឆ្នាំ២០៣០ ក្រោមលក្ខខណ្ឌប្រែប្រួលអាកាសធាតុ (ដូចជាគ្រោះរាំងស្ងួត) ជាពិសេសសម្រាប់ដំណាំសំខាន់ៗមួយចំនួន ដូចជាដំណាំស្រូវ ប្រសិនបើគ្មានការវិនិយោគក្នុងការពង្រីកប្រព័ន្ធស្រោចស្រពទេនោះ។
- យោងតាមកម្រងទិន្នន័យគ្រោះមហន្តរាយអន្តរជាតិ (EM-DAT) គ្រោះធម្មជាតិនៅឆ្នាំ២០១១ បានបង្កការខូចខាតសេដ្ឋកិច្ចប្រមាណ៤,៣% នៃផលិតផលក្នុងស្រុកសរុប។ ទឹកជំនន់ដែលបង្កដោយការប្រែប្រួលអាកាសធាតុត្រូវបានព្យាករណ៍ថា នឹងកើតមានកាន់តែញឹកញាប់ និងធ្ងន់ធ្ងរជាងមុន ជាពិសេសនៅតំបន់ទំនាបកណ្តាល។ នៅពេលដែលតំបន់ឆ្នេរនឹងរងឥទ្ធិពលពីខ្យល់ព្យុះស៊ីក្លូន មកពីមហាសមុទ្រប៉ាស៊ីហ្វិក តំបន់ទំនាបកណ្តាលនឹងរងគ្រោះដោយសារទឹកជំនន់ ដែលបង្កដោយកំណើនភ្លៀងធ្លាក់។ តំបន់ទាំងពីរនេះមានសារៈសំខាន់ណាស់ចំពោះសេដ្ឋកិច្ចជាតិ ដោយសារតែវិភាគទានខ្ពស់ទៅក្នុងសារពើពន្ធទទួលបានពីទេសចរណ៍ សេវាកម្ម សកម្មភាពនាវាចរ ការនេសាទ និងផលិតផលកសិកម្ម។ ជាការចាំបាច់ត្រូវចាត់វិធានការដើម្បីកាត់បន្ថយផលប៉ះពាល់នៃហានិភ័យ និងគ្រោះមហន្តរាយបណ្តាលមកពីប្រែប្រួលអាកាសធាតុ ដើម្បីឱ្យកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ តាមការរំពឹងទុកក្នុងកម្មវិធីអភិវឌ្ឍន៍ជាតិ។
- ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់កម្ពុជា នៅមានកម្រិតទាបខ្លាំង បើប្រៀបធៀបនឹងតួលេខមធ្យមនៅថ្នាក់តំបន់ និងពិភពលោក។ យោងតាមរបាយការណ៍ជាតិលើកទី២ ក្រោមអនុសញ្ញាក្របខ័ណ្ឌសហ

ប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ បរិមាណឧស្ម័នផ្ទះកញ្ចក់សរុបដែលកម្ពុជាបញ្ចេញនៅឆ្នាំ ២០០០ មានប្រមាណ៤៧,៦លានតោន ហើយវិស័យព្រៃឈើបានស្រូបយកចំនួនប្រមាណ៤៨លានតោន គិតជាសមមូលឧស្ម័នកាបូនិក។ នៅក្នុងអំឡុងពេលដូចគ្នានេះ វិស័យដឹកជញ្ជូនប្រើប្រាស់ឥន្ទនៈហ្វូស៊ីលច្រើនជាងគេ បន្ទាប់មកគឺការផលិតអគ្គិសនី លំនៅដ្ឋាន និងវិស័យឧស្សាហកម្ម។ កម្ពុជាត្រូវបង្កើនការផលិតថាមពល សំដៅជំរុញសកម្មភាពឧស្សាហកម្ម ទន្ទឹមនឹងការកែលម្អប្រសិទ្ធភាពថាមពលនៅក្នុងវិស័យដឹកជញ្ជូន និងវិស័យលំនៅដ្ឋាន ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ នៅក្នុងដំណាក់កាលបង្កើនការផ្គត់ផ្គង់នេះ ចាំបាច់ត្រូវចាប់ផ្តើមគិតគូរអំពីការបញ្ចូលប្រភពថាមពលកកើតឡើងវិញ ទៅក្នុងផលិតកម្មថាមពល។

**សមត្ថភាពឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ**

ផែនទីស្តីពីភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុនៅតំបន់អាស៊ីអាគ្នេយ៍ ដែលរៀបចំឡើងដោយកម្មវិធីសេដ្ឋកិច្ច និងបរិស្ថានសម្រាប់អាស៊ីអាគ្នេយ៍ បានបង្ហាញថា កម្ពុជាជាប្រទេសងាយរងគ្រោះបំផុតមួយ ពីការប្រែប្រួលអាកាសធាតុ ដោយសារសមត្ថភាពបន្សាំនៅមានកម្រិតទាប។

ការវិភាគ "ភាពខ្លាំង ភាពទន់ខ្សោយ កាលានុវត្តភាព និងការគម្រាមកំហែង" (SWOT) នៃវិធានការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុរបស់កម្ពុជា បានធ្វើឡើងតាមរយៈការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធជាច្រើន រួមមានស្ថាប័នរដ្ឋ សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងផ្នែកឯកជន។ លទ្ធផលពីការវិភាគ SWOT (ដូចមានបង្ហាញជូនខាងក្រោម) ត្រូវបានយកមកពិចារណាបន្ថែម ក្នុងពេលរៀបចំផែនការយុទ្ធសាស្ត្រនេះ។

***ភាពខ្លាំង***

- ព្រះរាជាណាចក្រកម្ពុជាមានកំណើនសេដ្ឋកិច្ចខ្ពស់
- ចំណាប់អារម្មណ៍លើចំណេះដឹង និងព័ត៌មានពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ
- ចំណាប់អារម្មណ៍លើការអភិវឌ្ឍដោយចីរភាពមានកម្រិតខ្ពស់
- មូលដ្ឋានធនធានធម្មជាតិ និងជីវៈចម្រុះសម្បូរបែប
- គោលនយោបាយរបស់រដ្ឋាភិបាលស្តីពីការអភិវឌ្ឍសេដ្ឋកិច្ច
- ក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួនបានបង្កើតយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុតាមវិស័យអាទិភាព
- ការគាំទ្រពីស្ថាប័នពាក់ព័ន្ធសហគមន៍អន្តរជាតិនិងសង្គមស៊ីវិល លើដំណោះស្រាយការប្រែប្រួលអាកាសធាតុ
- កំណើនការយល់ដឹងស្តីពីការប្រែប្រួលអាកាសធាតុ
- គោលនយោបាយស្តីពីបរិស្ថាន និងសុខភាព

- ហេដ្ឋារចនាសម្ព័ន្ធបានកែលម្អជាបន្តបន្ទាប់

*ភាពទន់ខ្សោយ*

- ការធ្វើសេចក្តីសម្រេចចិត្តដោយផ្អែកលើចំណេះដឹងវិទ្យាសាស្ត្រនៅមានភាពទន់ខ្សោយ
- គ្មាននីតិវិធីច្បាស់លាស់សម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ជាតិ
- សមត្ថភាពស្ថាប័នជាតិទទួលបន្ទុកការប្រែប្រួលអាកាសធាតុ និងការចូលរួមរបស់អ្នកពាក់ព័ន្ធនៅមានកម្រិត
- ព័ត៌មានចាស់ៗសម្រាប់ដោះស្រាយផលប៉ះពាល់អាកាសធាតុ
- កង្វះខាតធនធានមនុស្ស
- មិនមានទម្លាប់កសាងផែនការអំពីការប្រែប្រួលអាកាសធាតុ
- មូលដ្ឋានចំណេះដឹង ការស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាមានកម្រិតទាប
- ធនធានហិរញ្ញវត្ថុមានកម្រិត
- ប្រជាពលរដ្ឋមានសមត្ថភាពបន្សាំទាប

*ភាពលានុវត្តភាព*

- មូលនិធិប្រែប្រួលអាកាសធាតុពិភពលោកកើនឡើង
- ការបង្កើតរចនាសម្ព័ន្ធចំណេះដឹង និងព័ត៌មានជាតិ
- ការបង្កើតផែនការអភិវឌ្ឍន៍ដោយចីរភាពរបស់ជាតិ
- ការប្តេជ្ញា និងគាំទ្រខាងនយោបាយចំពោះដំណោះស្រាយការប្រែប្រួលអាកាសធាតុ
- កែលម្អជីវភាពប្រជាជន
- កិច្ចប្រឹងប្រែងពិភពលោកក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ
- កម្មវិធីដែលមានស្រាប់ ដូចជាសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា និងកម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ
- ដៃគូអភិវឌ្ឍន៍គាំទ្ររាជរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ
- កម្មវិធីបង្កើតជំនាញ និងវិជ្ជាជីវៈ

*ការគម្រាមកំហែង*

- ៤៣% នៃឃុំសរុបងាយរងគ្រោះបំផុត
- ការយល់ដឹងកម្រិតទាបអំពីការប្រែប្រួលអាកាសធាតុ និងជម្រើសវិធានការឆ្លើយតប
- គោលនយោបាយ និងអាទិភាពជាច្រើនប្រជែងជាមួយគោលនយោបាយស្តីពីការប្រែប្រួលអាកាសធាតុ

- វិស័យសេដ្ឋកិច្ចចម្បងៗ នៅតែបន្តប្រឈមនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ
- សមត្ថភាពនៅមានកម្រិតសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
- ព្រឹត្តិការណ៍អាកាសធាតុមិនប្រក្រតីកើតមានញឹកញាប់
- ខ្វះភាពធន់ទៅនឹងគ្រោះមហន្តរាយធម្មជាតិ

**ស្ថាប័នសម្របសម្រួលការងារប្រែប្រួលអាកាសធាតុ**

គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (គ.ជ.គ.ប.អ.) ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៦ ដោយមានអាណត្តិរៀបចំ សម្របសម្រួល និងតាមដានពិនិត្យការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ បរិធានច្បាប់ ផែនការ និងកម្មវិធីនានា របស់រាជរដ្ឋាភិបាល សំដៅឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ។ គណៈកម្មាធិការនេះមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាប្រធានកិត្តិយស និងឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន ជាប្រធាន។ ក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ ត្រូវបានបង្កើតឡើង ដែលជាអង្គភាពអន្តរក្រសួង សម្រាប់ផ្តល់ការគាំទ្របច្ចេកទេសដល់សមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ នៅក្នុងការបំពេញអាណត្តិរបស់ខ្លួន។ នាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃក្រសួងបរិស្ថាន មាននាទីជាលេខាធិការដ្ឋាន របស់គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងសម្របសម្រួលសកម្មភាព របស់ក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ។ ក្រសួងពាក់ព័ន្ធសំខាន់ៗ បានតែងតាំងមន្ត្រីបង្គោល និងក្រុមការងារប្រែប្រួលអាកាសធាតុ ដើម្បីធ្វើការងារទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដូចជាការរៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងគម្រោងប្រែប្រួលអាកាសធាតុតាមវិស័យ។

ជាការចាំបាច់ត្រូវពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធស្ថាប័នប្រែប្រួលអាកាសធាតុបច្ចុប្បន្ន សំដៅដាក់ចេញជាអនុសាសន៍សម្រាប់កែលម្អ ដើម្បីលើកកម្ពស់ការសម្របសម្រួលអន្តរក្រសួង និងការអនុវត្ត **ផ.យ.ប.អ.ក.** ក៏ដូចជាវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនានា។

**យេនឌ័រ និងការប្រែប្រួលអាកាសធាតុ**

រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា ក្នុងចំណោមប្រជាពលរដ្ឋក្រីក្រនៅជនបទ ដែលក្នុងនោះភាគច្រើនជាស្ត្រី ជាក្រុមងាយរងគ្រោះបំផុតពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដោយសារតែពួកគាត់ពឹងផ្អែកជាខ្លាំងលើកសិកម្ម និងធនធានធម្មជាតិ។ ក្រុមនេះងាយទទួលរងគ្រោះពីជម្ងឺ ដោយសារធនធាន និងសមត្ថភាពបន្សាំនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ក៏ដូចជាការត្រៀមបង្ការរបស់ពួកគាត់សម្រាប់ទប់ទល់នឹងហានិភ័យអាកាសធាតុ និងមុខសញ្ញាមហន្តរាយ នៅមានកម្រិត។ ដូច្នេះ ចាំបាច់ត្រូវបញ្ជ្រាបយេនឌ័រទៅក្នុងវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ រួមទាំងគោលនយោបាយ ច្បាប់ដែលមានស្រាប់ និងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ ដើម្បីឱ្យបញ្ហាអន្តរវិស័យនេះបានទទួលការគាំទ្រពីស្ថាប័នរាជរដ្ឋាភិបាលទាំង

អស់ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិលនានា ស្ថាប័នស្រាវជ្រាវអប់រំ និងវិស័យឯកជន។

**ការអប់រំ ការលើកកម្ពស់ការយល់ដឹង និងការប្រាស្រ័យទាក់ទង**

ការបញ្ជ្រាបចំណេះដឹង និងព័ត៌មានអំពីការប្រែប្រួលអាកាសធាតុទៅក្នុងការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ គឺជាគោលការណ៍គន្លឹះ ក្នុងការទ្រទ្រង់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ សម្រាប់កសាងសង្គមមួយ ដែលបៃតង មានសមធម៌ និងធន់ទៅនឹងអាកាសធាតុ។ ប្រការសំខាន់ គឺត្រូវបង្កើតបរិយាកាសអំណោយផលសម្រាប់ការសិក្សាអប់រំ និងការលើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ ដោយបង្កើត និងពង្រឹងរចនាសម្ព័ន្ធ ប្រព័ន្ធ និងឧបករណ៍សម្រាប់ការប្រាស្រ័យទាក់ទង។

## *៥.៣.ទិសដៅជាយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រ*

**ទិសដៅជាយុទ្ធសាស្ត្រទី ១ ៖ លើកកម្ពស់ភាពធន់នឹងអាកាសធាតុ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង ទឹក និងថាមពល**

<u>យុទ្ធសាស្ត្រ</u>

ក. សិក្សាវិភាគលើការរួមចំណែកនៃវិស័យពាក់ព័ន្ធក្នុងការធានាសន្តិសុខនៃប្រព័ន្ធសំខាន់ៗ។

ខ. ជំរុញ និងលើកទឹកចិត្តអ្នកពាក់ព័ន្ធ និងវិស័យនានា ឱ្យចូលរួមនៅក្នុងការកំណត់វិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

គ. ពង្រឹងយន្តការសម្របសម្រួលសម្រាប់ការឆ្លើយតបឱ្យស៊ីសង្វាក់គ្នា នៅក្នុងគោលនយោបាយឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

ឃ. បង្កើនសមត្ថភាពក្នុងការកំណត់រកកាលានុវត្តភាព ដែលកើតចេញពីការប្រែប្រួលអាកាសធាតុ នៅក្នុងប្រព័ន្ធផលិតកម្មកសិកម្ម ប្រព័ន្ធអេកូឡូស៊ី និងតំបន់ការពារធម្មជាតិ ៖

- ពិពិធកម្មកសិកម្ម( ឧ. ដំណាំ ការចិញ្ចឹមសត្វ។ល។)
- កំណើនផលិតភាព ( ឧ. ដំណាំ ដលផល ការចិញ្ចឹមសត្វ ព្រៃឈើ។ល។)
- ឱកាសសម្រាប់បង្កើនមុខដំណាំថ្មី
- ការគ្រប់គ្រងទីជម្រាល និងប្រព័ន្ធអេកូឡូស៊ី។

ង. សម្រួលដល់ធុរកិច្ច និងឧស្សាហកម្ម ដែលឆ្លើយតបទៅនឹងកាលានុវត្តភាពទីផ្សារកាបូន សម្រាប់ពាណិជ្ជកម្ម និងការវិនិយោគបៃតង។

ច. លើកកម្ពស់ថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងផលប៉ះពាល់សុខភាព ៖

- ថាមពលកកើតឡើងវិញ
- ប្រសិទ្ធភាពថាមពល
- ការផ្ទេរបច្ចេកវិទ្យាសមស្រប
- ការគ្រប់គ្រងសំណល់រឹង/រាវតាមវិធានការចម្រុះ នៅរាជធានី ទីក្រុងទីប្រជុំជន និងការគ្រប់គ្រងសំណល់សត្វ។

ឆ. បង្កើតប្រព័ន្ធផលិតកម្មថាមពលវិមជ្ឈការ ដែលរួមបញ្ចូលទាំងការប្រើប្រាស់ថាមពលកកើតឡើងវិញ ជាពិសេសថាមពលព្រះអាទិត្យ។

ជ. ស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធទឹក ដែលរួមទាំងប្រព័ន្ធធារាសាស្ត្រខ្នាតតូច មធ្យម និងខ្នាតធំ។

ឈ. ស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ដែលធន់នឹងអាកាសធាតុ និងតភ្ជាប់តំបន់ផលិតកម្មទៅទីផ្សារ។

ញ. បញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

**ទិសដៅជាយុទ្ធសាស្ត្រទី ២ ៖ កាត់បន្ថយភាពងាយរងគ្រោះតាមវិស័យ តំបន់ យេនឌ័រ និងសុខភាព នៅចំពោះមុខផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ**

<u>យុទ្ធសាស្ត្រ</u>

ក. ប្រើប្រាស់លទ្ធផលនៃការសិក្សាវាយតម្លៃដែលមានស្រាប់អំពីភាពងាយរងគ្រោះនិងហានិភ័យ ព្រមទាំងសិក្សាវាយតម្លៃជាថ្មី នៅក្នុងករណីចាំបាច់ ដើម្បីចាត់ជាអាទិភាពវិធានការបន្សាំសម្រាប់តំបន់សំខាន់ៗនៃប្រទេសកម្ពុជា ដូចជាតំបន់ឆ្នេរ តំបន់ខ្ពង់រាប ទីជនបទ និងទីក្រុង។

ខ. អនុវត្តសកម្មភាពគន្លឹះនានា ដែលកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ របស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ សម្រាប់ដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

គ. លើកកម្ពស់សមាហរណកម្ម ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ទៅក្នុងយុទ្ធសាស្ត្រជាតិ ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រជាតិគាំពារសង្គម។

ឃ. លើកកម្ពស់វិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុថ្នាក់សហគមន៍ និងពង្រឹងភាពជាដៃគូរវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន។

ង. ជំរុញការប្រើប្រាស់បច្ចេកវិទ្យាសមស្របក្នុងផលិតកម្មដំណាំ និងការចិញ្ចឹមសត្វ សម្រាប់កសិករដែលងាយរងគ្រោះ។

ច. កែលម្អប្រសិទ្ធភាពនៃការគ្រប់គ្រងវិស័យជលផល។

ឆ. កែលម្អស្ថានប្រព័ន្ធព្រៃឈើ ព្រៃលិចទឹក តំបន់ឆ្នេរ និងតំបន់ការពារធម្មជាតិ។

ជ. លើកកម្ពស់ការផលិតកៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាព ដោយផ្តោតលើវិធានការបន្សាំ និងកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

ឈ. លើកកម្ពស់ផលិតកម្មសត្វ និងកិច្ចការពារសុខភាពសត្វប្រកបដោយនិរន្តរភាព។

ញ. កែលម្អហេដ្ឋារចនាសម្ព័ន្ធថែទាំសុខភាព និងសមត្ថភាពរបស់បុគ្គលិកថែទាំសុខភាព ដើម្បីទប់ទល់នឹងជម្ងឺដែលបង្កដោយភ្នាក់ងារចម្លង និងជម្ងឺឆ្លងតាមទឹក នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។

ដ. ណែនាំពីបច្ចេកវិទ្យាអភិវឌ្ឍន៍ និងស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។

ឋ. លើកកម្ពស់ការកសាងផែនការ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននៅទីក្រុង ដែលត្រូវការទុនច្រើន។

ឌ. ពង្រឹងគុណភាពហេដ្ឋារចនាសម្ព័ន្ធជនបទ (ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ អណ្តូង និងលូដោះទឹក) ដើម្បីឱ្យធន់នឹងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត។

ឍ. លើកកម្ពស់ប្រព័ន្ធផ្តល់ព័ត៌មានជាមុនអំពីធាតុអាកាស។

ណ. ផ្តល់អាទិភាពដល់តម្រូវការរបស់ស្ត្រីនៅក្នុងការបន្សាំ និងសកម្មភាពកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

**ទិសដៅជាយុទ្ធសាស្ត្រទី ៣ ៖ លើកកម្ពស់ ភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (បឹងទន្លេសាប ទន្លេមេគង្គ តំបន់ឆ្នេរ តំបន់ខ្ពង់រាប ។ល។) ជីវៈចម្រុះ តំបន់ការពារធម្មជាតិ និងតំបន់បេតិកភណ្ឌវប្បធម៌**

<u>យុទ្ធសាស្ត្រ</u>

ក. ពង្រឹងការអភិរក្សជីវៈចម្រុះ និងស្តារប្រព័ន្ធអេកូឡូស៊ី ដែលរងការគម្រាមកំហែងពីការប្រែប្រួលអាកាសធាតុ។

ខ. លើកកម្ពស់ និងលើកទឹកចិត្តឱ្យមានដំណោះស្រាយ ដែលផ្អែកលើសហគមន៍ ផ្អែកលើប្រព័ន្ធអេកូឡូស៊ី និងអេកូទេសចរណ៍ ជាមធ្យោបាយមានប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។

គ. លើកកម្ពស់ការប្រើប្រាស់ការបង់ថ្លៃសេវាប្រព័ន្ធអេកូឡូស៊ី រួមទាំងកម្មវិធីកាត់បន្ថយការបញ្ចេញឧស្ម័ន ពីការបាត់បង់ និងការរេចរិលព្រៃឈើ (REDD+)។

ឃ. លើកកម្ពស់ការកសាងផែនការប្រើប្រាស់ដី ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។

**ទិសដៅជាយុទ្ធសាស្ត្រទី ៤ ៖ លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យា ដែលបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព**

__យុទ្ធសាស្ត្រ__

ក. សិក្សាវិភាគទៅលើជម្រើស ដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិចនៅតាមវិស័យ និងប្រភពបញ្ចេញឧស្ម័ន (កសិកម្ម ថាមពល ការដឹកជញ្ជូន ឧស្សាហកម្ម ការគ្រប់គ្រងការប្រើប្រាស់ដីនិងព្រៃឈើ និងការគ្រប់គ្រងសំណល់)។

ខ. រៀបចំគោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងផែនការសកម្មភាពអភិវឌ្ឍន៍ ដែលបញ្ចេញកាបូនតិច ដោយអនុលោមតាមអាទិភាពអភិវឌ្ឍន៍នានារបស់ជាតិ។

គ. ជំរុញការផ្ទេរបច្ចេកវិទ្យាសមស្រប ដើម្បីលើកកម្ពស់ការអភិវឌ្ឍ ដែលបញ្ចេញកាបូនតិច (ដូចជាកែលម្អប្រសិទ្ធភាពថាមពល ថាមពលកកើតឡើងវិញ។ល។) និងសម្រួលឱ្យមានការប្រើប្រាស់ តាមរយៈ ៖

- គោលការណ៍ណែនាំជំនួយបច្ចេកទេស និងការបង្កើតភាពជាដៃគូ
- ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និងសារពើពន្ធ
- យន្តការទីផ្សារកាបូន
- ការកៀរគរភាពជាដៃគូសាធារណៈ និងឯកជន។

ឃ. លើកកម្ពស់ការកសាងផែនការអភិវឌ្ឍន៍ទីក្រុង ដែលធន់នឹងអាកាសធាតុ និងបញ្ចេញកាបូនតិច ព្រមទាំងបង្កើតយន្តការសម្របសម្រួលនៅកម្រិតទីក្រុង (ដូចជា ប្រព័ន្ធដឹកជញ្ជូនសាធារណៈ ដែលមានប្រសិទ្ធភាព ទំនើបកម្មអាងប្រព្រឹត្តកម្ម និងទីលានចាក់សំណល់រឹង នៅរាជធានី ខេត្ត)។

ង. បង្កើតប្រព័ន្ធចុះបញ្ជីគម្រោង និងកម្មវិធីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

ច. បង្កើតប្រព័ន្ធសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ជាតិប្រកបដោយគុណភាព។

**ទិសដៅជាយុទ្ធសាស្ត្រទី ៥ ៖ ពង្រឹងសមត្ថភាព ចំណេះដឹង និងការយល់ដឹងសម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ**

**យុទ្ធសាស្ត្រ**

ក. ជំរុញការអនុវត្តមាត្រាទី៦ នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ស្តីពីការអប់រំ ការបណ្តុះបណ្តាល ការយល់ដឹងជាសាធារណៈ ការចូលរួម និងការទទួលបានព័ត៌មានរបស់មហាជន និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្រោមបរិបទប្រែប្រួលអាកាសធាតុ។

ខ. ពង្រឹងមធ្យោបាយដែលមានស្រាប់ សម្រាប់លើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ តាមរយៈភ្នាក់ងារផ្តល់សេវាកម្ម រាជរដ្ឋាភិបាល គ្រូបង្រៀន អ្នកសារព័ត៌មាន សេវាកម្មផ្សព្វផ្សាយ អ្នកដឹកនាំសាសនា និងអ្នកដឹកនាំសហគមន៍។

គ. រៀបចំកម្មវិធីបង្កើនការយល់ដឹង ដោយផ្តោតលើក្រុមគោលដៅជាក់លាក់ ដូចជាក្រុមពលរដ្ឋ ងាយរងគ្រោះបំផុត ស្ត្រី កុមារ យុវជន និងក្រុមជនជាតិភាគតិច។

ឃ. សម្រួលឱ្យសាធារណជនទទួលបានព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ តាមរយៈ វិទ្យុ ទូរទស្សន៍ សារព័ត៌មាន បច្ចេកវិទ្យាចល័ត វេបសាយ និងសម្ភារៈផ្សព្វផ្សាយសម្រាប់ក្រុមគោលដៅ។

ង. ផ្សព្វផ្សាយដល់វិស័យឯកជន ឱ្យស្វែងយល់អំពីការគំរាមកំហែង និងកាលានុវត្តភាព (ជំនួយបច្ចេកទេស ថវិកា និងការផ្ទេរបច្ចេកវិទ្យា) ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងបង្កើតភាពជាដៃគូសាធារណៈ និងឯកជន សម្រាប់ការប្រាស្រ័យទាក់ទង។

ច. បញ្ចូលប្រធានបទប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីសិក្សានៅគ្រប់កម្រិតសិក្សា។

ឆ. ពង្រឹងគុណភាពអប់រំគ្រូបង្រៀន និងបណ្តុះបណ្តាលអ្នកកសាងផែនការ អំពីវិធីសាស្ត្របង្រៀន និងសិក្សារៀនសូត្រអំពីការប្រែប្រួលអាកាសធាតុ។

ជ. ពង្រឹងសមត្ថភាពក្នុងការប្រមូល វិភាគ ធ្វើម៉ូដែល និងបកស្រាយទិន្នន័យអាកាសធាតុ ហើយផ្សព្វផ្សាយព័ត៌មានអាកាសធាតុដល់អ្នកប្រើប្រាស់ផ្ទាល់ ក្នុងវិស័យនានា ដែលរួមទាំងព្យាករណ៍ប្រចាំរដូវសម្រាប់បន្សាំ និងត្រៀមសម្ភារៈប្រកាសអាសន្នជាមុនរបស់សហគមន៍ ក្នុងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។

ឈ. កែលម្អប្រព័ន្ធព្យាករណ៍ និងពិនិត្យតាមដានធាតុអាកាសរបស់ជាតិ និងកសាងភាពជាដៃគូសម្រាប់បង្កើតម៉ូដែលបង្រួញមាត្រដ្ឋាន អំពីអាកាសធាតុទៅអនាគត។

ញ. បង្កើតប្រព័ន្ធផ្តល់ព័ត៌មានអំពីធាតុអាកាសជាមុន និងកម្មវិធីសម្រាប់គ្រប់គ្រងគ្រោះមហន្តរាយ ដែលទាក់ទងនឹងអាកាសធាតុ និងការស្តារឡើងវិញ។

ដ. ពង្រឹងតួនាទីរបស់សកលវិទ្យាល័យក្នុងការបណ្តុះបណ្តាល ស្រាវជ្រាវ អភិវឌ្ឍបច្ចេកវិទ្យា ដោយកសាងភាពជាដៃគូអន្តរជាតិ លើការស្រាវជ្រាវអំពីអាកាសធាតុ។

ឋ. ប្រើប្រាស់មេរៀនដែលទទួលបាន ចំណេះដឹង និងទម្លាប់ល្អៗនៅមូលដ្ឋាន សម្រាប់កសាងគោលនយោបាយ និងសកម្មភាពបន្ស៊ាំ និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

ឌ. បង្កើត "មជ្ឈមណ្ឌលគ្រប់គ្រងចំណេះដឹង" ដើម្បីសម្រួលដល់ការទទួលបានព័ត៌មានទាន់ហេតុការណ៍ដែលចាំបាច់សម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

## ទិសដៅជាយុទ្ធសាស្ត្រទី ៦ ៖ លើកកម្ពស់ការចូលរួម និងកិច្ចគាំពារសង្គមបែបបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ ដើម្បីកាត់បន្ថយការបាត់បង់ និងខូចខាត

**យុទ្ធសាស្ត្រ**

ក. លើកកម្ពស់មីក្រូហិរញ្ញប្បទាន ដើម្បីបង្កភាពងាយស្រួលដល់សហគមន៍មូលដ្ឋាន ក្នុងការទទួលបានឥណទានសម្រាប់ធ្វើសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

ខ. ជំរុញ និងលើកទឹកចិត្តឱ្យមានប្រព័ន្ធធានារ៉ាប់រង សម្រាប់កាត់បន្ថយបន្ទុកហានិភ័យ និងគ្រោះមហន្តរាយអាកាសធាតុមកលើសង្គម។

គ. ធ្វើសមាហរណកម្មយេនឌ័រទៅក្នុងការកសាងផែនការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

ឃ. ជំរុញដំណើរការវិមជ្ឈការ ដើម្បីពង្រឹងដំណើរការហិរញ្ញវត្ថុ និងស្ថាប័នសម្រាប់ការបន្ស៊ាំនៅមូលដ្ឋាន។

ង. ចាត់ចែងជាលក្ខណៈប្រព័ន្ធសម្រាប់ការចូលរួម និងការពិគ្រោះយោបល់ជាសាធារណៈ ដែលជាចំណុចចាប់ផ្តើមសម្រាប់កសាងផែនការបន្ស៊ាំ ការលើកកម្ពស់ឱ្យអ្នកពាក់ព័ន្ធនានាបានចូលរួម ទាំងអង្គការមិនមែនរដ្ឋាភិបាល អង្គការសហគមន៍ យុវជន សហគមន៍ជនជាតិដើមភាគតិច និងវិស័យឯកជន។

ច. លើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន រួមទាំងការទទួលខុសត្រូវចំពោះសង្គមរបស់ក្រុមហ៊ុនផងដែរ។

**ទិសដៅជាយុទ្ធសាស្ត្រទី ៧ ៖ ពង្រឹងស្ថាប័ន និងក្របខ័ណ្ឌការងារសម្របសម្រួល សម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ**

យុទ្ធសាស្ត្រ

ក. បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងយុទ្ធសាស្ត្រគាំពារសង្គម។

ខ. ពង្រឹងក្របខ័ណ្ឌស្ថាប័នជាតិ និងការសម្របសម្រួលអន្តរក្រសួង នៅក្នុងការកសាងគោលនយោបាយ។

គ. ពង្រឹងតួនាទី និងសមត្ថភាពរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុសម្រាប់សម្របសម្រួលហិរញ្ញប្បទានអាកាសធាតុ និងជាស្ថាប័នជាតិសម្រាប់អនុវត្តហិរញ្ញប្បទានអាកាសធាតុពិភពលោក។

ឃ. បង្កើតក្របខ័ណ្ឌជាតិសម្រាប់ការពិនិត្យតាមដាននិងវាយតម្លៃអំពីការប្រែប្រួលអាកាសធាតុ និងរួមបញ្ចូលក្របខ័ណ្ឌនេះទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏ដូចជាផែនការយុទ្ធសាស្ត្រជាតិគាំពារ សង្គម។

ង. លើកទឹកចិត្តក្រសួងពាក់ព័ន្ធ ឱ្យកសាងយុទ្ធសាស្ត្រ និងផែនការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ និងចូលរួមនៅក្នុងដំណើរការកសាងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា។

**ទិសដៅជាយុទ្ធសាស្ត្រទី ៨ ៖ ពង្រឹងកិច្ចសហការ និងចូលរួមយ៉ាងសកម្ម នៅក្នុងកិច្ចខិតខំប្រឹងប្រែងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់តំបន់ និងពិភពលោក**

យុទ្ធសាស្ត្រ

ក. លើកកម្ពស់កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ ស្តីពីការប្រែប្រួលអាកាសធាតុ នៅក្នុងយន្តការអន្តររដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ៖

- ការអនុវត្តកាតព្វកិច្ចនៅក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- កិច្ចសហប្រតិបត្តិការក្រោមក្របខ័ណ្ឌអាស៊ាន
- កិច្ចសហការត្បូង-ត្បូង និងជើង-ត្បូង
- កិច្ចផ្តួចផ្តើមឆ្លងដែន ដូចជាក្នុងក្របខ័ណ្ឌអាងទន្លេមេគង្គ។ល។
- កិច្ចសហប្រតិបត្តិការតាមរយៈយន្តការអភិវឌ្ឍន៍ស្អាត យន្តការទីផ្សាកាបូន និងយន្តការឥណទានកាបូនពាក់ព័ន្ធនានា។

ខ. ពង្រឹងយន្តការស្ថាប័នជាតិសម្រាប់សម្របសម្រួលការពិគ្រោះយោបល់អំពីជំហរជាតិ និងការឆ្លើយតបទៅនឹងបញ្ហាបច្ចុប្បន្ន និងអនាគត ក្នុងការចរចាជាអន្តរជាតិអំពីការប្រែប្រួលអាកាសធាតុ។

គ. ពង្រឹងជំនាញចរចារបស់កម្ពុជាក្នុងកិច្ចចរចាអន្តរជាតិអំពីការប្រែប្រួលអាកាសធាតុ និងពង្រឹងសមត្ថភាពសម្រាប់អនុវត្តកាតព្វកិច្ចអន្តរជាតិនានា។

ឃ. ចូលរួមយ៉ាងសកម្មជាមួយកិច្ចផ្តួចផ្តើម និងកម្មវិធីនៅថ្នាក់តំបន់ និងកម្រិតពិភពលោក សំដៅរៀនសូត្រពីគ្នាទៅវិញទៅមក និងចែករំលែកជាមួយអន្តរជាតិនូវបទពិសោធរបស់កម្ពុជាអំពីការប្រែប្រួលអាកាសធាតុ។

ង. ធានាឱ្យមានហិរញ្ញប្បទានអាកាសធាតុពីយន្តការផ្តល់មូលនិធិអន្តរជាតិ។

# ៦. សកម្មភាព

ផែនការយុទ្ធសាស្ត្រនេះ ផ្តល់ជាក្របខ័ណ្ឌធំទូលាយមួយ សម្រាប់អនុវត្តវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ ចាំបាច់ត្រូវរៀបចំផែនការសកម្មភាព និងយន្តការពាក់ព័ន្ធនានា ដូចជាយន្តការហិរញ្ញប្បទាន ក្របខ័ណ្ឌត្រួតពិនិត្យ តាមដាន និងវាយតម្លៃ និងក្របខ័ណ្ឌច្បាប់ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនេះ និងផ្តល់ជាមូលដ្ឋានរឹងមាំ សម្រាប់ការកៀរគរធនធាន។

## *៦.១. ដំណាក់កាលសម្រាប់អនុវត្ត ផ.យ.ប.អ.ក.*

ការអនុវត្ត **ផ.យ.ប.អ.ក.** ត្រូវអនុលោមតាមដំណាក់កាលដូចខាងក្រោម ៖

- **នៅក្នុងរយៈពេលខ្លី** (២០១៣–២០១៤) ៖ យន្តការចាត់ចែងស្ថាប័ន និងហិរញ្ញវត្ថុសម្រាប់អនុវត្ត **ផ.យ.ប.អ.ក.** ត្រូវរៀបចំឡើង រួមផ្សំជាមួយក្របខ័ណ្ឌជាតិសម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃ។ នៅក្នុងដំណាក់កាលនេះក្រសួង-ស្ថាប័នពាក់ព័ន្ធនីមួយៗ ត្រូវកសាងផែនការសកម្មភាពលម្អិត និងចាត់អាទិភាព (២០១៤-២០១៨) ដែលរួមមានសកម្មភាពជាក់លាក់មួយ សម្រាប់ការគ្រប់គ្រងចំណេះដឹង និងការងារសម្របសម្រួល។
- **នៅក្នុងរយៈពេលមធ្យម** (២០១៤–២០១៨) ៖ ដំណាក់កាលនេះ នឹងបន្តគាំទ្រដល់ការអនុវត្តសកម្មភាពដូចដែលបានគ្រោងក្នុងដំណាក់កាលទី១ ជាមួយការពង្រីកសកម្មភាពដទៃទៀត ដូចជា ការរៀបចំយន្តការទទួលបានមូលនិធិបន្សាំនិងមូលនិធិអាកាសធាតុបៃតង ការស្រាវជ្រាវ និងការគ្រប់គ្រងចំណេះដឹង ការអភិវឌ្ឍសមត្ថភាព ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅតាមកម្រិតថ្នាក់នៃវិស័យនានា ការប្រតិបត្តិប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃ និងគ្រប់គ្រងទិន្នន័យ និងការចាប់ផ្តើមគម្រោងឬកម្មវិធីនានា ដែលមានអាទិភាពខ្ពស់នៅក្នុងវិស័យសំខាន់ៗ ដូចបានកំណត់នៅក្នុងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ជាដំបូង អាទិភាពត្រូវផ្តោតលើសកម្មភាពបន្សាំ ហើយបន្តិចម្តងៗនឹងគាំទ្រការពង្រីក

សកម្មភាពកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់។ នៅក្នុងដំណាក់កាលនេះ ការបញ្ជ្រាបហិរញ្ញប្បទានប្រែប្រួលអាកាសធាតុទៅក្នុងការកសាងផែនការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការលើកគម្រោងថវិកា និងនីតិវិធីនៃការអនុវត្តនឹងចាប់ផ្តើម និងពង្រីកជាបណ្តើរៗ។ បន្ថែមលើនេះ កម្ពុជានឹងបង្កើតស្ថាប័នសមស្របមួយដែលមានសមត្ថភាពគ្រប់គ្រាន់ និងលក្ខណៈសម្បត្តិពេញលេញ ដែលអាចបានការទទួលស្គាល់ជាផ្លូវការ និងមានសិទ្ធិទទួលយកថវិកាដោយផ្ទាល់ពីមូលនិធិបន្សាំ និងមូលនិធិអាកាសធាតុបៃតង។

- **នៅក្នុងរយៈពេលវែង** (២០១៩ – ២០២៣)៖ ដំណាក់កាលនេះបន្តផ្តោតលើការស្រាវជ្រាវ និងការរៀនសូត្រ ប៉ុន្តែគោលដៅចម្បង គឺការពង្រីកសកម្មភាពជោគជ័យទាំងឡាយ ដែលសម្រេចបានកន្លងមក និងបន្តបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការប្រើប្រាស់មូលនិធិគាំទ្រនឹងកាន់តែកើនច្រើន សម្រាប់កម្មវិធីជាតិ រួមទាំងការផ្តល់មូលនិធិសម្រាប់វិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមរយៈរដ្ឋបាលនៅថ្នាក់ក្រោមជាតិផងដែរ។

ខាងក្រោមនេះមានរៀបរាប់អំពីសកម្មភាពនានា ដែលត្រូវអនុវត្តនៅក្នុងរយៈពេលខ្លី។

**ការចាត់ចែងរចនាសម្ព័ន្ធស្ថាប័ន**

នៅកម្រិតថ្នាក់ជាតិ **គ.ជ.គ.ប.អ.** មានតួនាទីទទួលខុសត្រូវរួម លើការគ្រប់គ្រង និងពិនិត្យតាមដានការអនុវត្ត **ផ.យ.ប.អ.ក.** ដោយមានការគាំទ្របច្ចេកទេសពីក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ និងការគាំទ្រការងារចាត់ចែងរដ្ឋបាលពីលេខាធិការដ្ឋាន **គ.ជ.គ.ប.អ.**។

ជាការចាំបាច់ ត្រូវពិនិត្យកែសម្រួលការរៀបចំ អាណត្តិ និងតួនាទី-ភារកិច្ចនៃស្ថាប័នប្រែប្រួលអាកាសធាតុកម្ពុជានានា សំដៅឆ្លុះបញ្ចាំងលើការទទួលខុសត្រូវជាក់លាក់របស់ខ្លួន ក្នុងការគ្រប់គ្រង និងពិនិត្យតាមដានការអនុវត្ត **ផ.យ.ប.អ.ក.**។ លេខាធិការដ្ឋាន **គ.ជ.គ.ប.អ.** ត្រូវមានឋានៈតាមផ្លូវច្បាប់ ជាស្ថាប័នអន្តរក្រសួងនៅក្រោម **គ.ជ.គ.ប.អ.** ដែលមានតួនាទី និងសិទ្ធិអំណាចពេញលេញ ក្នុងការសម្របសម្រួលការងារអន្តរវិស័យ ហើយមានសមត្ថភាពគ្រប់គ្រាន់ និងលក្ខណៈសម្បត្តិពេញលេញ ដែលអាចបានការទទួលស្គាល់ជាផ្លូវការ និងមានសិទ្ធិទទួលយកថវិកាដោយផ្ទាល់ពីមូលនិធិអាកាសធាតុពិភពលោក។ នីតិវិធីផ្លូវច្បាប់ចាំបាច់នឹងមានចែងលម្អិតនៅក្នុងផែនការសកម្មភាពសម្រាប់មុខងារគ្រប់គ្រងចំណេះដឹង និងការសម្របសម្រួលជាយុទ្ធសាស្ត្រ។

នៅកម្រិតក្រសួង មន្ត្រីបង្គោលប្រែប្រួលអាកាសធាតុ និង/ឬក្រុមការងារត្រូវបានបង្កើតឡើងរួចហើយ។ ការទទួលខុសត្រូវរបស់មន្ត្រីបង្គោលទាំងនេះនិងក្រុមការងារ ត្រូវធ្វើឱ្យច្បាស់លាស់ នាពេលឆាប់ៗខាងមុខ ជាពិសេសទំនាក់ទំនងជាមួយនាយកដ្ឋានផ្សេងទៀតនៅក្នុងក្រសួងពាក់ព័ន្ធ ដើម្បីធានាថាការរៀបចំគោលនយោបាយ កម្មវិធី និងការវិនិយោគតាមវិស័យ បានគិតគូរពេញលេញអំពីហានិភ័យ និងឱកាសនៃការប្រែប្រួលអាកាសធាតុ។

នៅកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ គោលការណ៍ណែនាំអំពីការកសាងផែនការអភិវឌ្ឍន៍នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុនឹងត្រូវដាក់ឱ្យប្រើប្រាស់ នៅខែមិថុនា ឆ្នាំ២០១៤ ក្រោមការដឹកនាំរបស់លេខាធិការដ្ឋាន **គ.ជ.គ.ប.អ.**។ គោលការណ៍ណែនាំទាំងនេះត្រូវផ្អែកលើបទពិសោធជាច្រើន ដែលទទួលបានក្នុងបណ្ដាឆ្នាំកន្លងទៅថ្មីៗនេះ តាមរយៈគម្រោងសាកល្បង ដែលភាគច្រើនមាននៅថ្នាក់ឃុំ។ តាមតែអាចធ្វើបាន គោលការណ៍ណែនាំទាំងនេះនឹងមានរួមបញ្ចូលអនុសាសន៍នានាអំពីកិច្ចសហការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ នៅលំដាប់ខុសៗគ្នា (ខេត្ត/ក្រុង ស្រុក/ខណ្ឌ និងឃុំ/សង្កាត់) និងជាពិសេសនីតិវិធីសម្រាប់ឱ្យឃុំទទួលបានជំនាញបច្ចេកទេសអំពីការប្រែប្រួលអាកាសធាតុ ពីការិយាល័យ ឬមន្ទីរនានានៅថ្នាក់ស្រុក ឬថ្នាក់ខេត្ត។

### ការកសាងផែនការសកម្មភាព

ក្រសួងពាក់ព័ន្ធទាំងអស់ ត្រូវបង្កើតផែនការសកម្មភាពអាទិភាពរបស់ខ្លួន ដោយមានកំណត់ថ្លៃចំណាយសម្រាប់អនុវត្ត **ផ.យ.ប.អ.** តាមវិស័យ ក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីលេខាធិការដ្ឋាន នៃ**គ.ជ.គ.ប.អ.**។ ផែនការសកម្មភាពទាំងនេះ នឹងត្រូវបន្សុីគ្នាយ៉ាងជិតស្និទ្ធ ជាមួយយុទ្ធសាស្ត្ររបស់វិស័យពាក់ព័ន្ធ។ ត្រូវកសាងផែនការសកម្មភាពជាក់លាក់មួយផងដែរ សម្រាប់មុខងារសម្របសម្រួល ដែលរួមទាំងតួនាទីរបស់គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ និងលេខាធិការដ្ឋាននៃ **គ.ជ.គ.ប.អ.**។ គោលការណ៍នាំមុខសម្រាប់ការកសាងផែនការសកម្មភាពទាំងនេះមានចែងនៅក្នុងផ្នែក៦.២ ខាងក្រោម។

### ការបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ

ការផ្ដល់ហិរញ្ញប្បទានសម្រាប់ **ផ.យ.ប.អ.ក.** នឹងប្រព្រឹត្តិទៅ តាមរយៈការប្រើប្រាស់នូវគំរូផ្ដល់មូលនិធិផ្សេងៗគ្នាមួយចំនួន ដោយក្នុងនោះរួមមាន វិធីសាស្ត្រដែលធ្លាប់អនុវត្តកន្លងមក និងវិធីសាស្ត្រថ្មីៗ ដែលទាក់ទងនឹងហិរញ្ញប្បទានអាកាសធាតុ។ ដូច្នេះចាំបាច់ត្រូវជានាឱ្យមានការសម្របសម្រួលនូវគំរូហិរញ្ញប្បទានខុសៗគ្នាទាំងនេះ ដើម្បីឱ្យដៃគូដែលមានសក្ដានុពលក្នុងការផ្ដល់មូលនិធិ អាចយល់បានច្បាស់លាស់អំពីថ្លៃចំណាយ និងការចាត់ជាអាទិភាពនូវសកម្មភាពនានានៅក្រោម **ផ.យ.ប.អ.ក.**។ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ ត្រូវដឹកនាំការបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ ដែលនឹងគាំទ្រដល់របៀបអនុវត្ត ជាកម្មវិធីសម្រាប់ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។

### ការបង្កើតក្របខ័ណ្ឌពិនិត្យ តាមដាន និងវាយតម្លៃ

ក្របខ័ណ្ឌជាតិមួយសម្រាប់ (Monitoring and Evaluation or M&E) កំពុងស្ថិតក្នុងការរៀបចំ ហើយរំពឹងថានឹងត្រូវរៀបចំរួចស្រេច នៅពាក់កណ្ដាលឆ្នាំ២០១៤។ ក្របខ័ណ្ឌនេះត្រូវមានភាពស៊ីសង្វាក់គ្នា និងត្រូវដាក់

បញ្ចូលជាមួយប្រព័ន្ធ M&E របស់ជាតិ។ សេចក្តីពិស្តារបន្ថែមអំពីក្របខ័ណ្ឌ M&E សម្រាប់ផែនការយុទ្ធសាស្ត្រនេះ មានបង្ហាញនៅក្នុងផ្នែកទី៨ ខាងក្រោម។

**ការបង្កើតក្របខ័ណ្ឌច្បាប់ស្តីពីការប្រែប្រួលអាកាសធាតុ**

ក្របខ័ណ្ឌច្បាប់ចាំបាច់មានសារៈសំខាន់ក្នុងការគាំទ្រដល់ការអនុវត្ត **ផ.យ.ប.អ.ក.** តាមរយៈការបញ្ជ្រាបបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយពាក់ព័ន្ធ និងច្បាប់សំខាន់ៗ។ ប្រការនេះនឹងជួយពង្រឹង និងគោរពតាមអនុសាសន៍គោលនយោបាយសំខាន់ៗ ពាក់ព័ន្ធនឹងការឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុ។

## ៦.២. *ការបង្កើតកម្មវិធី និងការកសាងផែនការសកម្មភាព*

ការអនុវត្ត **ផ.យ.ប.អ.ក.** ទាមទារនូវអភិក្រមផ្អែកលើកម្មវិធី ដើម្បីធានាឱ្យមានការសម្របសម្រួលជាយុទ្ធសាស្ត្រ និងការចាត់អាទិភាពនូវសកម្មភាពនានា។ ក្រៅពីការរៀបចំកម្មវិធីដោយផ្អែកលើហានិភ័យ គួរលើកទឹកចិត្តឱ្យមានសកម្មភាពនានា ដែលជំរុញ ឬគាំទ្រដល់ការពង្រឹងបន្ថែមនូវកាលានុវត្តភាពនានា ក៏ដូចជាការពង្រីកអត្ថប្រយោជន៍ និងផលចំណេញបន្ថែមសម្រាប់សង្គម និងប្រព័ន្ធនានា។ សេចក្តីពិស្តារនៃផែនការសកម្មភាពមានចែងនៅក្នុងឯកសារដាច់ដោយឡែក ទៅតាមការកំណត់របស់ទីស្តីការគណៈរដ្ឋមន្ត្រី។ គោលការណ៍ដូចខាងក្រោមនេះនឹងត្រូវយកមកអនុវត្តនៅក្នុងការបង្កើតកម្មវិធី ដែលនឹងត្រូវផ្អែកលើផែនការសកម្មភាពតាមវិស័យ។

**រយៈពេល**

**ផ.យ.ប.អ.ក.** ត្រូវបានរៀបចំឡើងសម្រាប់រយៈពេល១០ ឆ្នាំ (២០១៤-២០២៣) ដោយមានកំណត់កាលបរិច្ឆេទសម្រាប់ការពិនិត្យកែសម្រួលនៅឆ្នាំ២០១៨។ ផែនការសកម្មភាពតាមវិស័យ (និងកម្មវិធីរួមដែលស៊ីគ្នានេះ) នឹងត្រូវរៀបចំឡើងសម្រាប់ដំណាក់កាលដំបូង ដែលមានរយៈពេល៥ ឆ្នាំ (២០១៤-២០១៨) ពោលគឺស្របគ្នាជាមួយវដ្តនៃការកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨)។ ផែនការសកម្មភាពនឹងប្រើប្រាស់វិធីសាស្ត្រសមស្របសម្រាប់ការចាត់អាទិភាព និងការកំណត់ពេលវេលា ដែលក្នុងនោះរួមមាន ការវិភាគ និងការបង្កើតផែនទីភាពងាយរងគ្រោះ និងការវិភាគថ្លៃចំណាយ-ផលចំណេញ។

**ការពង្រឹងបន្ថែមលើយុទ្ធសាស្ត្ររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា**

ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលរួមបញ្ចូលទៅក្នុងកម្មវិធីរបស់ **ផ.យ.ប.អ.ក.** នឹងមិនរៀបចំឡើងជាឯកសារដាច់ដោយឡែក នៅក្នុងក្រសួង ស្ថាប័ននីមួយៗ ឡើយ។ ជាការពិត សកម្មភាពថ្មីមួយចំនួន ដែលផ្តោតលើការប្រែប្រួលអាកាសធាតុ នឹងត្រូវស្នើឡើង ប៉ុន្តែសកម្មភាពភាគច្រើននឹងពាក់ព័ន្ធដោយផ្ទាល់ជាមួយបញ្ជីគម្រោងវិនិយោគសាធារណៈ ដែលមានស្រាប់នៅក្នុងក្រសួង ស្ថាប័ន។ ក្នុងគ្រប់ករណីទាំងអស់ ផែនការសកម្មភាពដែលស្នើឡើង នឹងត្រូវរួមបញ្ចូលនៅក្នុងការចាត់ចែងកសាងផែនការ

និងការគ្រប់គ្រងជាលក្ខណៈស្តង់ដាររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។ ប្រការនេះរួមមានទាំងការគិតគូរពិចារណាអំពីសកម្មភាពនានា ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងដំណើរការលើកថវិកា និងការបង្កើតសូចនាករដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងក្របខ័ណ្ឌ M&E តាមវិស័យ។

**បញ្ហាអន្តរវិស័យ**

ការបង្កើតកម្មវិធីនៅក្រោម **ផ.យ.ប.អ.ក.** ក៏ផ្តោតផងដែរលើបញ្ហាទូទៅ ដែលពាក់ព័ន្ធជាមួយបញ្ហាអន្តរវិស័យ ដូចជាយេនឌ័រ កិច្ចគាំពារសង្គម ការស្រាវជ្រាវ ការលើកកម្ពស់ការយល់ដឹង ការប្រាស្រ័យទាក់ទង M&E ហិរញ្ញប្បទានអាកាសធាតុ និងការគ្រប់គ្រងចំណេះដឹង។

**ការបង្កើតកម្មវិធីចម្រុះ**

ដោយសារការប្រែប្រួលអាកាសធាតុទាក់ទងនឹងវិស័យជាច្រើន ការបង្កើតកម្មវិធីចម្រុះមានសារៈសំខាន់ណាស់ក្នុងការទាញយកប្រយោជន៍ពីវិធីសាស្ត្រនានា ដែលមានលក្ខណៈពហុជំនាញ អន្តរវិស័យ មានអ្នកពាក់ព័ន្ធចម្រុះ និងពហុទិដ្ឋភាព នៅក្នុងសកម្មភាពឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់គួរតែគិតគូរពិចារណាអំពីចំណងទាក់ទងជាមួយវិស័យដទៃទៀត នៅពេលកសាងផែនការសកម្មភាពរបស់ខ្លួន ហើយលេខាធិការដ្ឋាននៃ **គ.ជ.គ.ប.អ.** នឹងផ្តល់ការគាំទ្រ ដើម្បីពិនិត្យមើលចំណងទាក់ទងទាំងនេះ។

**ភាពជាដៃគូ**

ប្រការសំខាន់គឺត្រូវទទួលស្គាល់ថា ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល (ទាំងជាតិ និងអន្តរជាតិ) វិស័យឯកជន សហគមន៍មូលដ្ឋាន និងអង្គការដទៃទៀត គឺជាអ្នកដើរតួយ៉ាងសំខាន់នៅក្នុងការអនុវត្តសកម្មភាពប្រែប្រួលអាកាសធាតុនៅថ្នាក់មូលដ្ឋាន ក៏ដូចជាក្នុងការស្រាវជ្រាវអភិវឌ្ឍន៍ និងការរៀនសូត្រដែលពាក់ព័ន្ធជាមួយការប្រែប្រួលអាកាសធាតុ។ ពិតមែនតែផែនការយុទ្ធសាស្ត្រនេះជាឯកសាររបស់រាជរដ្ឋាភិបាល ដែលផ្តោតលើការប្រើប្រាស់ធនធានសាធារណៈក្តី ក៏ប្រការសំខាន់គឺថាធនធានទាំងនេះនឹងត្រូវប្រើប្រាស់ជាកាតាលីករសម្រាប់ពង្រីកសកម្មភាព និងវិធានការនានាឱ្យកាន់តែធំទូលាយថែមទៀត ពីសំណាក់អ្នកពាក់ព័ន្ធដទៃទៀត ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ក្នុងន័យនេះ គួរលើកទឹកចិត្តឱ្យស្ថាប័នរាជរដ្ឋាភិបាលទាក់ទាញដៃគូពាក់ព័ន្ធនានាឱ្យមកចូលរួមនៅក្នុងការកសាងផែនការសកម្មភាព និងកំណត់ភាពជាដៃគូនៅក្នុងការអនុវត្តផែនការសកម្មភាពរបស់ខ្លួន។

# ៧. ការផ្តល់ធនធានហិរញ្ញវត្ថុ

## *៧.១. គោលការណ៍នានា*

**ផ.យ.ប.អ.ក.** រួមជាមួយផែនការសកម្មភាពពាក់ព័ន្ធនានា នឹងផ្តល់ជាក្របខ័ណ្ឌយុទ្ធសាស្ត្រមួយ សម្រាប់ការបង្កើតកម្មវិធីអន្តរាគមន៍លើបញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជា។ យន្តការហិរញ្ញប្បទានប្រែប្រួលអាកាសធាតុរបស់ជាតិត្រូវគាំទ្រវិធីសាស្ត្រជាយុទ្ធសាស្ត្រនេះ តាមរយៈការអនុវត្តគោលការណ៍នានាដូចតទៅ ៖

- **ការបន្ស៊ីគ្នាជាមួយអាទិភាពជាតិ ៖** ការប្រើប្រាស់ធនធានហិរញ្ញវត្ថុ ត្រូវតែឆ្លើយតបទៅនឹងអាទិភាពរបស់ជាតិ តាមរយៈការផ្តល់មូលនិធិសម្រាប់កម្មវិធី និងគម្រោងនានា ដែលមានចែងនៅក្នុងផែនការសកម្មភាពនៅក្រោម **ផ.យ.ប.អ.ក.**។ រាល់សំណើហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ ត្រូវតែដាក់ជូនគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុពិនិត្យ និងសម្រេច។
- **ការប្រមូលផ្តុំធនធាន ៖** ដើម្បីកាត់បន្ថយថ្លៃចំណាយប្រតិបត្តិការ និងនៅក្នុងករណីដែលអាចធ្វើបាន គួរផ្តល់ហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុតាមរយៈយន្តការផ្តល់មូលនិធិរួមគ្នា។ យន្តការទាំងនេះរួមមានរាល់យន្តការប្រមូលផ្តុំធនធានដែលមានស្រាប់នៅក្នុងវិស័យពាក់ព័ន្ធ និងអាចជាមូលនិធិដែលផ្តោតលើការប្រែប្រួលអាកាសធាតុដាច់ដោយឡែក។
- **ការប្រើប្រាស់ប្រព័ន្ធ និងនីតិវិធីរបស់ជាតិ ៖** គំរូដែលរាជរដ្ឋាភិបាលកម្ពុជាចង់បានសម្រាប់ការផ្តល់ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ នៅក្នុងរយៈពេលមធ្យម ទៅរយៈពេលវែង គឺការគាំទ្រថវិកាដោយផ្ទាល់។ ទោះជាយ៉ាងណាក៏ដោយ ការប្រែប្រួលអាកាសធាតុ គឺជាកិច្ចការថ្មីមួយ ដែលចាំបាច់ត្រូវមានអន្តរកាល ដើម្បីដាក់ឱ្យអនុវត្តប្រព័ន្ធពិនិត្យតាមដានវាយតម្លៃ និងកត់ត្រាហិរញ្ញវត្ថុ ដើម្បីអាចឱ្យគេវាយតម្លៃអំពីផលប៉ះពាល់ និងប្រសិទ្ធភាពនៃការគាំទ្រថវិកាសម្រាប់ការងារប្រែប្រួលអាកាសធាតុ។ មូលនិធិជាតិប្រែប្រួលអាកាសធាតុមួយអាចនឹងត្រូវបង្កើតឡើង ដើម្បីទទួលការគាំទ្រហិរញ្ញវត្ថុពីក្នុង និងក្រៅប្រទេស ហើយវិភាជន៍មូលនិធិនេះទៅគម្រោងប្រែប្រួលអាកាសធាតុដែលមានអាទិភាពខ្ពស់។
- **ការផ្ទេរអំណាចទៅថ្នាក់ក្រោម ៖** ទោះបីការប្រែប្រួលអាកាសធាតុ ត្រូវការសម្របសម្រួលពី **គ.ជ.គ.ប.អ.** ដើម្បីបន្ស៊ីជាមួយអាទិភាពនានារបស់ជាតិក៏ដោយ យន្តការហិរញ្ញប្បទានត្រូវតែធានាថា ធនធានថវិកាត្រូវស្ថិតនៅក្រោមការចាត់ចែងរបស់ក្រសួងពាក់ព័ន្ធ និងរដ្ឋបាលមូលដ្ឋានដែលពាក់ព័ន្ធ។ លេខាធិការដ្ឋាននៃ **គ.ជ.គ.ប.អ.** ត្រូវដើរតួជាស្ថាប័នអនុវត្តសម្រាប់តែគម្រោងយុទ្ធសាស្ត្រ ឬដែលមានលក្ខណៈអន្តរវិស័យ ដែលមិនស្ថិតនៅក្រោមអាណត្តិរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធណាមួយផ្សេង ឬរដ្ឋបាលថ្នាក់ក្រោមជាតិឡើយ។

## ៧.២. វិធីសាស្ត្រ

ការបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុសម្រាប់កម្ពុជា ត្រូវប្រព្រឹត្តិទៅតាមរយៈដំហានមួយចំនួន។ ការពិនិត្យការចំណាយសាធារណៈ និងស្ថាប័នលើការងារអាកាសធាតុ (Climate Public Expenditure and Institutional Review or CPEIR) បានធ្វើឡើងនៅឆ្នាំ២០១២ និងបានផ្តល់ព័ត៌មានដំបូងអំពីស្ថានភាពបច្ចុប្បន្ននៃការចំណាយសម្រាប់ការងារប្រែប្រួលអាកាសធាតុនៅកម្ពុជា និងការប្រឈមនានាខាងសមត្ថភាព ដែលពាក់ព័ន្ធ។

របាយការណ៍ CPEIR បានប៉ាន់ស្មានថា នៅក្នុងអំឡុងឆ្នាំ២០០៩-២០១១ ការចំណាយសាធារណៈជាមធ្យម១៥,៨% មានការពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។ នេះជាកម្រិតខ្ពស់បង្គួរមួយ ធៀបនឹងប្រទេសដទៃទៀតក្នុងតំបន់។ ហិរញ្ញប្បទានអាកាសធាតុ គួរតែផ្តោតមិនត្រឹមតែលើការទាក់ទាញធនធានថ្មីៗប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវផ្តោតផងដែរលើការកែលម្អភាពផ្តល់ផល និងប្រសិទ្ធភាពនៃការចំណាយជាច្រើនរួចមកហើយ ដែលទាក់ទងជាមួយការប្រែប្រួលអាកាសធាតុ។ មូលនិធិដែលមានស្រាប់ទាំងនេះមិនសុទ្ធតែបានសម្របសម្រួលល្អនោះទេ ដោយសារមូលនិធិភាគច្រើនបានមកតាមរយៈគម្រោងក្នុងវិស័យដាក់លាក់ (៦០%) ហើយអន្តរាគមន៍នៃគម្រោងទាំងនោះពុំបានទទួលការវាយតម្លៃជាលក្ខណៈប្រព័ន្ធដោយផ្អែកលើទស្សនទាននៃការប្រែប្រួលអាកាសធាតុឡើយ។ ការផ្តល់មូលនិធិលើការងារប្រែប្រួលអាកាសធាតុ ដែលបានមកពីម្ចាស់ជំនួយទ្វេភាគី ពហុភាគី ឬតាមរយៈមូលនិធិអាកាសធាតុពិភពលោក មានត្រឹមតែ៤០% នៃតួលេខសរុបប៉ុណ្ណោះ។ នៅក្នុងបណ្តាឆ្នាំខាងមុខនេះ មានការរំពឹងថា ភាគចំណែកនៃហិរញ្ញប្បទានដែលផ្តោតលើការងារប្រែប្រួលអាកាសធាតុ នឹងកើនឡើងថែមទៀត។ នេះជាឱកាសមួយសម្រាប់កម្ពុជា ដោយហេតុថា ជាគោលការណ៍ មូលនិធិទាំងនេះអាចត្រូវបានវិភាជន៍សម្រាប់វិស័យ និងកម្មវិធីអាទិភាព ដូចមានចែងនៅក្នុង **ផ.យ.ប.អ.ក.**។ គម្រោងខ្លះនឹងបន្តទទួលមូលនិធិ តាមរយៈរបៀបដូចធ្លាប់អនុវត្តពីមុនមក ប៉ុន្តែយន្តការប្រមូលផ្តុំអាចដាក់ឱ្យអនុវត្ត ដើម្បីផ្តល់មូលនិធិសម្រាប់គម្រោងដែលមានការពាក់ព័ន្ធខ្លាំង (រួមទាំងការអភិវឌ្ឍសមត្ថភាពស្ថាប័នលើការប្រែប្រួលអាកាសធាតុផងដែរ) ការបំពេញបន្ថែមលើគម្រោងកំពុងដំណើរការដែលទាមទារឱ្យមានលក្ខខណ្ឌនៃភាពធន់នឹងអាកាសធាតុ និងបន្តអនុវត្តសាកល្បងវិធីសាស្ត្របែបច្នៃប្រឌិតមួយចំនួននៅក្នុងការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

បច្ចុប្បន្ន ការចំណាយសាធារណៈតាមរយៈរដ្ឋបាលនៅថ្នាក់ក្រោមជាតិនៅតែមានចំនួនតិចតួចនៅឡើយ (៥ ទៅ៦% នៃការចំណាយសរុបរបស់រដ្ឋ) ប៉ុន្តែមានសារៈសំខាន់ណាស់សម្រាប់កិច្ចផ្តួចផ្តើមបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដែលទាមទារឱ្យផ្តល់ការគាំទ្រ ដើម្បីមានភាពធន់នឹងអាកាសធាតុប្រសើរជាងមុននៅកម្រិតសហគមន៍។ យន្តការហិរញ្ញប្បទានទៅអនាគត គួរតែរួមបញ្ចូលនីតិវិធី និងបរិធានសមស្រប ដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុ នៅក្នុងការកសាងផែនការ និងថវិកានៅថ្នាក់ក្រោមជាតិ។

ប្រការសំខាន់ គឺត្រូវធ្វើការពិនិត្យតាមដានទៀងទាត់អំពីការវិវត្តនៃការចំណាយលើការប្រែប្រួលអាកាសធាតុ និងការគាំទ្ររបស់ការចំណាយទាំងនោះលើអាទិភាពនៅក្នុង **ផ.យ.ប.អ.ក.** និង **ផ.យ.អ.ជ.** ក៏ដូចជាភាពផ្តល់ផល និងប្រសិទ្ធភាពនៃការចំណាយទាំងនោះផងដែរ។ ត្រូវឱ្យមានការពិនិត្យជាទៀងទាត់ ដើម្បីធ្វើបច្ចុប្បន្នភាពព័ត៌មាននៅក្នុងរបាយការណ៍ CPEIR ហើយយន្តការនានាដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការថវិកាជាតិ ក៏នឹងត្រូវបង្កើតឡើងផងដែរ។

នៅឆ្នាំ២០១៤ សកម្មភាពនានាដូចខាងក្រោមនេះ នឹងត្រូវអនុវត្ត ដើម្បីដាក់ឱ្យប្រើប្រាស់ក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ ដែលមានភាពទាក់ទាញ និងប្រសិទ្ធភាពសម្រាប់កម្ពុជា ៖

- ការវិភាគឱកាសសម្រាប់កៀរគរធនធាន (ក្នុង និងក្រៅស្រុក) ទាំងនៅថ្នាក់ជាតិ និងក្នុងវិស័យអាទិភាព។
- ការកំណត់ថវិកា សម្រាប់អនុវត្ត **ផ.យ.ប.អ.ក.** និង **ផ.យ.ប.អ.** តាមវិស័យ ដោយមានការចាត់អាទិភាពសម្រាប់គម្រោង ដែលមានការពាក់ព័ន្ធកម្រិតខ្ពស់។
- ការកំណត់ថ្លៃខូចខាតពីផលប៉ះពាល់សេដ្ឋកិច្ច-សង្គមនៃការមិនធ្វើសកម្មភាព និងផលចំណេញសុទ្ធ ពីការឆ្លើយតប ក្រោមសេណារីយ៉ូផ្សេងៗ ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់កំណត់អាទិភាពចំណាយក្នុងវិស័យ ឬវិស័យរងនីមួយៗ។
- ការវិភាគទម្លាប់ប្រតិបត្តិល្អរបស់ជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធនៅក្នុងការចាត់ចែងគ្រប់គ្រងមូលនិធិប្រមូលផ្តុំ និងអនុសាសន៍អំពីរចនាសម្ព័ន្ធដែលបានស្នើឡើង សម្រាប់យន្តការហិរញ្ញវត្ថុអាកាសធាតុនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- ការវិភាគភាពខ្វះចន្លោះនៃសមត្ថភាព និងអនុសាសន៍ ដើម្បីអភិវឌ្ឍសមត្ថភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅគ្រប់គ្រងយន្តការហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុដែលបានស្នើឡើង។ ការវិភាគនេះក៏ត្រូវមានអនុសាសន៍សម្រាប់ការងារបន្ថែម ដើម្បីពិនិត្យលទ្ធភាពក្នុងការកៀរគរហិរញ្ញវត្ថុ ពីវិស័យឯកជនផងដែរ សម្រាប់សកម្មភាពបន្សាំ និងកាត់បន្ថយការបញ្ចេញឧស្ម័ន។

សកម្មភាពទាំងនេះនឹងនាំទៅរកការបង្កើតក្របខ័ណ្ឌកម្មវិធីមួយ ដែលផ្អែកលើផែនការសកម្មភាពនៅក្នុងវិស័យជាអាទិភាព និងបន្សុីគ្នាជាមួយ **ផ.យ.អ.ជ.** ២០១៤-២០១៨។

### *៧.៣. ការគ្រប់គ្រង និងរចនាសម្ព័ន្ធស្ថាប័នសម្រាប់ការអនុវត្ត*

អនុក្រុមហិរញ្ញវត្ថុអាកាសធាតុ នៃក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ មានសមាសភាពមកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងបរិស្ថាន ក្រសួងផែនការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គណៈកម្មាធិការស្តារ និងអភិវឌ្ឍន៍កម្ពុជា) និងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅ

ថ្នាក់ក្រោមជាតិ។ អនុក្រុមនេះត្រូវដឹកនាំការបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុរបស់ជាតិ ដើម្បីដាក់ជូនទៅ **គ.ជ.គ.ប.អ.** នៅឆ្នាំ២០១៤។

នៅខណៈដែលពុំទាន់បានកំណត់យន្តការហិរញ្ញប្បទានជាក់លាក់ ជាការចាំបាច់ត្រូវសម្របសម្រួល និងបន្សុីគ្នាជាមួយ **ផ.យ.ប.អ.ក.** នូវហិរញ្ញវត្ថុក្នុងស្រុក និងប្រភពហិរញ្ញវត្ថុអាកាសធាតុក្រៅស្រុកចម្បងៗ ចំនួន៣ (មូលនិធិអាកាសធាតុពិភពលោក មូលនិធិអាកាសធាតុទ្វេភាគី និងគម្រោងតាមវិស័យដែលបានដាក់បញ្ចូលសកម្មភាពប្រែប្រួលអាកាសធាតុ)។ ការសម្របសម្រួលរវាងគម្រោង "ពីថ្នាក់លើ" និងយន្តការមូលនិធិប្រមូលផ្តុំក៏ជាតម្រូវការចាំបាច់ផងដែរ។

អនុលោមតាមគោលនយោបាយរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គណៈកម្មាធិការស្តារ និងអភិវឌ្ឍន៍កម្ពុជា) រាជរដ្ឋាភិបាលចង់ឱ្យប្រើ អភិក្រមផ្អែកលើកម្មវិធី (Programme-based approach or PBA) ដើម្បីគ្រប់គ្រងគំរូខុសៗគ្នាទាំងនេះ។ **គ.ជ.គ.ប.អ.** នឹងដាក់ឱ្យប្រើប្រាស់រចនាសម្ព័ន្ធសមស្រប ដើម្បីគ្រប់គ្រងអភិក្រមផ្អែកលើកម្មវិធី សម្រាប់ការងារប្រែប្រួលអាកាសធាតុ ដែលរួមទាំងរចនាសម្ព័ន្ធមួយ សម្រាប់ការពិភាក្សា និងការសម្របសម្រួលជាមួយម្ចាស់ជំនួយផងដែរ។ អភិក្រមផ្អែកលើកម្មវិធីនេះនឹងជួយសម្រួលការអនុវត្តគំរូហិរញ្ញប្បទានផ្សេងៗគ្នា ហើយវាផ្តល់ចំណុចចាប់ផ្តើម និងក្របខ័ណ្ឌឯកភាពមួយ សម្រាប់ការងារកសាងផែនការ និងប្រព័ន្ធ M&E សម្រាប់អន្តរាគមន៍នានា ទាក់ទងនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ លេខាធិការដ្ឋាននៃ **គ.ជ.គ.ប.អ.** ត្រូវដើរ តួជាលេខាធិការដ្ឋានសម្រាប់អនុវត្តអភិក្រមផ្អែកលើកម្មវិធីនេះ។ ការបង្កើតយន្តការទាំងនេះទាមទារឱ្យមានការរៀបចំផែនការអភិវឌ្ឍន៍សមត្ថភាពប្រកបដោយការសម្របសម្រួលរវាងគ្នា។

## ៨. ការពិនិត្យតាមដាន និងវាយតម្លៃ

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើប្រព័ន្ធអេកូឡូស៊ី និងសង្គម មានលក្ខណៈស្មុគស្មាញ។ ការដោះស្រាយបញ្ហាទាំងនេះតាមរយៈការបន្សាំ ទាមទារឱ្យមានវិធានការបន្សាំប្រកបដោយការសម្របសម្រួលរវាងវិស័យជាច្រើន និងតាមមាត្រដ្ឋានខុសៗគ្នា។ ការបង្កើតលំនាំអភិវឌ្ឍន៍ដែលបញ្ចេញកាបូនតិច និងការរួមចំណែកក្នុងកិច្ចប្រឹងប្រែងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ទាមទារបច្ចេកវិទ្យាថ្មីៗ និងគោលនយោបាយអន្តរវិស័យ។ ដោយសារភាពស្មុគស្មាញនៃសកម្មភាពទាំងនេះ និងបញ្ហាបច្ចេកទេសដែលពាក់ព័ន្ធនឹងការវាយតម្លៃប្រសិទ្ធភាព និងផលប៉ះពាល់នានា នោះការពិនិត្យតាមដាននិងវាយតម្លៃ លើការកាត់បន្ថយការបញ្ចេញឧស្ម័ន និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ គឺជាការប្រឈមថ្មីមួយ។ **ផ.យ.ប.អ.ក.** ទទួលស្គាល់ពីសារៈសំខាន់នៃការដោះស្រាយបញ្ហាប្រឈមទាំងនេះ តាមរយៈការបង្កើតក្របខ័ណ្ឌជាតិមួយសម្រាប់ M&E លើការងារប្រែប្រួលអាកាសធាតុ ដោយមានចក្ខុវិស័យក្នុងការរួមបញ្ចូលក្របខ័ណ្ឌនេះ ទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍នៅថ្នាក់ជាតិ និង

ថ្នាក់ក្រោមជាតិ។ ការកសាង និងបញ្ជ្រាបក្របខ័ណ្ឌ M&E គឺជាកិច្ចប្រឹងប្រែងរយៈពេលវែងមួយ ដែលមានសារៈសំខាន់ជាយុទ្ធសាស្ត្រ ពីព្រោះថាវានឹងបង្កើតលក្ខខណ្ឌអំណោយផល ដោយផ្អែកលើគណនេយ្យភាព និងការរៀនសូត្រ។ គណនេយ្យភាពល្អជាងមុននឹងសម្រួលដល់ការទទួលបានហិរញ្ញវត្ថុអាកាសធាតុអន្តរជាតិថ្មីៗ ហើយការរៀនសូត្រពីការវិនិយោគនានានឹងបង្កើតចំណេះដឹងថ្មីៗ ដែលមានសារៈសំខាន់សម្រាប់ការកសាងគោលនយោបាយទៅអនាគត។ ក្របខ័ណ្ឌជាតិសម្រាប់ M&E លើការប្រែប្រួលអាកាសធាតុមានបំណង ៖

- វាស់ស្ទង់ថា តើប្រសិទ្ធភាពនៃកិច្ចប្រឹងប្រែងក្នុងការងារបន្សុំានឹងការប្រែប្រួលអាកាសធាតុមានកម្រិតណាក្នុងការធានាឱ្យការអភិវឌ្ឍស្ថិតក្នុងលំនាំត្រូវ នៅក្នុងលក្ខខណ្ឌអាកាសធាតុដែលប្រែប្រួល។
- ពិនិត្យតាមដានសកម្មភាពកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងគោលនយោបាយអភិវឌ្ឍន៍ដែលបញ្ចេញកាបូនតិច។
- ចងក្រងភស្តុតាង និងមេរៀននានា ដើម្បីជាមូលដ្ឋានសម្រាប់ការកសាងគោលនយោបាយទៅអនាគត។
- សម្រួលឱ្យមានសមាហរណកម្មស៊ីសង្វាក់គ្នានៃ M&E លើការប្រែប្រួលអាកាសធាតុនៅក្នុងការកសាងផែនការអភិវឌ្ឍន៍ជាតិ និងវិស័យសំខាន់ៗ។
- ផ្តល់ព័ត៌មានដែលចាំបាច់ ក្នុងការបំពេញកាតព្វកិច្ចធ្វើរបាយការណ៍ ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងដៃគូអភិវឌ្ឍន៍។

## *៨.១. គោលការណ៍នានា*

គោលការណ៍នានាដែលអាចពង្រឹងក្របខ័ណ្ឌនេះ រួមមាន ៖

- **ការប្រើប្រាស់ប្រព័ន្ធ និងនីតិវិធីរបស់ជាតិ ៖** ក្របខ័ណ្ឌនេះនឹងរួមបញ្ចូលជាមួយប្រព័ន្ធ M&E របស់ជាតិ។ សូចនាករ និងនីតិវិធីពិនិត្យតាមដាន ត្រូវពឹងផ្អែកឱ្យបានច្រើនបំផុតលើទិន្នន័យ ដែលបច្ចុប្បន្ននេះស្ថិតក្រោមការពិនិត្យតាមដានដោយក្រសួងពាក់ព័ន្ធ។ សូចនាករ និងនីតិវិធីទាំងនេះ ត្រូវតែមានសង្គតិភាពជាមួយគោលការណ៍ណែនាំរបស់ក្រសួងផែនការ អំពីប្រព័ន្ធ M&E របស់ជាតិផងដែរ។ ក្របខ័ណ្ឌនេះនឹងចាត់ជាប្រព័ន្ធ និងពង្រឹងបន្ថែមលើកិច្ចផ្តួចផ្តើម ដែលកំពុងអនុវត្តសម្រាប់ការពិនិត្យតាមដាន និងរាយការណ៍អំពីការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។
- **ការបញ្ជ្រាប M&E ការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍នៅថ្នាក់ជាតិ ថ្នាក់វិស័យ និងថ្នាក់ក្រោមជាតិ ៖** ការប្រែប្រួលអាកាសធាតុអាចធ្វើឱ្យខូចខាតសមិទ្ធិផលនៃចំណុចដៅអភិវឌ្ឍន៍ ដែលមានចែងនៅក្នុង **ផ.យ.អ.ជ.** និងយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ។ នីតិវិធី និងសូចនាករនានា សម្រាប់តាមដានវិធានការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ត្រូវរួមបញ្ចូលទៅក្នុងប្រព័ន្ធ M&E របស់ជាតិ និងត្រូវ

ប្រើជាឯកសារយោង សម្រាប់តាមដានប្រសិទ្ធភាពនៃយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ និងផែនការសកម្មភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

- **ការពង្រឹងគណនេយ្យភាព សមធម៌ និងតម្លាភាព ៖** ក្របខ័ណ្ឌនេះនឹងផ្តល់ជាវិធីមួយ សម្រាប់វាស់ប្រសិទ្ធភាព និងភាពផ្តល់ផលនៃធនធានដែលប្រើប្រាស់ ដើម្បីសម្រេចតាមចំណុចដៅនានា ដូចមានចែងក្នុងគោលនយោបាយ និងផែនការសកម្មភាព ហើយនឹងកែលម្អគណនេយ្យភាព ចំពោះមុខសាធារណជន ស្ថាប័នរដ្ឋ សង្គមស៊ីវិល និងម្ចាស់ជំនួយអន្តរជាតិ។
- **លើកកម្ពស់ការរៀនសូត្រដោយមានការចូលរួម ៖** ការកសាងគោលនយោបាយឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ គឺជាកិច្ចប្រឹងប្រែងថ្មីមួយនៅកម្ពុជា និងលើពិភពលោក។ ការបង្ហាញភស្តុតាងច្បាស់លាស់ថាគោលនយោបាយ និងវិធានការនានាមានប្រសិទ្ធភាព មានសារៈសំខាន់ណាស់សម្រាប់ជាមូលដ្ឋានក្នុងការកសាងគោលនយោបាយទៅអនាគត។ ដូច្នេះក្របខ័ណ្ឌនេះនឹងផ្តោតលើការបង្កើតចំណេះដឹង តាមរយៈវិធីសាស្ត្រដែលមានការចូលរួម ហើយគាំទ្រដល់ការកំណត់រក និងចែករំលែកចំណេះដឹង។
- **ដំណោះស្រាយបញ្ហាយេនឌ័រ ៖** ស្ត្រី និងក្រុមអ្នកទន់ខ្សោយ ច្រើនតែស្ថិតក្នុងចំណោមអ្នកដែលរងឥទ្ធិពលធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ។ ក្របខ័ណ្ឌនេះនឹងដោះស្រាយបញ្ហាសមធម៌យេនឌ័រ ការប្រតិបត្តិដែលគិតគូរអំពីយេនឌ័រ នៅក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងការបញ្ជ្រាបយេនឌ័រនៅក្នុងវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

## *៨.២. វិធីសាស្ត្រ*

ក្របខ័ណ្ឌអាកាសធាតុរបស់ជាតិសម្រាប់ M&E លើវិធានការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនឹងត្រូវរៀបចំឡើង ដោយយោងទៅទម្លាប់ប្រតិបត្តិល្អអន្តរជាតិ។ ឯកសារគោលគំនិតមួយនឹងត្រូវរៀបចំឡើង ដើម្បីគណនា និងកៀរគរធនធានចាំបាច់ សម្រាប់រៀបចំក្របខ័ណ្ឌនេះឱ្យបានឆាប់រហ័ស។ ក្របខ័ណ្ឌនេះនឹងត្រូវរៀបចំរួចរាល់នៅឆ្នាំ២០១៤ ហើយមានរៀបរាប់អំពី ៖ ទ្រឹស្តីនៃការប្រែប្រួល, ក្របខ័ណ្ឌសូចនាករ ជាមួយស្ថានភាពគោល និងចំណុចដៅសម្រាប់តាមដាន **ផ.យ.ប.អ.ក.** និងផែនការសកម្មភាពដែលពាក់ព័ន្ធ, នីតិវិធីសម្រាប់ការប្រមូលទិន្នន័យ, គោលការណ៍ណែនាំសម្រាប់វិភាគនិងរាយការណ៍, គោលការណ៍ណែនាំសម្រាប់រួមបញ្ចូលការគ្រប់គ្រងចំណេះដឹង, ការរៀនសូត្រនិងចែករំលែកលទ្ធផល, គោលការណ៍ណែនាំសម្រាប់រួមបញ្ចូលនៅក្នុងប្រព័ន្ធ M&E របស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា, រចនាសម្ព័ន្ធស្ថាប័នលម្អិត និងយន្តការសម្របសម្រួល។

ក្របខ័ណ្ឌសូចនាករនេះនឹងមាន២ ជំពូក សម្រាប់វាស់ស្ទង់វិធានការឆ្លើយតបខាងស្ថាប័នគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងគុណផលនៃការអភិវឌ្ឍនៅក្នុងលក្ខខណ្ឌនៃការប្រែប្រួលអាកាសធាតុ។

- **សូចនាករដើមខ្សែ** ដែលតាមដានប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យអាកាសធាតុ ៖ រាប់បញ្ចូលសូចនាករនានា ដែលទាក់ទងនឹងក្របខ័ណ្ឌស្ថាប័ន ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅក្នុងគោលនយោបាយ និងដំណើរការកសាងផែនការ ហិរញ្ញប្បទានអាកាសធាតុ សមត្ថភាពស្ថាប័ន សមធម៌ តម្លាភាព និងការចូលរួមរបស់អ្នកពាក់ព័ន្ធនានានិងវិស័យឯកជន។
- **សូចនាករចុងខ្សែ** ដែលតាមដានការប្រែប្រួលនៃស្ថានភាពអភិវឌ្ឍន៍ការបញ្ចេញឧស្ម័ន និងភាពងាយរងគ្រោះនៃសហគមន៍ និងប្រព័ន្ធអេកូឡូស៊ីពីការប្រែប្រួលអាកាសធាតុ។ សូចនាករទាំងនេះត្រូវដាក់បញ្ចូលនូវស្ថិតិអភិវឌ្ឍន៍ជាតិ ក៏ដូចជាសូចនាកររួមបញ្ចូលពីវិស័យនានា និងពីគម្រោងបន្សុំនិងកាត់បន្ថយ ដោយឡែក។ លទ្ធផលការងារនឹងត្រូវយកមកវាយតម្លៃស្របជាមួយនិន្នាការអាកាសធាតុ និងព្រឹត្តិការណ៍អាកាសធាតុមិនប្រក្រតី។

សូចនាករនានាសម្រាប់ការដាក់បញ្ចូលទៅក្នុង **ផ.យ.អ.ជ.** ក៏ត្រូវតែកំណត់ផងដែរ។ ផែនការមួយនឹងត្រូវរៀបចំឡើង ដែលចែងអំពីសកម្មភាពនានា ការអភិវឌ្ឍសមត្ថភាព និងការកំណត់ថ្លៃចំណាយសម្រាប់ការអនុវត្តរយៈពេលវែង និងការបញ្ជ្រាបក្របខ័ណ្ឌនេះនៅក្នុងក្រសួងពាក់ព័ន្ធ។

នៅក្នុងរយៈពេលមធ្យម (២០១៤-២០១៨) ក្របខ័ណ្ឌនេះនឹងត្រូវដាក់ឱ្យក្រសួងពាក់ព័ន្ធ និងគម្រោងនានា យកទៅអនុវត្តនៅតាមវិស័យជាអាទិភាព ដែលការជ្រើសរើសនេះនឹងធ្វើឡើង អាស្រ័យលើសមត្ថភាព និងធនធានដែលមាន។ ការធ្វើសមាហរណកម្ម M&E នៅក្នុងផែនការថ្នាក់មូលដ្ឋានក៏នឹងត្រូវអនុវត្តសាកល្បងផងដែរ។ ធនធានគ្រប់គ្រាន់នឹងត្រូវផ្តល់នៅក្នុងដំណាក់កាលចាប់ផ្តើម សម្រាប់គម្រោងជ្រើសរើសមួយចំនួន ដើម្បីបំពេញការចំណាយបន្ថែមលើសមត្ថភាពបច្ចេកទេសជំនាញក្នុង M&E ការងារប្រែប្រួលអាកាសធាតុ ការប្រមូលទិន្នន័យគោល ការបង្កើតទ្រឹស្តីអំពីការប្រែប្រួល ការរៀនសូត្រ និងការគ្រប់គ្រងចំណេះដឹង។

នៅក្នុងដំណាក់កាលនេះ បណ្តាញការងារមួយនៃទីតាំងនានាសម្រាប់ការពិនិត្យតាមដានរយៈពេលវែង នឹងត្រូវបង្កើតឡើង សម្រាប់វាយតម្លៃប្រសិទ្ធភាព និងនិរន្តរភាពនៃវិធានការបន្សុំ និងកាត់បន្ថយការបញ្ចេញឧស្ម័នដែលអនុវត្តតាមរយៈគម្រោងសាកល្បង។ ទីតាំងទាំងនោះនឹងត្រូវកំណត់យកនៅក្នុងតំបន់ងាយរងគ្រោះខ្លាំង ដូចជា ប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ និងក្នុងទីតាំងនានា ដែលអន្តរាគមន៍សាកល្បងបានបង្ហាញលទ្ធផលជាទីពេញចិត្ត។ ប្រព័ន្ធនេះនឹងបង្កើតភស្តុតាង ដែលនឹងត្រូវរក្សាទុក នៅក្នុងកម្រងទិន្នន័យជាតិ ស្តីពីវិធាននិងបច្ចេកវិទ្យានានា ដែលនឹងត្រូវគ្រប់គ្រងដោយលេខាធិការដ្ឋាននៃ **គ.ជ.គ.ប.អ.** ក្រោមការសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍។

នៅក្នុងរយៈពេលវែង (២០១៩ - ២០២៤) ក្របខ័ណ្ឌនេះនឹងត្រូវកែសម្រួល ដោយផ្អែកលើមេរៀន ដែលកើតចេញពីដំណាក់កាលសាកល្បង ហើយត្រូវបញ្ជ្រាបទៅក្នុងក្រសួងពាក់ព័ន្ធ ដែលនៅសេសសល់ និងក្នុងការកសាងផែនការថ្នាក់ក្រោមជាតិ និងនៅតាមមូលដ្ឋាន។

## *៨.៣. ការគ្រប់គ្រង និងរចនាសម្ព័ន្ធស្ថាប័នសម្រាប់ការអនុវត្ត*

លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ត្រូវដើរតួជាលេខាធិការដ្ឋានសម្រាប់សម្របសម្រួលការបង្កើត និងការអនុវត្តក្របខ័ណ្ឌនេះ។ លេខាធិការដ្ឋាននេះក៏មានភារៈទទួលខុសត្រូវលើការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំសម្រាប់ **ផ.យ.ប.អ.ក.** ក្រោមការសម្របសម្រួលជាមួយការពិនិត្យវឌ្ឍនភាព **ផ.យ.អ.ជ.** ប្រចាំឆ្នាំផងដែរ។ អង្គភាពមួយដែលទទួលខុសត្រូវលើ M&E នឹងត្រូវបង្កើតឡើង នៅក្នុងលេខាធិការដ្ឋាននេះ។ យន្តការសម្របសម្រួលមួយនៅក្នុងក្រសួងផែនការ នឹងត្រូវស្នើឱ្យបង្កើតឡើង សម្រាប់ធ្វើសមាហរណកម្មក្របខ័ណ្ឌនេះក្នុងប្រព័ន្ធ M&E សម្រាប់ **ផ.យ.អ.ជ.**។

អនុក្រុមមួយ នៃក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុសម្រាប់ M&E នឹងត្រូវបង្កើតឡើង ដើម្បីសម្របសម្រួលការផ្លាស់ប្តូរទិន្នន័យ និងការបញ្ជ្រាបក្របខ័ណ្ឌនេះនៅក្នុងក្រសួងពាក់ព័ន្ធ។ ក្រសួងពាក់ព័ន្ធ វិទ្យាស្ថានជាតិស្ថិតិ និងភាគីដទៃទៀត ដែលមានចំណាប់អារម្មណ៍ចូលរួមនៅក្នុងដំណើរការនេះ ត្រូវឯកភាពគ្នាលើសូចនាករ នីតិវិធី និងការទទួលខុសត្រូវនានាលើការប្រមូលទិន្នន័យ។

ត្រូវសិក្សាអំពីភាពជាដៃគូមួយជាមួយគ្រឹះស្ថានស្រាវជ្រាវ និងគ្រឹះស្ថានសិក្សានានា សម្រាប់គ្រប់គ្រងបណ្តាញការងារនៃទីតាំងទាំងឡាយ សម្រាប់ការពិនិត្យតាមដានរយៈពេលវែង។ រចនាសម្ព័ន្ធនេះក៏អាចយកទៅប្រើប្រាស់ផងដែរ សម្រាប់ការសិក្សាវាយតម្លៃបណ្តោះអាសន្ន អំពីប្រសិទ្ធភាពនៃការងារបន្សាំនិងការកាត់បន្ថយការបញ្ចេញឧស្ម័ន ដោយផ្អែកលើទិន្នន័យដែលបណ្តាញនេះប្រមូលបាន។

## **៩. សេចក្តីសន្និដ្ឋាន**

រាជរដ្ឋាភិបាលកម្ពុជាដាក់ចេញនូវ **ផ.យ.ប.អ.ក.** ជាវិធានការត្រូវអនុវត្តបន្ត ក្នុងការឆ្លើយតបខាងគោលនយោបាយជាតិ ដោយផ្តល់នូវក្របខ័ណ្ឌមួយ សម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងតម្រង់ទិសអន្តរកាល ឈានទៅរកការអភិវឌ្ឍដែលបញ្ចេញកាបូនតិច និងធន់នឹងអាកាសធាតុ។ **ផ.យ.ប.អ.ក.** គាំទ្រដល់ការត្រៀមលក្ខណៈរបស់ជាតិ ក្នុងការឆ្លើយតបទៅនឹងហានិភ័យអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ ហើយពង្រឹងជាបន្ថែមលើឱកាសនានា ដែលលេចឡើងថ្មី ដូចជាការអភិវឌ្ឍបៃតង ការកៀរគរមូលនិធិអាកាសធាតុពីប្រភពទ្វេភាគីនិងពហុភាគី និងពង្រឹងការចូលរួមឱ្យមានប្រសិទ្ធភាពនៅក្នុងការពិភាក្សា និងការចរចាជាអន្តរជាតិ អំពីការប្រែប្រួលអាកាសធាតុ ទាំងនៅថ្នាក់តំបន់ និងកម្រិតពិភពលោក។

**ផ.យ.ប.អ.ក.** នឹងជួយពង្រឹងសមត្ថភាព ក្នុងការដោះស្រាយផលប៉ះពាល់អាកាសធាតុមកលើដំណើរការអភិវឌ្ឍន៍ជាតិ តាមរយៈការសម្របសម្រួលកិច្ចប្រឹងប្រែងនានា ដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជន និងប្រព័ន្ធធម្មជាតិ ដែលទ្រទ្រង់ដល់ការចិញ្ចឹមជីវិត ហើយជំរុញកំណើនសេដ្ឋកិច្ច និងវិបុលភាពជាតិ។ ការអនុវត្ត **ផ.យ.ប.អ.ក.** នឹងពង្រឹងសមត្ថភាពជាតិ បង្កើនការយល់ដឹង និងគាំទ្រការធ្វើសេចក្តីសម្រេចដោយផ្អែកលើចំណេះដឹង ដែលទទួលបានពីការអនុវត្តសកម្មភាពនានា ដែលជាវិភាគទានដ៏សំខាន់សម្រាប់ដំណោះស្រាយប្រកបដោយនិរន្តរភាព។ ការកសាងភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន នឹងបង្កើតជាវេទិកាសម្រាប់ការចូលរួមយ៉ាងសកម្ម និងការកៀរគរធនធានសម្រាប់អនុវត្តយុទ្ធសាស្ត្រនេះ។

## ឧបសម្ព័ន្ធ

### *ឧបសម្ព័ន្ធ ១ ៖ វិភាគទាននៃគោលដៅ ផ.យ.ប.អ. តាមវិស័យ ទៅក្នុងគោលដៅយុទ្ធសាស្ត្រនៃ ផ.យ.ប.អ.ក.*

ស្របជាមួយការកសាង **ផ.យ.ប.អ.ក.** ក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួន បានរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងប្រែប្រួលអាកាសធាតុ (**ផ.យ.ប.អ.**) តាមវិស័យរបស់ខ្លួន។ វិធានការមួយចំនួនត្រូវបានអនុវត្ត ដើម្បីបន្សុី **ផ.យ.ប.អ.ក.** និង **ផ.យ.ប.អ.** តាមវិស័យ នៅក្នុងដំណើរការរៀបចំផែនការនេះ និងក្នុងការបង្កើតទំនាក់ទំនងរវាងផែនការយុទ្ធសាស្ត្រទាំងនេះ ដើម្បីបញ្ចៀសភាពត្រួតគ្នា ដោយសារឯកសារទាំងពីរនេះ ផ្តោតលើការអនុវត្តនៅកម្រិតខុសៗគ្នា។ ទិសដៅជាយុទ្ធសាស្ត្រនៃ **ផ.យ.ប.អ.ក.** ត្រូវបានបង្កើតឡើង ដោយផ្អែកមួយផ្នែកលើទិសដៅជាយុទ្ធសាស្ត្រនៃ **ផ.យ.ប.អ.** តាមវិស័យរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ រួមមានក្រសួងបរិស្ថាន (ក.ប.ស.) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ក.ក.រ.ន.) ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (ក.ឧ.រ.ថ.) ក្រសួងអប់រំ យុវជន និងកីឡា (ក.អ.យ.ក.) ក្រសួងសុខាភិបាល (ក.ស.ភ.) ក្រសួងកិច្ចការនារី (ក.ក.ន.) ក្រសួងធនធានទឹក និងឧតុនិយម (ក.ធ.ទ.ឧ.) ក្រសួងសាធារណការ និងដឹកជញ្ជូន (ក.ស.ដ.) ក្រសួងអភិវឌ្ឍន៍ជនបទ (ក.អ.ជ.) និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម.)។

តារាងទី១. ការវិភាគគោលដៅនៃ **ផ.យ.ប.អ.** តាមវិស័យ ធៀបនឹងទិសដៅជាយុទ្ធសាស្ត្រនៃ **ផ.យ.ប.អ.ជ.**

| ១. លើកកម្ពស់ភាពធន់នឹងអាកាសធាតុតាមរយៈការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង ទឹក និងថាមពល។ | |
|---|---|
| ក.ប.ស. | • ជំរុញ និងលើកទឹកចិត្តអ្នកពាក់ព័ន្ធ និងវិស័យនានា ឱ្យចូលរួមនៅក្នុងការកំណត់វិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។<br>• ពង្រឹងយន្តការសម្របសម្រួល សម្រាប់ការឆ្លើយតបឱ្យស៊ីសង្វាក់គ្នា នៅក្នុងគោលនយោបាយឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។<br>• បង្កើនសមត្ថភាពក្នុងការកំណត់រកកាលានុវត្តភាព ដែលកើតចេញពីការប្រែប្រួលអាកាសធាតុ នៅក្នុងប្រព័ន្ធផលិតកម្មកសិកម្ម ប្រព័ន្ធអេកូឡូស៊ី និងតំបន់ការពារធម្មជាតិ។<br>• សម្រួលដល់ធុរកិច្ច និងឧស្សាហកម្ម ដែលឆ្លើយតបទៅនឹងកាលានុវត្តភាពទីផ្សារកាបូន សម្រាប់ពាណិជ្ជកម្ម និងការវិនិយោគបៃតង។<br>• ការគ្រប់គ្រងសំណល់រឹង/រាវតាមវិធានការចម្រុះ នៅរាជធានី ទីក្រុងទីប្រជុំជន និងការគ្រប់គ្រងសំណល់សត្វ។<br>• បញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ |

| | |
|---|---|
| ក.ក.រ.ន. | • ជំរុញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ ផលិតកម្មសត្វ និងដំណាំ។<br>• បង្កើនការប្រើប្រាស់ថាមពលកកើតឡើងវិញ (ជីវៈម៉ាស និងជីវឧស្ម័ន) ប្រសិទ្ធភាពនិងការប្រើប្រាស់បច្ចេកវិទ្យាសាស្ត្រកសិកម្មឱ្យបានសមស្រប។ |
| ក.ឧ.រ.ថ. | • កៀរគរធនធានតាមរយៈការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុ។ |
| ក.ស.ភ. | • កែលម្អហេដ្ឋារចនាសម្ព័ន្ធថែទាំសុខភាព និងសមត្ថភាពបុគ្គលិកពេទ្យ ដើម្បីទប់ទល់នឹងជម្ងឺ ពីភ្នាក់ងារចម្លង និងជម្ងឺឆ្លងតាមទឹក នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។ |
| ក.ស.ជ. | • កែលម្អឥន្ធនៈដែលបានពីប្រេងកាត។ |
| ក.អ.ជ. | • គាំទ្រដល់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការបង្កើតឱកាសធុរកិច្ចនៅមូលដ្ឋានដែលផ្តោតលើការផ្តល់មីក្រូឥណទានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម។ |
| ២. កាត់បន្ថយភាពងាយរងគ្រោះតាមវិស័យ តំបន់ យេនឌ័រ និងសុខភាព នៅចំពោះមុខផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ | |
| ក.ប.ស. | • ប្រើប្រាស់លទ្ធផលនៃការសិក្សាវាយតម្លៃដែលមានស្រាប់អំពីភាពងាយរងគ្រោះ និងហានិភ័យ ព្រមទាំងសិក្សាវាយតម្លៃជាថ្មី នៅក្នុងករណីចាំបាច់។<br>• លើកកម្ពស់វិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុថ្នាក់សហគមន៍ និងពង្រឹងភាពជាដៃគូរវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន។<br>• កែលម្អស្ថានប្រព័ន្ធព្រៃឈើព្រៃលិចទឹកតំបន់ឆ្នេរ និងតំបន់ការពារធម្មជាតិ។ |
| ក.ក.រ.ន. | • ជំរុញកសិករដែលងាយរងគ្រោះឱ្យប្រើប្រាស់បច្ចេកវិទ្យាថ្មីៗលើផលិតកម្មសត្វ និងដំណាំ។<br>• លើកកម្ពស់ប្រសិទ្ធភាពនៃអន្តរាគមន៍ខាងការសង្គ្រោះ និងស្តារការខូចខាតឡើងវិញ។<br>• កែលម្អប្រសិទ្ធភាពនៃការគ្រប់គ្រងវិស័យជលផល។<br>• ពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ។<br>• លើកកម្ពស់ផលិតកម្មកៅស៊ូធម្មជាតិដោយនិរន្តរភាព ដោយផ្តោតលើវិធានការបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ។<br>• លើកកម្ពស់ការអភិវឌ្ឍផលិតកម្មសត្វ និងការពារសុខភាពសត្វដោយនិរន្តរភាព។ |
| ក.ឧ.រ.ថ. | • រួមបញ្ចូលគោលគំនិតអំពីយេនឌ័រទៅក្នុង **ផ.យ.ប.អ.** តាមវិស័យ |
| ក.អ.យ.ក. | • ពង្រឹងគុណភាពនៃការអប់រំគ្រូបង្រៀន និងការបណ្តុះបណ្តាលអ្នកកសាងផែនការអំពីវិធីសាស្ត្របង្រៀន និងសិក្សារៀនសូត្រស្តីពីការប្រែប្រួលអាកាសធាតុ។ |

| | |
|---|---|
| | • សាងសង់សាលារៀនដែលឆ្លើយតបនឹងការបន្សាំ ទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យ។ |
| ក.ក.ន. | • បង្កើតលក្ខណៈវិនិច្ឆ័យដោយផ្អែកលើបេកគំហើញនៃការវិភាគភាពងាយរងគ្រោះ និងការបន្សាំ សម្រាប់ចាត់ជាអាទិភាពនូវតម្រូវការរបស់ស្ត្រី ដើម្បីឱ្យមានសកម្មភាពបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ |
| ក.ធ.ទ.ន. | • ណែនាំពីបច្ចេកវិទ្យាអភិវឌ្ឍន៍ និងការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។ |
| ក.ស.ជ. | • លើកកម្ពស់ការកសាងផែនការ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននៅទីក្រុង ដែលត្រូវការដើមទុនច្រើន។ |
| ក.អ.ជ. | • ពង្រឹងគុណភាពហេដ្ឋារចនាសម្ព័ន្ធជនបទ (ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ អណ្តូង និងលូដោះទឹក) ដើម្បីឱ្យធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត។<br>• កសាងគោលនយោបាយ និងការសិក្សា ដើម្បីឱ្យការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទ (ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ អណ្តូងស្រះ និងស្ពាន) ធន់នឹងការប្រែប្រួលអាកាសធាតុ។ |
| គ.ជ.គ.ម. | • បង្កើនការយកចិត្តទុកដាក់ចំពោះហានិភ័យ។<br>• លើកកម្ពស់ប្រព័ន្ធផ្តល់ដំណឹងជាមុនអំពីអាកាសធាតុ។ |
| ៣. លើកកម្ពស់ភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (បឹងទន្លេសាប ទន្លេមេគង្គ តំបន់ឆ្នេរ តំបន់ខ្ពង់រាប ។ល។) ជីវៈចម្រុះ តំបន់ការពារធម្មជាតិ និងតំបន់បេតិកភណ្ឌវប្បធម៌។ | |
| ក.ប.ស. | • ពង្រឹងការអភិរក្សជីវៈចម្រុះ និងស្តារប្រព័ន្ធអេកូឡូស៊ី ដែលរងការគម្រាមកំហែងពីការប្រែប្រួលអាកាសធាតុ។<br>• លើកកម្ពស់ និងលើកទឹកចិត្តឱ្យមានដំណោះស្រាយដែលផ្អែកលើសហគមន៍ និងផ្អែកលើប្រព័ន្ធអេកូឡូស៊ី និងអេកូទេសចរណ៍ ជាមធ្យោបាយដ៏មានប្រសិទ្ធភាព ក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។<br>• លើកកម្ពស់ការប្រើប្រាស់ការបង់ថ្លៃសេវាប្រព័ន្ធអេកូឡូស៊ី ដែលរួមទាំងកម្មវិធីកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ (REDD+)។ |
| ក.ក.រ.ន. | • លើកទឹកចិត្តឱ្យមានការអភិរក្ស និងគ្រប់គ្រងធនធានព្រៃឈើដោយនិរន្តរភាព។<br>• លើកកម្ពស់ការអភិវឌ្ឍ និងកែលម្អប្រសិទ្ធភាពនៃការគ្រប់គ្រងវិស័យជលផល។<br>• កែលម្អស្ថានប្រព័ន្ធព្រៃឈើ និងការពារព្រៃលិចទឹក។ |

| | |
|---|---|
| | • លើកកម្ពស់ការអភិរក្ស និងគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព។<br>• លើកកម្ពស់ការគ្រប់គ្រង និងអភិរក្សជលផល និងវារីវប្បកម្មដោយនិរន្តរភាព។ |
| ក.ធ.ទ.ឱ. | • កសាងផែនការធនធានទឹកចម្រុះសម្រាប់រយៈពេលវែង ដែលផ្តល់ឱកាសប្រសើរបំផុតក្នុងការកាត់បន្ថយឥទ្ធិពលអវិជ្ជមាននៃកំណើនកម្ពស់ទឹកសមុទ្រ។ |
| ៤. លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យា ដែលបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព។ | |
| ក.ប.ស. | • សិក្សាវិភាគទៅលើជម្រើស ដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិចនៅតាមវិស័យ និងប្រភពបញ្ចេញឧស្ម័ន។<br>• រៀបចំគោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងផែនការសកម្មភាពអភិវឌ្ឍន៍ ដែលបញ្ចេញកាបូនតិច ដោយអនុលោមតាមអាទិភាពអភិវឌ្ឍន៍នានារបស់ជាតិ។<br>• ជំរុញការផ្ទេរបច្ចេកវិទ្យាសមស្រប ដើម្បីលើកកម្ពស់ការអភិវឌ្ឍ ដែលបញ្ចេញកាបូនតិច។ |
| ក.ក.រ.ន. | • បង្កើនការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ពីការបាត់បង់ព្រៃឈើ និងការរេចរិលព្រៃឈើ ផលិតកម្មសត្វ និងដំណាំ និងផលិតកម្មបឋម។ |
| ក.ឧ.រ.ថ. | • គាំទ្រ និងបង្កើតច្បាប់ គោលនយោបាយ គោលការណ៍ណែនាំបច្ចេកទេស និងឯកសារណែនាំបច្ចេកទេស ដែលទាក់ទងនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមក លើវិស័យកម្មន្តសាល ឧស្សាហកម្ម និងថាមពល។ |
| ក.ស.ដ. | • បង្កើនការត្រួតពិនិត្យ និងថែរក្សាយានយន្ត។<br>• លើកកម្ពស់ការដឹកជញ្ជូនសាធារណៈតាមទីក្រុងធំៗ។<br>• ជំរុញបច្ចេកវិទ្យាដឹកជញ្ជូន ដែលមានប្រសិទ្ធភាព និងមានការទទួលស្គាល់ សម្រាប់កាត់បន្ថយ និងការអភិវឌ្ឍដែលបញ្ចេញកាបូនកម្រិតទាប។<br>• លើកកម្ពស់ការបើកបរដែលមានប្រសិទ្ធភាព។ |
| ៥. ពង្រឹងសមត្ថភាព ចំណេះដឹង និងការយល់ដឹងសម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ | |
| ក.ប.ស. | • ជំរុញការអនុវត្តមាត្រាទី៦ នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។<br>• ពង្រឹងមធ្យោបាយដែលមានស្រាប់សម្រាប់លើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ។<br>• ផ្សព្វផ្សាយដល់វិស័យឯកជនឱ្យស្វែងយល់អំពីការគំរាមកំហែង និងកាលានុវត្តភាព ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងបង្កើតភាពជាដៃគូសាធារណៈ និងឯកជនសម្រាប់ការប្រាស្រ័យទាក់ទង។<br>• ពង្រឹងសមត្ថភាពក្នុងការប្រមូល វិភាគ ធ្វើម៉ូដែល និងបកស្រាយទិន្នន័យអាកាសធាតុ ហើយផ្សព្វផ្សាយព័ត៌មានអាកាសធាតុដល់អ្នកប្រើប្រាស់។ |

| | |
|---|---|
| | • ប្រើប្រាស់មេរៀនដែលទទួលបាន ចំណេះដឹង និងទម្លាប់ល្អៗនៅមូលដ្ឋាន សម្រាប់កសាងគោលនយោបាយ និងសកម្មភាពបន្សាំ និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។<br>• បង្កើត "មជ្ឈមណ្ឌលគ្រប់គ្រងចំណេះដឹង" ដើម្បីសម្រួលដល់ការទទួលបានព័ត៌មានទាន់ហេតុការណ៍ ដែលចាំបាច់សម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ |
| ក.ក.រ.ន. | • កែលម្អសមត្ថភាពមនុស្ស និងស្ថាប័នអំពីបច្ចេកវិទ្យាថ្មីៗខាងដំណាំ កៅស៊ូ ផលិតកម្មសត្វ ព្រៃឈើ និងជលផល ដែលមានសមត្ថភាពបន្សាំចំពោះគ្រោះរាំងស្ងួត ទឹកជំនន់ កំណើនសីតុណ្ហភាព ការជ្រាបចូល នៃទឹកជំនន់ និងការបំផ្លិចបំផ្លាញដោយសត្វល្អិត និងជម្ងឺនានា។<br>• ពង្រឹងសេវាកម្មផ្សព្វផ្សាយអំពីការផ្ទេរបច្ចេកវិទ្យាសម្រាប់សុវត្ថិភាពស្បៀង។<br>• លើកកម្ពស់ការស្រាវជ្រាវ និងវារីវប្បកម្មគ្រប់ប្រភេទ។<br>• លើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស ដែលមានសារៈសំខាន់ក្នុងវិភាគទានដល់ការបន្សាំ និងកាត់បន្ថយផលប៉ះពាល់មកលើផលិតកម្មដំណាំ កៅស៊ូ សត្វ ព្រៃឈើ និងធនធានជលផល។<br>• ផ្តល់ការបណ្តុះបណ្តាលអប់រំអំពីការផ្សព្វផ្សាយ ការផ្ទេរ និងចែករំលែកព័ត៌មាន។<br>• កសាងសមត្ថភាពអំពីការប្រើប្រាស់បច្ចេកវិទ្យាសមស្រប ដែលគ្មានឥទ្ធិពលមកលើសុខភាពសាធារណៈ។<br>• កសាងសមត្ថភាពអំពីការប្រើប្រាស់បច្ចេកវិទ្យាសមស្រប ដែលគ្មានឥទ្ធិពលមកលើសុខភាពសាធារណៈ (ផលិតកម្មសត្វ)។<br>• ពង្រឹងសមត្ថភាព និងការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ (ក្នុងវិស័យជលផល)។ |
| ក.ឧ.រ.ថ. | • ពង្រឹងសមត្ថភាពធនធានមនុស្ស ជំនាញ បទពិសោធ និងការអភិវឌ្ឍស្ថាប័ន។<br>• កសាង និងជំរុញយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង ការចែករំលែកព័ត៌មាន ដែលមានមេត្រីភាពជាមួយបរិស្ថាន និងបៃតង ទាក់ទងនឹងកម្មន្តសាល ឧស្សាហកម្ម និងថាមពល។<br>• លើកទឹកចិត្តឱ្យបង្កើតការស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យា។ |
| ក.អ.យ.ក. | • កែលម្អគោលនយោបាយអប់រំ ការវិភាគ ការស្រាវជ្រាវ និងកសាងផែនការសម្រាប់ការប្រែប្រួលអាកាសធាតុ។<br>• ពង្រឹងគុណភាពនៃការអប់រំគ្រូបង្រៀន និងការបណ្តុះបណ្តាលអ្នកកសាងផែនការអំពីវិធីសាស្ត្របង្រៀន និងសិក្សារៀនសូត្រអំពីការប្រែប្រួលអាកាសធាតុ។<br>• បណ្តុះបណ្តាលតាមកម្មវិធីស្តីពីការបន្សាំ ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។ |

| | |
|---|---|
| | • បង្កើនការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងពង្រឹងកម្មវិធីអប់រំក្រៅប្រព័ន្ធ តាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសាធារណៈ បណ្តាញ និងភាពជាដៃគូ។ |
| ក.ស.ភ. | • កែលម្អហេដ្ឋារចនាសម្ព័ន្ធថែទាំសុខភាព និងសមត្ថភាពបុគ្គលិកពេទ្យ ដើម្បីទប់ទល់នឹងជម្ងឺពីភ្នាក់ងារបង្ករោគ និងជម្ងឺឆ្លងតាមទឹក នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។<br>• កែលម្អចំណេះដឹង និងសមត្ថភាពស្រាវជ្រាវអំពីផលប៉ះពាល់មកលើសុខភាព និងភាពងាយរងគ្រោះ នៅចំពោះមុខការប្រែប្រួលអាកាសធាតុ ជាមូលដ្ឋានព័ត៌មានសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការយុទ្ធសាស្ត្រសុខភាពរបស់ ក្រសួងសុខាភិបាល និងផែនការវិស័យផ្សេងទៀត។ |
| ក.ក.ន. | • បង្កើនកម្រិតយល់ដឹងដល់អ្នកកសាងគោលនយោបាយសាធារណៈ អំពីសារៈសំខាន់នៃសមភាពយេនឌ័រនៅក្នុងការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដើម្បីសម្រេចគោលបំណងតាមវិស័យនៅក្នុងការងារប្រែប្រួលអាកាសធាតុ។<br>• ពង្រឹងសមត្ថភាពដើម្បីកសាងផែនការអនុវត្ត និងពិនិត្យតាមដានកិច្ចផ្តួចផ្តើមបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុដែលរួមបញ្ចូលយេនឌ័រ។ |
| ក.ធ.ទ.ឧ. | • បញ្ជ្រាបការយល់ដឹង និងចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុ ដែលទាក់ទងនឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក ដល់គ្រប់ទិដ្ឋភាពទាំងអស់នៃការអភិវឌ្ឍដែលទាក់ទងនឹងទឹក នៅថ្នាក់មូលដ្ឋាន ខេត្ត និងជាតិ តាមរយៈស្ប៉តទូរទស្សន៍ វិទ្យុ និងយុទ្ធនាការព័ត៌មាន។<br>• កសាងសមត្ថភាពបុគ្គលិក អំពីធនធានទឹកនិងការប្រែប្រួលអាកាសធាតុ តាមរយៈការសិក្សារយៈពេលវែង វគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងទស្សនកិច្ចសិក្សានៅក្នុង និងក្រៅប្រទេស និងក្នុងតំបន់។<br>• ពង្រឹងសមត្ថភាពកសិករនៅមូលដ្ឋាន ជាពិសេសសមាជិកសមាគមកសិករប្រើប្រាស់ទឹក អំពីការជ្រើសរើសពូជដំណាំ ដែលមិនសូវត្រូវការទឹក និងការកសាងផែនការសម្រាប់ប្រព័ន្ធដំណាំដែលមិនសូវត្រូវការទឹក សម្រាប់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។<br>• បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់ប្រមូល និងចែករំលែកទិន្នន័យ និងព័ត៌មានអំពីបញ្ហាប្រែប្រួលអាកាសធាតុ ដែលទាក់ទងនឹងធនធានទឹក និងសមត្ថភាពបន្សាំ/កាត់បន្ថយសម្រាប់អ្នកពាក់ព័ន្ធនានា។<br>• បង្កើត និងកែលម្អបណ្តាញសម្រាប់ឧតុនិយម និងជលសាស្ត្រ ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ទឹកភ្លៀង ទឹកជំនន់ គ្រោះរាំងស្ងួត និងធាតុអាកាស។ |

| | |
|---|---|
| | • បង្កើតសេវាឧតុនិយមដែលអាចទុកចិត្តបាន និងដែលអាចព្យាករណ៍បាន។<br>• កែលម្អសមត្ថភាពធនធានមនុស្សនៅថ្នាក់ជាតិ និងខេត្ត ដើម្បីឆ្លើយតបនឹងលក្ខខណ្ឌរបស់អ្នកផ្តល់សេវាព័ត៌មានឧតុនិយមដែលមានគុណភាពខ្ពស់។<br>• បង្កើតប្រព័ន្ធជូនដំណឹងជាមុននៅថ្នាក់ជាតិ និងផ្តល់ព័ត៌មានដែលទាក់ទងនឹងការបំពុលខ្យល់។ |
| ក.ស.ជ. | • បង្កើនការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ ដែលបង្កដោយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីវិស័យដឹកជញ្ជូន។ |
| ក.អ.ជ. | • គាំទ្រដល់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈបង្កើនការយល់ដឹងនៅជនបទអំពីគោលគំនិតនៃការប្រែប្រួលអាកាសធាតុ និងជម្រើសនៃការឆ្លើយតប។<br>• ផ្តល់ការអភិវឌ្ឍសមត្ថភាពដល់សមាជិកគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ អំពីជម្រើសបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងប្រើប្រាស់ចំណេះដឹងវិទ្យាសាស្ត្រដទៃទៀត ដែលអាចបន្សាំសម្រាប់ប្រជាពលរដ្ឋនៅមូលដ្ឋានប្រើប្រាស់ (ការថែទាំសុខភាពបឋម អនាម័យទឹក ការផ្សព្វផ្សាយ លទ្ធផលនៃការស្រាវជ្រាវ និងការអភិវឌ្ឍសហគមន៍)។ |
| គ.ជ.គ.ម. | • កសាងភាពធន់ទៅនឹងគ្រោះមហន្តរាយ និងសមត្ថភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅគ្រប់លំដាប់ថ្នាក់ តាមរយៈការអប់រំ។ |
| ៦. លើកកម្ពស់ការចូលរួម និងកិច្ចគាំពារសង្គមបែបបន្សាំនឹងការប្រែប្រួលអាកាសធាតុដើម្បីកាត់បន្ថយការបាត់បង់ និងខូចខាត។ | |
| ក.ប.ស. | • ជំរុញដំណើរការវិមជ្ឈការ ដើម្បីពង្រឹងដំណើរការហិរញ្ញវត្ថុ និងស្ថាប័នសម្រាប់ការបន្សាំនៅមូលដ្ឋាន។<br>• ចាត់ចែងជាលក្ខណៈប្រព័ន្ធសម្រាប់ការចូលរួម និងការពិគ្រោះយោបល់ជាសាធារណៈ សម្រាប់កសាងផែនការបន្សាំ ការលើកកម្ពស់ឱ្យអ្នកពាក់ព័ន្ធនានាបានចូលរួម ទាំងអង្គការមិនមែនរដ្ឋាភិបាល អង្គការសហគមន៍ យុវជន សហគមន៍ជនជាតិដើមភាគតិច និងវិស័យឯកជន។<br>• លើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជនរួមទាំងការទទួលខុសត្រូវចំពោះសង្គមរបស់ក្រុមហ៊ុនផងដែរ។ |
| ក.ឧ.រ.ថ. | • លើកទឹកចិត្ត និងជំរុញការចូលរួមរបស់វិស័យឯកជននៅក្នុង **ផ.យ.ប.អ.** តាមវិស័យ។<br>• រួមបញ្ចូលគោលគំនិតអំពីយេនឌ័រទៅក្នុង។ |
| ក.ក.ន. | • បង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងការកសាងគោលនយោបាយប្រែប្រួលអាកាសធាតុ។<br>• បង្កើតបទបញ្ញាមូលនិធិសម្រាប់កិច្ចផ្តួចផ្តើមយេនឌ័រ និងការប្រែប្រួលអាកាសធាតុ និងដាក់ឱ្យ |

| | |
|---|---|
| | ប្រតិបត្តិការតាមរយៈថវិកា ដែលឆ្លើយតបនឹងបញ្ហាយេនឌ័រនៅក្នុងគម្រោង កម្មវិធី គោលនយោបាយ បច្ចុប្បន្ន និងអនាគត (ទាំងធនធានពីខាងក្រៅនិងខាងក្នុងប្រទេស)។<br>• កំណត់រកយន្តការដែលមានប្រសិទ្ធភាព សម្រាប់ពង្រីកបទពិសោធ ដែលមានការទទួលស្គាល់អំពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ។<br>• ជំរុញ និងវិភាគមេរៀន និងទម្លាប់ល្អៗអំពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ សម្រាប់ការចែករំលែក និងការរៀនសូត្រនៅក្នុងវេទិកាជាតិតំបន់និងពិភពលោក។ |
| ក.ធ.ទ.ឧ. | • ពង្រឹងសមត្ថភាពកសិករនៅមូលដ្ឋាន ជាពិសេសសមាជិកគណៈកម្មាធិការកសិករប្រើប្រាស់ទឹក អំពីការជ្រើសរើសពូជដំណាំ ដែលមិនសូវត្រូវការទឹក និងការកសាងផែនការសម្រាប់ប្រព័ន្ធដំណាំដែលមិនសូវត្រូវការទឹកសម្រាប់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ |
| ក.អ.ជ. | • គាំទ្រការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការបង្កើតឱកាសធុរកិច្ចនៅមូលដ្ឋាន ដែលផ្តោតលើការផ្តល់មីក្រូឥណទានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។ |
| គ.ជ.គ.ម. | • ផ្សារភ្ជាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។ |
| ៧. ពង្រឹងស្ថាប័ន និងក្របខ័ណ្ឌការងារសម្របសម្រួល សម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ។ | |
| ក.ប.ស. | • ពង្រឹងក្របខ័ណ្ឌស្ថាប័នជាតិ និងការសម្របសម្រួលអន្តរក្រសួងនៅក្នុងការកសាងគោលនយោបាយ។<br>• ពង្រឹងតួនាទី និងសមត្ថភាពរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ។<br>• បង្កើតក្របខ័ណ្ឌជាតិសម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃអំពីការប្រែប្រួលអាកាសធាតុ។<br>• លើកទឹកចិត្តក្រសួងពាក់ព័ន្ធឱ្យកសាងយុទ្ធសាស្ត្រ និងផែនការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ។ |
| ក.ឧ.រ.ថ. | • ពង្រឹងសមត្ថភាពធនធានមនុស្សជំនាញបទពិសោធ និងការអភិវឌ្ឍស្ថាប័ន។<br>• កៀរគរធនធានតាមរយៈការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុ។ |
| ក.អ.យ.ក. | • កែលម្អគោលនយោបាយសិក្សាអប់រំ វិភាគ ស្រាវជ្រាវ និងកសាងផែនការ អំពីការប្រែប្រួលអាកាសធាតុ។ |
| ក.ក.ន. | • ពង្រឹងសមត្ថភាព ដើម្បីកសាងផែនការអនុវត្តន៍ និងពិនិត្យតាមដានកិច្ចផ្តួចផ្តើមបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដែលរួមបញ្ចូលយេនឌ័រ។ |
| ក.ធ.ទ.ឧ. | • កៀរគរ និងធានាឱ្យមានធនធានហិរញ្ញវត្ថុសម្រាប់កម្មវិធី គម្រោង ការស្រាវជ្រាវ និងអភិវឌ្ឍន៍ អំពីការបន្សាំឬកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដែលទាក់ទងនឹងធនធានទឹកពីស្ថាប័ន |

| | |
|---|---|
| | រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។<br>• ពង្រឹងកិច្ចសហប្រតិបត្តិការ និងយន្តការសម្របសម្រួលក្នុងចំណោមស្ថាប័នតាមវិស័យខុសៗគ្នា នៅថ្នាក់មូលដ្ឋានជាតិ តំបន់ និងអន្តរជាតិ ដោយអនុវត្តសកម្មភាពនានានៃការគ្រប់គ្រងធនធានទឹកបែបសមាហរណកម្ម សម្រាប់វិធានការបន្សាំ និងការកាត់បន្ថយ។ |
| ក.ស.ដ. | • ប្តូរការដឹកជញ្ជូនទំនិញតាមផ្លូវឆ្ងាយពីរថយន្តមករថភ្លើង។ |
| ៨. ពង្រឹងកិច្ចសហការ និងចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចខិតខំប្រឹងប្រែងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់តំបន់ និងពិភពលោក។ | |
| ក.ប.ស. | • លើកកម្ពស់កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ស្តីពីការប្រែប្រួលអាកាសធាតុ នៅក្នុងយន្តការអន្តររដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល។<br>• ពង្រឹងយន្តការស្ថាប័នជាតិសម្រាប់សម្របសម្រួលការពិគ្រោះយោបល់អំពីជំហរជាតិ និងការឆ្លើយតបទៅនឹងបញ្ហាបច្ចុប្បន្ន និងអនាគត ក្នុងការចរចាជាអន្តរជាតិអំពីការប្រែប្រួលអាកាសធាតុ។<br>• ពង្រឹងជំនាញចរចារបស់កម្ពុជាក្នុងកិច្ចចរចាអន្តរជាតិអំពីការប្រែប្រួលអាកាសធាតុ និងពង្រឹងសមត្ថភាពសម្រាប់អនុវត្តកាតព្វកិច្ចអន្តរជាតិនានា។<br>• ចូលរួមយ៉ាងសកម្មជាមួយកិច្ចផ្តួចផ្តើមនិងកម្មវិធីនៅថ្នាក់តំបន់ និងកម្រិតពិភពលោក សំដៅរៀនសូត្រពីគ្នាទៅវិញទៅមក និងចែករំលែកជាមួយអន្តរជាតិនូវបទពិសោធរបស់កម្ពុជាអំពីការប្រែប្រួលអាកាសធាតុ។<br>• ធានាឱ្យមានហិរញ្ញប្បទានអាកាសធាតុពីយន្តការផ្តល់មូលនិធិអន្តរជាតិ។ |
| ក.ធ.ទ.ឧ. | • ពង្រឹងកិច្ចសហប្រតិបត្តិការ និងយន្តការសម្របសម្រួលក្នុងចំណោមស្ថាប័នតាមវិស័យខុសៗគ្នា នៅថ្នាក់មូលដ្ឋាន ជាតិ តំបន់ និងអន្តរជាតិ ដោយអនុវត្តទិដ្ឋភាពនានានៃការគ្រប់គ្រងធនធានទឹកបែបសមាហរណកម្ម សម្រាប់វិធានការបន្សាំ និងការកាត់បន្ថយ។<br>• ពង្រីកបណ្តាញអាកាសធាតុនៅថ្នាក់ជាតិ និងអន្តរជាតិ។ |
| ក.ស.ដ. | • ពង្រឹងការគ្រប់គ្រងចរាចរណ៍។ |

### ឧបសម្ព័ន្ធ ២ ៖ ការវិភាគអាទិភាពនៃ ផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣ ធៀបនឹងទិសដៅជាយុទ្ធសាស្ត្រនៃ ផ.យ.ប.អ.ក.

<table>
<tr><th>អាទិភាពប្រែប្រួលអាកាសធាតុ នៅក្នុង ផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣</th><th>ទិសដៅជាយុទ្ធសាស្ត្រនៃ ផ.យ.ប.អ.ក.</th></tr>
<tr><td>• រៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។</td><td></td></tr>
<tr><td>• ជំរុញ និងសម្របសម្រួលការបញ្ជ្រាប់ការងារប្រែប្រួលអាកាសធាតុ ទៅក្នុងវិស័យពាក់ព័ន្ធ។</td><td>១. លើកកម្ពស់ភាពធន់នឹងអាកាសធាតុតាមរយៈការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង ទឹក និង ថាមពល។</td></tr>
<tr><td rowspan="2">• ជំរុញការអនុវត្តន៍ និងធ្វើបច្ចុប្បន្នកម្ម កម្មវិធីសកម្មភាពជាតិ ស្តីពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។</td><td>២. កាត់បន្ថយភាពងាយរងគ្រោះតាមវិស័យ តំបន់ យេនឌ័រ និងសុខភាព នៅចំពោះមុខផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។</td></tr>
<tr><td>៣. លើកកម្ពស់ ភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (បឹងទន្លេសាប ទន្លេមេគង្គ តំបន់ឆ្នេរ តំបន់ខ្ពង់រាប ។ល។) ជីវៈចម្រុះ តំបន់ការពារធម្មជាតិ និងតំបន់បេតិកភណ្ឌវប្បធម៌។</td></tr>
<tr><td>• បន្តកំណត់រក និងជំរុញការអនុវត្ត យន្តការអភិវឌ្ឍន៍ស្អាត និងគម្រោងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់នានា។</td><td rowspan="2">៤. លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យា ដែលបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព។</td></tr>
<tr><td>• ធ្វើវិមជ្ឈការ ការធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ និងរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យមូលដ្ឋាន។</td></tr>
<tr><td>• អប់រំ និងផ្សព្វផ្សាយ ដល់សាធារណជនស្តីពីការប្រែប្រួលអាកាសធាតុ។</td><td>៥. ពង្រឹងសមត្ថភាព ចំណេះដឹង និងការយល់ដឹងសម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។</td></tr>
<tr><td></td><td>៦. លើកកម្ពស់ការចូលរួម និងកិច្ចគាំពារសង្គមបែបបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដើម្បីកាត់បន្ថយការបាត់បង់ និងខូចខាត។</td></tr>
</table>

| | |
|---|---|
| • ពង្រឹងសមត្ថភាពរបស់ លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ។ | ៧. ពង្រឹងស្ថាប័ន និងក្របខ័ណ្ឌការងារសម្របសម្រួលសម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ។ |
| • ជំរុញនូវការបង្កើតមូលនិធិប្រែប្រួលអាកាសធាតុជាតិ។ | |
| • បន្តការរៀបចំ របាយការណ៍ជាតិលើកទី២ ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ | ៨. ពង្រឹងកិច្ចសហការនិងចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចខិតខំប្រឹងប្រែងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់តំបន់ និងពិភពលោក។ |
| • កៀរគរធនធាននិងការគាំទ្រសម្រាប់ដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។ | |